

# ការវាយប្រហារ និង ការគំរាមកំហែង
## អ្នកការពារសិទ្ធិមនុស្ស នៅកម្ពុជា

ឆ្នាំ ២០០៦

របាយការណ៍សង្ខេប លីកាដូ
ខែធ្នូ ឆ្នាំ២០០៦

លីកាដូ

LICADHO

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

Cambodian League for the
Promotion and Defense of Human Rights

# ការវាយប្រហារ និង ការគំរាមកំហែង
# អ្នកការពារសិទ្ធិមនុស្ស នៅកម្ពុជា ឆ្នាំ២០០៦

---

របាយការណ៍សង្ខេប លីកាដូ

ខែធ្នូ ឆ្នាំ២០០៦

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ នឹងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

លីកាដូ កំពុងបន្តសកម្មភាពរបស់ខ្លួនតាមរយៈការិយាល័យកម្មវិធីទាំង ៧ របស់ខ្លួន ដូចខាងក្រោម:

- **ការិយាល័យឯកសារ និងធនធានព័ត៌មាន** គឺជាការិយាល័យដែលរក្សាចងក្រងសំណុំរឿងនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីងាយស្រួលក្នុងការរកឯកសារ នឹងវិភាគអោយបានឆាប់រហ័ស។
- **ការិយាល័យអប់រំសិទ្ធិមនុស្ស**គឺជាការិយាល័យដែលបើកវគ្គបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ក្រុមគោលដៅនានា ដូចជា មន្ត្រីរាជការ សិស្ស និស្សិត ព្រះសង្ឃ ព្រមទាំងបើកវគ្គផ្សព្វផ្សាយសិទ្ធិមនុស្សដល់សាធារណៈជននានាថែមទៀតផង។
- **ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស** គឺជាការិយាល័យដែលមានតួនាទីជាអ្នកស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស និងជួយជនរងគ្រោះនានា ក្នុងដំណើរការបណ្តឹងដែលពាក់ព័ន្ធខាងផ្នែកច្បាប់ ។ បុគ្គលិកដែលមានការហ្វឹកហ្វឺនជំនាញត្រឹមត្រូវក៏បានឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីវាយតម្លៃស្ថានភាពពន្ធនាគារ ព្រមទាំងជួយ អោយពិរុទ្ធជនទាំងឡាយទទួលបាននូវតំណាងផ្នែកច្បាប់ទៀតផង។
- **ការិយាល័យពេទ្យ** គឺជាការិយាល័យដែលផ្តល់សេវាវេជ្ជសាស្ត្រដល់ពិរុទ្ធជន ទណ្ឌិត និងមន្ត្រីពន្ធនាគារនៅតាម ពន្ធនាគារចំនួន ១៨ កន្លែង។ ក្រៅពីនេះ ក៏បានផ្តល់សេវាវេជ្ជសាស្ត្រ និងជួយបញ្ជូនជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្សទៅមន្ទីរពេទ្យផងដែរ។
- **កម្មវិធីប្រឆាំងនឹងទារុណ្ណកម្ម** ជាការិយាល័យផ្តល់សេវាកម្មស្តារលទ្ធភាពទូទៅ ដល់ជនរងគ្រោះដោយអំពើទារុណ្ណកម្ម និងធ្វើការតស៊ូមតិប្រឆាំងនឹងអំពើទារុណ្ណកម្ម។
- **ការិយាល័យសិទ្ធិកុមារ** ជាការិយាល័យដែលផ្តល់ការអប់រំសិទ្ធិកុមារដល់សាធារណៈជនទូទៅ ស្តាបនាបណ្តាញ ការពារកុមារនៅតាមមូលដ្ឋាននានា និងស៊ើបអង្កេតការរំលោភសិទ្ធិកុមារ ។
- **ការិយាល័យសិទ្ធិស្ត្រី** ជាការិយាល័យអប់រំសិទ្ធិស្ត្រីដល់សាធារណៈជនទូទៅ ស៊ើបអង្កេតការរំលោភសិទ្ធិស្ត្រី និងធ្វើការតស៊ូមតិ ដើម្បីអោយមានការផ្លាស់ប្តូរផ្នែកច្បាប់ និងសង្គម។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការលីកាដូ

អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦, ផ្លូវលេខ ៩៩, រាជធានីភ្នំពេញ, កម្ពុជា

ទូរស័ព្ទ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ៣៦៤៩០១ , ទូរសារ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ២១៧ ៦២៦

អ៊ីម៉ែល: contact@licadho.org គេហទំព័រ: http://www.licadho.org/

# មាតិការឿង

**សង្ខេបប្រតិបត្តិ** ........ **១**

I.**សេចក្តីផ្តើម** ........ **៣**

អ្នកការពារសិទ្ធិមនុស្ស-តើពួកគេជានរណា ? ........ ៣

កិច្ចការពារស្របច្បាប់ចំពោះអ្នកការពារសិទ្ធិ ........ ៣

II. **សាវតា** ........ **៥**

សិទ្ធិមនុស្សនៅកម្ពុជា ........ ៥

ការបង្ក្រាបលើសង្គមស៊ីវិល ........ ៥

សហគមន៍អន្តរជាតិ ........ ៧

ឧបសគ្គផ្នែកច្បាប់ ........ ៨

III. **ការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្ស ខែមករា-តុលា ២០០៦** ........ **១០**

ជនរងគ្រោះ និងអ្នកប្រព្រឹត្ត ........ ១០

អង្គការសិទ្ធិមនុស្សមិនមែនរដ្ឋាភិបាល ........ ១០

អ្នកជួយជនភៀសខ្លួន ........ ១១

តំណាងសហជីពកម្មករ ........ ១៣

សកម្មជនដីធ្លី និងធនធានធម្មជាតិ ........ ១៨

IV. **អនុសាសន៍** ........ **២៨**

**ឧបសម្ព័ន្ធទី ១:តារាងឧបទ្ទវហេតុពាក់ព័ន្ធនិងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាខែមករា-តុលា ២០០៦** ...... **២៩**

**ឧបសម្ព័ន្ធទី២: សេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងស្ថាប័នសង្គមក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល១៩៩៨** ........ ៤៨

# សង្ខេបប្រតិបត្តិ

ឆ្នាំ២០០៦ ជាឆ្នាំដ៏អាក្រក់សំរាប់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ។ កាលពីថ្ងៃទី១ ខែមករា សកម្មជនសិទ្ធិមនុស្សដ៏សំខាន់បំផុតរបស់ប្រទេសចំនួនពីររូប ភ្ញាក់ពីដំណេកឡើងនៅក្នុងពន្ធនាគារព្រៃស បន្ទាប់ពីពួកគេត្រូវបានចាប់ខ្លួនកាលពីមួយថ្ងៃកន្លងទៅពីបទបរិហារកេរ្តិ៍រដ្ឋាភិបាល ។ រយៈពេលប៉ុន្មានថ្ងៃបន្ទាប់មក សកម្មជនសិទ្ធិមនុស្សទីបីក៏ត្រូវបានចាប់ខ្លួននិងដាក់ក្នុងពន្ធនាគារដែរ ។ សកម្មជនដទៃទៀតបានពួនលាក់ខ្លួន ក្លាយជាជនរងគ្រោះនៃអំពើបង្ក្រាបលើសេរីភាពក្នុងការបញ្ចេញមតិ ដែលជាការវាយប្រហារទៅលើសង្គមស៊ីវិលកម្ពុជាដែលមានសកម្មភាពរស់រវើក និងជាអ្នកដែលងាយទទួលរងគ្រោះ ។

ទោះបីជាមានការធ្វើអន្តរាគមន៍ពីសហគមន៍អន្តរជាតិ ដើម្បីដោះលែងសកម្មជនជាប់ឃុំខ្លួនក្នុងពន្ធនាគារទាំងបីរូបនៅចុងខែមករាក៏ដោយ តែការចាប់ខ្លួនសកម្មជនទាំងនោះ បង្កើតបានជាទស្សនីយភាពមួយនៃឆ្នាំដ៏អាក្រក់របស់អ្នកការពារសិទ្ធិមនុស្សនាសម័យកាលថ្មីៗនេះ ។ ទោះបីជារបាយការណ៍នេះគ្របដណ្តប់តែរយៈពេលដប់ខែនៃឆ្នាំ២០០៦ ប៉ុន្តែការវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើអ្នកការពារសិទ្ធិមនុស្សមានចំនួនច្រើនជាងក្នុងកំឡុងពេលដប់ខែក្នុងឆ្នាំ២០០៥ កន្លងទៅ ។

មានភស្តុតាងបង្ហាញពីការផ្លាស់ប្តូរទម្រង់នៃការគំរាមកំហែង និងការវាយប្រហារ ។ បុគ្គលិកនៃអង្គការសិទ្ធិមនុស្សជាតិកំពុងក្លាយជាគោលដៅនៃការយាយី បំភិតបំភ័យ និងការរារាំងដល់ការបំពេញការងាររបស់ពួកគេ ។ ប៉ុន្តែ ទម្រង់នៃការវាយប្រហារដែលមានលក្ខណៈធ្ងន់ធ្ងរ មានដូចជា ការវាយធ្វើបាបលើរូបរាងកាយ ឬការចាប់ខ្លួននិងដាក់ពន្ធនាគារកំពុងកើតមានច្រើនឡើងផ្ទាល់ទៅលើសកម្មជននៅតាមសហគមន៍ មេដឹកនាំសហជីពកម្មករ និងតំណាងក្រុមជនដែលគេមិនយកចិត្តទុកដាក់ និងជាជនដែលងាយរងគ្រោះដទៃទៀត ។ ដោយឆ្លុះបញ្ចាំងពីការកើនឡើងនូវរឿងវិវាទដីធ្លី និងធនធានធម្មជាតិដទៃទៀត ព្រមទាំងលក្ខខណ្ឌការងារដ៏អាក្រក់ វាជានិន្នាការមួយដែលទំនងជាមិនអាចផ្លាស់ប្តូរបាននៅថ្ងៃអនាគត ។ ការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរតែងតែសំដៅមកលើអ្នកការពារសិទ្ធិមនុស្ស ជាពិសេសអ្នកការពារសិទ្ធិមនុស្សនៅជនបទដាច់ស្រយាល និងអ្នកការពារសិទ្ធិមនុស្សដែលគ្មានអង្គការតាមផ្លូវការណាជួយគាំទ្រ ដែលអ្នកទាំងនោះទទួលបានកិច្ចការពារយ៉ាងតិចតួចជាងគេបំផុត ។

សហគមន៍អន្តរជាតិធ្វើការបានតិចតួច ដើម្បីបន្ធូរបន្ថយកំរិតនៃការកើនឡើងនៃការគំរាមកំហែងទៅលើអ្នកការពារសិទ្ធិមនុស្ស ។ លើកលែងតែចំពោះការចាប់ខ្លួនដោយសំអាងថាបានបរិហារកេរ្តិ៍រដ្ឋាភិបាល ដែលត្រូវបានគេផ្សព្វផ្សាយជាច្រើន សហគមន៍អន្តរជាតិម្ចាស់អ្នកផ្តល់ជំនួយដ៏មានឥទ្ធិពលពុំបានថ្កោលទោសចំពោះការចាប់ខ្លួននោះទេ ។ ជាក់ស្តែងនៅពេលប្រទេសផ្តល់ជំនួយជួបជាមួយរដ្ឋាភិបាល នៅឯកិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំនាខែមីនា គេពុំមានរបៀបវារៈស្តីពីសិទ្ធិមនុស្សទេ សូម្បីតែការគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្សក៏ពុំត្រូវបានគេលើកយកមកពិភាក្សាឡើយ ។

របាយការណ៍សង្ខេបនេះ ផ្តល់នូវការវិភាគមួយអំពីការកើនឡើងនូវការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា រវាងខែមករា ដល់ខែតុលា ឆ្នាំ២០០៦ ។ ឯកសារនេះផ្អែកតាមការស៊ើបអង្កេត និងព័ត៌មានដទៃ

ទៀត ដែលចងក្រងដោយអង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស-លីកាដូ ជាមួយនឹងការគាំទ្របន្ថែមពីការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា និងអង្គការសិទ្ធិមនុស្សរួមទាំងអង្គការនៅតាមសហគមន៍ក្នុងកម្ពុជាមួយចំនួនទៀត ។

របាយការណ៍សង្ខេបនេះពុំមានលក្ខណៈទូលំទូលាយឡើយ ។ អង្គការលីកាដូដឹងថាមានករណីគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្សជាច្រើនទៀតមិនត្រូវបានរាយការ ហើយមានសកម្មជនជាច្រើននាក់កំពុងប្រឈមមុខនឹងការបំភិតបំភ័យ និងការយាយីជារៀងរាល់ថ្ងៃ ។ ជាពិសេស ការគំរាមកំហែង និងវាយធ្វើបាបលើសកម្មជននៅតាមសហគមន៍ និងមេដឹកនាំសហជីពកម្មករជាផ្នែកមួយនៃបញ្ហាដែលគេបានមើលឃើញ (ដូចជាចំណុចកំពូលនៃផ្ទាំងទឹកកកដែលអណ្តែត) តែផ្ទុយទៅវិញវាកំពុងតែរីករាលដាល ។ អង្គការលីកាដូជឿជាក់ថា អាជ្ញាធរកម្ពុជា និងសហគមន៍អន្តរជាតិត្រូវតែមានវិធានការជាបន្ទាន់ដើម្បីបញ្ឈប់សកម្មភាពមិនប្រក្រតីទាំងនេះ ។

# I. សេចក្ដីផ្ដើម

## អ្នកការពារសិទ្ធិមនុស្ស តើពួកគេជានរណា ?

អ្នកការពារសិទ្ធិមនុស្ស គឺជាមនុស្សដែលជាបុគ្គល ឬរួមជាមួយអ្នកដទៃទៀត ធ្វើសកម្មភាពដើម្បីលើកស្ទួយ ឬការពារសិទ្ធិមនុស្សជាមូលដ្ឋានតាមវិធីអហិង្សាសកម្ម ។ អ្នកការពារសិទ្ធិមនុស្សអាចជាផ្នែកជាមួយរបស់អង្គការសិទ្ធិមនុស្សជាតិ ឬអន្តរជាតិតាមផ្លូវការ ឬអាចធ្វើការនៅតាមសហគមន៍មូលដ្ឋានរបស់ខ្លួន។ ជារឿយៗពួកគេគឺជាបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាល អ្នកដឹកនាំសហជីពកម្មករ មេដឹកនាំសហគមន៍ អ្នកសារព័ត៌មាន គ្រូបង្រៀន ឬសិស្សនិស្សិត ប៉ុន្តែ អាចជានរណាក៏បានដែរ ដោយមិនគិតដល់វិជ្ជាជីវៈជាប្រចាំរបស់ពួកគេទេ ។ បច្ចុប្បន្ននេះនៅកម្ពុជា សកម្មជនសិទ្ធិមនុស្ស សកម្មជននៅតាមសហគមន៍មានការកើនឡើង ហើយអង្គការសិទ្ធិមនុស្សនានាបំពេញតួនាទីជាចំបងក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស ។

ក្នុងការកំណត់ថា តើករណីមួយអាចជាអំពើគំរាមកំហែងដល់អ្នកការពារសិទ្ធិមនុស្សម្នាក់ ឬយ៉ាងណានោះ អង្គការលីកាដូយល់ឃើញថា ជាការសំខាន់ត្រូវកំណត់ថា តើជនរងគ្រោះបានធ្វើសកម្មភាពដែលការពារ ឬលើកស្ទួយសិទ្ធិមនុស្សដូចដែលមានចែងនៅក្នុងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងត្រូវបានធានាដោយច្បាប់អន្តរជាតិនានា ដូចជាកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយដែរឬទេ? សកម្មភាពដូចពោលខាងលើនេះត្រូវធ្វើឡើងទាំងស្រុង ឬមួយផ្នែកតំណាងឱ្យអ្នកដទៃ ហើយត្រូវបង្ហាញឱ្យឃើញនូវទំនាក់ទំនងជាមូលហេតុច្បាស់លាស់រវាងសកម្មភាពដែលបានអនុវត្ត ដើម្បីការពារសិទ្ធិមនុស្ស ហើយដែលបានទទួលរងពីការគំរាមកំហែង ការយាយី ឬការបំភិតបំភ័យ ។

សូមកត់សម្គាល់ថា អ្នកនយោបាយអាចធ្វើសកម្មភាពជាអ្នកការពារសិទ្ធិមនុស្ស ដូចអ្នកដទៃទៀត អាជ្ញាធរគ្រប់គ្រងប្រទេសដែលមានអ្នកធ្វើរបាយការណ៍សិទ្ធិមនុស្សមិនល្អ ដូចជាប្រទេសកម្ពុជាជាដើម តែងតែព្យាយាមបង្ខូចឈ្មោះអង្គការសិទ្ធិមនុស្សអព្យាក្រិត្យ ដោយភ្ជាប់អង្គការសិទ្ធិមនុស្សទាំងនោះទៅនឹងគណបក្សនយោបាយជំទាស់ ។ ដើម្បីចៀសវាងការចោទប្រកាន់ពីភាពលំអៀងទៅរកគណបក្សនយោបាយ និងចង់បង្ហាញពីកិច្ចការពារផ្សេង ។ ការគំរាមកំហែង ឬការវាយប្រហារចំពោះអ្នកនយោបាយអាចទទួលបានក្រោមការពារនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ ហេតុនេះ ការគំរាមកំហែងដែលអ្នកនយោបាយជាតិបានទទួលមិនបញ្ចូលនៅក្នុងរបាយការណ៍សង្ខេបនេះទេ ។

## កិច្ចការពារស្របច្បាប់ចំពោះអ្នកការពារសិទ្ធិមនុស្ស

នៅកម្ពុជា កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ បានផ្ដល់ជាមូលដ្ឋានច្បាប់សំរាប់ការពារអ្នកការពារសិទ្ធិមនុស្ស ដូចជាការទទួលស្គាល់សិទ្ធិសេរីភាពក្នុងការបង្កើតសមាគម ការជួបប្រមូលផ្ដុំ និងការបញ្ចេញមតិជាដើម ។ នៅឆ្នាំ១៩៩២ រដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខា និងផ្ដល់សច្ចាប័នទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធ មានដូចជាកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។ បទបញ្ញត្តិនៃកតិកាសញ្ញាទាំងពីរ និងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សទាំងនេះ ត្រូវ

បានបញ្ចូលនៅក្នុងច្បាប់ជាតិនៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ។

នៅឆ្នាំ១៩៩៨ នៅក្នុងឱកាសខួបលើកទី៥០នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តទទួលយកជាឯកឆន្ទនូវសេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងស្ថាប័នសង្គមដើម្បីលើកស្ទួយនិងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន[១] ដែលមានការទទួលស្គាល់ជាសកល ។ សេចក្តីប្រកាសនេះបានក្លាយជា " សេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស " ។

សេចក្តីប្រកាសមានចែងអំពីសិទ្ធិ និងកិច្ចការពារចំពោះអ្នកការពារសិទ្ធិមនុស្ស ដែលត្រូវតែគាំទ្រដោយប្រទេសជាសមាជិក ដូចជា សិទ្ធិស្វែងរកព័ត៌មាន ទទួល និងរក្សាទុកព័ត៌មានទាក់ទងនឹងសិទ្ធិមនុស្ស ឬការរិះគន់មិនគោរពបទដ្ឋានសិទ្ធិមនុស្សរបស់រដ្ឋាភិបាលជាដើម ។ តំណាងពិសេសរបស់អគ្គលេខាធិការទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្សបានធ្វើការកត់សម្គាល់ថា សេចក្តីប្រកាសនេះផ្អែកតាមគោលការណ៍ជាកាតព្វកិច្ចផ្លូវច្បាប់ និងជាសិទ្ធិដែលមានកំណត់រួចនៅក្នុងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលមានស្រាប់ ហើយដោយសារ "សេចក្តីប្រកាសនេះត្រូវបានអនុម័តទទួលយកជាឯកឆន្ទដោយមហាសន្និបាតអង្គការសហប្រជាជាតិ.... ដូច្នេះសេចក្តីប្រកាសនេះតំណាងឱ្យការប្តេជ្ញាចិត្តដ៏មុតមាំសំរាប់ប្រទេសនានា ដើម្បីនឹងគោរពអនុវត្តសេចក្តីប្រកាសនេះ[២] "។

[1] អង្គការសហប្រជាជាតិ ឯកសារយោង : A/RES/53/144 ចេញផ្សាយនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ។

[2] សូមមើលឧបសម្ព័ន្ធទី២ : សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីអ្នកការពារសិទ្ធិមនុស្ស

# II. សាវតា

## សិទ្ធិមនុស្សនៅកម្ពុជា

នៅក្នុងសុន្ទរកថាទៅកាន់មហាសន្និបាតអង្គការសហប្រជាតិនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥ លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានមានប្រសាសន៍ថា សិទ្ធិមនុស្សនៅកម្ពុជា "ត្រូវបានគោរពយ៉ាងពេញលេញ" [៣] ។ មានមនុស្សមួយចំនួនតូចតែប៉ុណ្ណោះដែលយល់ស្របជាមួយការវាយតំលៃនេះ ។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស មានជំនឿថាឆ្នាំ២០០៥ បង្ហាញពី "ការធ្លាក់ចុះយ៉ាងខ្លាំង" ដែលកម្ពុជាសំរេចបានកន្លងមកក្នុងការគោរពសិទ្ធិមនុស្ស និងស្ថាបនារបបនយោបាយពហុបក្ស ចាប់តាំងពីការចុះហត្ថលេខាកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានធ្វើការកត់សំគាល់ថា "គណបក្សនយោ-បាយជំទាស់ត្រូវបានបំបែកបំបាកបានដោយជោគជ័យតាមរយៈការចាប់ខ្លួន ឬការគំរាមចាប់ខ្លួនអ្នកតំណាងរាស្ត្រ ។ សកម្មជន និងអ្នកសារព័ត៌មាន ដែលហ៊ាននិយាយអំពីការបន្លំរឹបអូសយកដីរបស់កសិករ ការកាប់ព្រៃឈើខុសច្បាប់ ឬសន្ធិសញ្ញាព្រំដែនប្រកបដោយភាពចំរូងចំរាស់ជាមួយប្រទេសវៀតណាម ត្រូវបានចាប់ខ្លួន វាយធ្វើបាបលើរូបរាងកាយ ឬគំរាមដល់អាយុជីវិត ឬចោទប្រកាន់ និងដាក់ពន្ធនាគារ ដោយចោទពីបទបរិហារកេរ្តិ៍មិនត្រឹមត្រូវ" [៤] ។ អង្គការលើកលែងទោសអន្តរជាតិបានរាយការណ៍ថា ការរិះគន់ដោយសន្តិភាពលើរដ្ឋាភិបាលត្រូវបានចុះថយ ដោយសារអ្នកការពារសិទ្ធិមនុស្ស និងអ្នកនយោបាយរបស់គណបក្សជំទាស់ត្រូវប្រឈមមុខនឹងការគំរាមកំហែង ហើយការរឹតត្បិតលើសេរីភាពក្នុងការជួបជុំគ្នានៅតែបន្ត ។ របាយការណ៍នេះបានផ្តោតទៅលើ "អំពើពុករលួយ និងប្រព័ន្ធតុលាការទន់ខ្សោយរបស់កម្ពុជា" ការរំលោភលើអនុសញ្ញាឆ្នាំ១៩៥១ ស្តីពីជនភៀសខ្លួន និងការផ្តល់ដីសម្បទានដោយរដ្ឋាភិបាល ដែលធ្វើឱ្យប្រជាពលរដ្ឋកម្ពុជានៅតែបន្តការបាត់បង់ដីធ្លី និងរស់នៅក្នុងស្ថានភាពក្រីក្រ [៥] ។



កងប៉ូលីសបង្ក្រាបបាតុកម្មចល័តចុះឡើង
ដើម្បីបំបែកក្រុមបាតុករ ។

ក្រសួងការបរទេសសហរដ្ឋអាមេរិក បានកត់សម្គាល់នៅឆ្នាំ២០០៥ថា ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាកាន់តែអនទៅៗ ។ មានសេចក្តីរាយការណ៍អំពី "ការសំលាប់ក្រៅប្រព័ន្ធតុលាការ និទ្ទណ្ឌភាពចំពោះកងកំលាំងសន្តិសុខ ការរំលោភលើសិទ្ធិអ្នកជាប់ឃុំឃាំង ច្រើនតែមានការបង្ខំឱ្យឆ្លើយសារភាព ស្ថានភាពពន្ធនាគារអាក្រក់ ការចាប់ខ្លួនតាមទំនើងចិត្ត និងការឃុំខ្លួនបណ្តោះអាសន្នលើសពីរយៈពេលកំណត់ដោយច្បាប់ប្រព័ន្ធតុលាការទន់ខ្សោយ និងការបដិសេធសិទ្ធិទទួលបានការជំនុំជំរះដោយយុត្តិធម៌ រដ្ឋាភិបាលត្រួតត្រាឬមានឥទ្ធិពលលើខ្លឹមសារដែលផ្សព្វផ្សាយតាមទូរទស្សន៍ និងវិទ្យុ រដ្ឋាភិបាលធ្វើជ្រៀតជ្រែកលើសេរីភាពក្នុងការប្រមូលផ្តុំ អំពើ

---

[៣] សុន្ទរកថារបស់សម្តេច**ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា នៅឯមហាសន្និបាតរបស់អង្គការសហប្រជាជាតិនាទីក្រុង NewYork នៅថ្ងៃទី១៥ ខែសីហា ២០០៥ ។

[៤] របាយការណ៍ពិភពលោករបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សឆ្នាំ២០០៥ HRW, New York ចេញផ្សាយថ្ងៃខែមករា ឆ្នាំ២០០៦ ។

[៥] របាយការណ៍របស់ Amnesty International ឆ្នាំ២០០៦ ចុះផ្សាយនៅថ្ងៃទី ២៤ ខែឧសភា ។

ហិង្សាក្នុងគ្រួសារ និងការរើសអើងចំពោះស្ត្រីនៅកន្លែងធ្វើការ ការរំលោភបំពានលើកុមារ ការជួញដូរស្ត្រីនិងកុមារ វិវាទដីធ្លី និងកង្វះខាតដំណោះស្រាយត្រឹមត្រូវ សកម្មភាពប្រឆាំងនឹងសហជីពកម្មករដោយនិយោជក និងការមិនអនុវត្តច្បាប់ការងារ និងពលកម្មកុមារ "[៦] ។

ដប់ប្រាំឆ្នាំក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា ប្រទេសនៅតែរងគ្រោះដោយការរំលោភបំពានសិទ្ធិមនុស្ស ហើយបរិយាកាសសំរាប់អ្នកដែលស្វែងរកវិធានការដើម្បីដោះស្រាយបញ្ហាទាំងអស់នោះនៅតែជួបការលំបាក និងគ្រោះថ្នាក់ ។

## ការបង្ក្រាបលើសង្គមស៊ីវិល

ចាប់ពីឆ្នាំ២០០៦ សង្គមស៊ីវិលរបស់កម្ពុជាជួបភាពច្របូកច្របល់ ។ អ្នកការពារសិទ្ធិមនុស្សដ៏សំខាន់របស់ប្រទេសចំនួនពីរនាក់ គឺលោក កឹម សុខា ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងលោក យេង វីរៈ ប្រធានមជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារនៅល្ងាចឆ្លងថ្ងៃបុណ្យចូលឆ្នាំសកល ឆ្នាំ២០០៥ ដោយទទួលការចោទប្រកាន់ពីបទបរិហារកេរ្តិ៍រដ្ឋាភិបាល ។ ប៉ុន្មានថ្ងៃក្រោយមក លោក ប៉ា ងួនទៀង (ក៏ជាបុគ្គលិករបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា) ត្រូវបានចាប់ខ្លួន ហើយដាក់ឃុំក្នុងពន្ធនាគារផងដែរ ។ នៅក្នុងពន្ធនាគារព្រៃសអ្នកទាំងអស់គ្នានេះបានចូលរួមជាមួយអ្នកសារព័ត៌មានដ៏សំខាន់មួយរូប គឺលោក ម៉ម សូណង់ដូ និងលោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា ។ ពួកអ្នកទាំងពីរនាក់នេះត្រូវបានចាប់ខ្លួននៅខែតុលា ឆ្នាំ២០០៥ ក្រោមការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងបទចោទប្រកាន់បទល្មើសពាក់ព័ន្ធផ្សេងៗទៀត ។ មានមេដឹកនាំសង្គមស៊ីវិលខ្លះបានរត់ចាកចេញពីប្រទេសដោយភ័យខ្លាចពីការចាប់ខ្លួន ។ មេដឹកនាំគណបក្សជំទាស់លោក សម រង្ស៊ី និរទេសនៅក្រៅប្រទេស បន្ទាប់ពីអភ័យឯកសិទ្ធិរដ្ឋសភារបស់លោកត្រូវបានដកហូតនៅខែកុម្ភៈ ឆ្នាំ២០០៥ ហើយក្រោយមកលោកត្រូវបានតុលាការផ្តន្ទាទោសឱ្យជាប់ក្នុងពន្ធនាគាររយៈពេល១៨ខែពីបទបរិហារកេរ្តិ៍ ។ ទន្ទឹមនឹងគ្នានោះផងដែរ តំណាងរាស្ត្រគណបក្សជំទាស់ លោក ជាម ចន្នី ត្រូវបានផ្តន្ទាទោសឱ្យជាប់ក្នុងពន្ធនាគារយោធារយៈពេល៧ឆ្នាំពីបទបង្កើតកងទ័ពខុសច្បាប់ ។ ការចាប់ខ្លួន ការចោទប្រកាន់ ឬផ្តន្ទាទោសខាងលើមិនបានធ្វើឡើងតាមនីតិវិធីឡើយ[៧] ។

តែការឃុំខ្លួនសកម្មជនសិទ្ធិមនុស្សមានរយៈពេលខ្លីតែប៉ុណ្ណោះ ដោយសារមានអន្តរាគមន៍ខ្លាំងឡើងៗពីសហគមន៍ជាតិនិងអន្តរជាតិ ។ នៅថ្ងៃទី១១ ខែមករា លោក យេង វីរៈ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ហើយប្រាំមួយថ្ងៃក្រោយមកលោក កឹម សុខា លោក ប៉ា ងួនទៀង លោក ម៉ម សូណង់ដូ និងលោក រ៉ុង ឈុន ក៏ត្រូវបានដោះលែងឱ្យមានសេរីភាពឡើងវិញ ។ តែការដោះលែងនេះមានការភ្ជាប់ជាមួយលក្ខខណ្ឌបាននៅក្រៅបណ្តោះអាសន្នដោយមានការធានាដោយលោកនាយករដ្ឋមន្ត្រីផ្ទាល់ ដោយចាត់ទុកដូចជា "កាដូ" ចំពោះដំណើរទស្សនះកិច្ចរបស់មន្ត្រីជាន់ខ្ពស់របស់សហរដ្ឋអាមេរិកក្នុងឱកាសសម្ពោធស្ថានទូតថ្មី ។ លោកនាយករដ្ឋមន្ត្រីប្រកាសជាច្រើនដង នៅចំពោះមុខសាធារណជនថា សកម្មជនណាម្នាក់ដែលប្រព្រឹត្តទង្វើ "យ៉ាងក្រអឺតក្រទម" អាចត្រូវចាប់ខ្លួន

[6] របាយការណ៍ប្រចាំប្រទេសស្តីពីការអនុវត្តន៍សិទ្ធិមនុស្សឆ្នាំ២០០៥ :ការិយាលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស និងពលកម្ម ។ចុះផ្សាយនៅថ្ងៃទី៨ ខែមីនា ឆ្នាំ ២០០៦

[7] សំរាប់ព័ត៌មានសំអិតអំពីការត្រួតពិនិត្យការបង្ក្រាប សូមមើលរបាយការណ៍របស់លីកាដូ :ការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា

ឡើងវិញ ។ នៅពេលសរសេររបាយការណ៍នេះ ការចោទប្រកាន់ទៅលើសកម្មជនសិទ្ធិមនុស្សខាងលើមិនទាន់បញ្ចប់នៅឡើយទេ ។ ផ្នែកលើកត្តាផ្លូវច្បាប់សកម្មជនសិទ្ធិមនុស្សទាំងនោះមិនត្រូវទទួលការជំនុំជម្រះបានឡើយ[8] តែពួកគេនៅតែទទួលការគំរាមកំហែងដដែល ។ មធ្យោបាយប្រហាក់ប្រហែលគ្នានេះត្រូវបានប្រើទៅលើអ្នកការពារសិទ្ធិមនុស្សជាច្រើនទូទាំងប្រទេសកម្ពុជានៅខែបន្តបន្ទាប់ ។

ប៉ុន្មានខែក្រោយមកលោក ជាម ចន្នី និងលោក សម រង្ស៊ី ត្រូវបានលើកលែងទោស ។ លោក ជាម ចន្នី ត្រូវបានដោះលែងឱ្យមានសេរីភាពឡើងវិញពីពន្ធនាគារ ហើយលោក សម រង្ស៊ី វិលត្រលប់ចូលក្នុងប្រទេស ។ ចំពោះអ្នកសង្កេតការមួយចំនួនយល់ឃើញថា ព្រឹត្តិការណ៍ឆ្នាំ២០០៦ជាភស្តុតាងបញ្ជាក់ពីវិធីទន់ភ្លន់របស់រដ្ឋាភិបាលចំពោះអ្នកជំទាស និងការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះសិទ្ធិមនុស្ស ។ ទោះជាយ៉ាងក៏ដោយ នៅតែមានអ្នកមានទស្សនៈផ្ទុយមួយចំនួនសន្និដ្ឋានថា ការដោះលែងអ្នកការពារសិទ្ធិមនុស្ស និងការផ្សះផ្សាជាមួយគណបក្សជំទាស់អាចជាប់ទាក់ទងជាមួយកិច្ចប្រជុំរវាងរដ្ឋាភិបាល និងសហគមន៍ផ្ដល់ជំនួយអន្តរជាតិដែលខិតជិតមកដល់នោះវិញទេ[9] ។

## សហគមន៍អន្តរជាតិ

មានសហគមន៍អន្តរជាតិជាច្រើនជំទាស់នឹងការចាប់ខ្លួនលោក កឹម សុខា លោក យ៉េង វីរៈ និង ប៉ា ងួនទៀងតែការរិះគន់ភាគច្រើនបញ្ឈប់ទៅវិញយ៉ាងឆាប់រហ័ស ជាមួយនឹងការដោះលែងពួកអ្នកទាំងអស់នោះដោយមានលក្ខខណ្ឌ ។ អង្គការសិទ្ធិមនុស្សអន្តរជាតិ ដូចជា អង្គការលើកលែងទោសអន្តរជាតិ និងអង្គការឃ្លាំមើលសិទ្ធិមនុស្ស បន្តថ្កោលទោសដល់រដ្ឋាភិបាលដោយការមិនបានគោរពសិទ្ធិមនុស្សឱ្យបានជោគជ័យ និងការវាយប្រហារលើអ្នកការពារសិទ្ធិមនុស្ស ប៉ុន្តែ សហគមន៍ម្ចាស់អ្នកផ្ដល់ជំនួយអន្តរជាតិដែលមានឥទ្ធិពលបែរជានៅស្ងៀមទៅវិញ ។ នៅពេលរដ្ឋាភិបាលជួបប្រជុំជា មួយតំណាងប្រទេសផ្ដល់ជំនួយនៅឯកិច្ចប្រជុំពិគ្រោះយោបល់ថ្ងៃទី ២-៣ ខែមីនា បញ្ហាសិទ្ធិមនុស្សមិនត្រូវបានលើក យកមកពិភាក្សាឡើយ នេះបើតាមប្រសាសន៍របស់លោករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គាត ឈុន និងជាសហប្រធាននៃអង្គប្រជុំ[10] ។ នៅឯកិច្ចប្រជុំនេះ ប្រទេសអ្នកផ្ដល់ជំនួយបានបង្កើនប្រាក់ជំនួយរបស់គេពី ៥០៤ លាន ដុល្លារ នៅខែធ្នូ ឆ្នាំ២០០៤ ទៅ ៦០១ លានដុល្លារវិញ ។ លោក Joseph Mussomeli ឯកអគ្គរដ្ឋទូត របស់សហរដ្ឋអាមេរិក បានពិពណ៌នាវិធានការរបស់លោកនាយករដ្ឋមន្ត្រីនាពេលថ្មីៗនៃការដោះលែងអ្នកការពារសិទ្ធិមនុស្សដែលជាប់ឃុំក្នុងពន្ធនាគារដោយមិនបានប្រព្រឹត្តអ្វីខុសថាជា "ថាមភាពដ៏អស្ចារ្យ និងពោរពេញដោយសេចក្ដីក្លាហាន "[11] ។

[8] ក្រោមក្រមព្រហ្មទណ្ឌកម្ពុជា ជនជាប់ចោទត្រូវតែនាំមកសវនាការក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីចាប់ខ្លួន ទោះបីជាពួកគេស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន ឬមិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នក៏ដោយ ។

[9] អត្ថបទរបស់លោក Guy de Launey ចំណងជើងថា "លើកលែងទោស រង្សីដែលកំពុងនិរទេស ព័ត៌មានរបស់ BBC, February 05 2005

[10] អត្ថបទរបស់ Erik Wasson & Kay Kimsong ក្រោមចំណងជើងថា ប្រទេសផ្ដល់ជំនួយសន្យាផ្ដល់ជំនួយនូវចំនួនទឹកប្រាក់ $601នៅឯកិច្ចប្រជុំពិគ្រោះយោបល់ ។ ព្រឹត្តិបត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយថ្ងៃទី ៤-៥ ខែមីនា ឆ្នាំ ២០០៦ ។

[11] អត្ថបទរបស់ Erik Wasson & Kay Kimsong ក្រោមចំណងជើងថាប្រទេសផ្ដល់ជំនួយយល់ឃើញថា ច្បាប់ប្រឆាំងនឹងអំពើពុករលួយជាការសាកល្បងរបស់រដ្ឋាភិបាល ។ ព្រឹត្តិបត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយថ្ងៃទី ៦ ខែមីនា ឆ្នាំ ២០០៦ ។

អាជ្ញាធរកម្ពុជាតែងតែមិនយកទុកដាក់ចំពោះបុគ្គលនៅសហគមន៍អន្តរជាតិ ដែលតែងតែចោទសួរពីរបាយការណ៍សិទ្ធិមនុស្សរបស់កម្ពុជា ក្នុងនោះមន្ត្រីរដ្ឋាភិបាលបានព្រឹត្តកម្មជាច្រើនដងនៅចំពោះមុខសាធារណជនលើអ្នកការពារសិទ្ធិមនុស្សអន្តរជាតិ ។ នៅខែមីនា តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលទើបតែតែងតាំងថ្មីគឺលោកសាស្ត្រាចារ្យ Yash Ghai បានរិះគន់អំពីការក្តោបក្តាប់អំណាច និងការមិនរីកចំរើនខាងវិស័យសិទ្ធិមនុស្សនៅកម្ពុជា ។ ជាការឆ្លើយតប លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា លោកសាស្ត្រចារ្យ ជា "មនុស្សជំលើយ " និងជា" អ្នកទេសចរណ៍រយៈពេលយូរអង្វែង "ដែល" មកដោយមិនចេះដឹងអ្វីទាល់តែសោះ" [១២] ។ លោកនាយករដ្ឋមន្ត្រីមិនព្រមជួបជាមួយលោក Ghai ក្នុងដំណើរទស្សនៈកិច្ចរបស់លោកចំនួនពីរដងមកកម្ពុជា លោកបានថ្លែងថា លោកនឹងមិនជួបជាមួយបេសកជនរបស់អង្គការសហប្រជាជាតិរូបនោះទេ ហើយថែមទាំងបានអំពាវនាវទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិលោក Kofi Annan ដកដំណែង លោក Ghai ចេញទៀតផង ។ លោករដ្ឋមន្ត្រីក្រសួងព័ត៌មាន ខៀវ កញ្ញារិទ្ធ បានបន្ថែមថា លោក Ghai ទទួលព័ត៌មានមិនត្រឹមត្រូវពីបុគ្គលិករបស់លោកដែលបំរើការងារនៅការិយាល័យសិទ្ធិមនុស្សរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ហើយបានហៅពួកអ្នកថា "ជាបុគ្គលិកកំជិលបំផុតដែលអង្គការសហប្រជាជាតិមាន " [១៣] ។

## ឧបសគ្គផ្នែកនីតិក្រម

នៅមុនកិច្ចប្រជុំក្រុមពិគ្រោះយោបល់ លោកនាយករដ្ឋមន្ត្រីបានបង្ហាញពីចេតនារបស់លោកចំពោះការដកបទល្មើសព្រហ្មទណ្ឌពីបទបរិហារកេរ្តិ៍ [១៤] ហើយនៅថ្ងៃទី២៦ ខែឧសភា រដ្ឋសភាអនុម័តច្បាប់វិសោធនកម្មក្រមព្រហ្មទណ្ឌ ដោយដកទោសពន្ធនាគារចេញពីបទបរិហារកេរ្តិ៍ ។ ប៉ុន្តែ បរិហារកេរ្តិ៍មិនទាន់ដកចេញពីបទព្រហ្មទណ្ឌទាំងស្រុងទេ នៅតែជាបទល្មើសព្រហ្មទណ្ឌដដែល ដែលតម្រូវឱ្យចាប់ខ្លួនជនសង្ស័យ និងបង់ពិន័យជាប្រាក់ចំនួនដប់លានរៀល (២.៥០០ដុល្លារ) ជាចំនួនមួយដែលប្រជាពលរដ្ឋកម្ពុជាភាគច្រើនពុំមានលទ្ធភាពបង់ ហើយអាចប្រឈមមុខនឹងការជាប់ឃុំក្នុងពន្ធនាគារដោយសារតែប្រាក់ពិន័យនេះ ។ បទចោទប្រកាន់បរិហារកេរ្តិ៍នៅតែបន្តអនុវត្តទៅលើលោក Julio Jeldres អ្នកនិពន្ធជីវប្រវត្តិរបស់ក្រុមព្រះរាជវង្សានុវង្ស ។ នៅខែកញ្ញា លោក Jeldres ត្រូវបានពិន័យជាប្រាក់ចំនួនប្រាំបីលានរៀល (២.០០០ដុល្លារ) បូកជាមួយសំណងជំងឺចិត្តចំនួនដប់លានរៀលក្នុងបទចោទប្រកាន់ថាបានបរិហារកេរ្តិ៍លោកនាយរដ្ឋមន្ត្រី ។ នៅមានភស្តុតាងបង្ហាញពីការចោទប្រកាន់ក្នុងបទផ្សព្វផ្សាយព័ត៌មានមិនពិតដែលអាចផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់បីករណី ដែលជាទោសព្រហ្មទណ្ឌមួយជំនួសបទបរិហារកេរ្តិ៍ធ្វើជាមធ្យោបាយសំរាប់ឃុំឃាំងអ្នកទិតៀន ។ ឧទាហរណ៍ លោក ទៀង ណារីទ្ធ ជាសាស្ត្រាចារ្យសកលវិទ្យាល័យមួយត្រូវបានចាប់ខ្លួននៅថ្ងៃទី៤ ខែកញ្ញា ក្រោមការចោទប្រកាន់ពីបទផ្សព្វផ្សាយព័ត៌មានមិនពិត ដោយសារគាត់សរសេរសៀវភៅដែលបានរិះគន់នយោបាយរបស់រដ្ឋាភិបាល បច្ចុប្បន្ននេះកំពុងជាប់ឃុំនៅពន្ធនាគារព្រៃសរង់ចាំតុលាការបើក

---

[12] អត្ថបទរបស់ Erik Wasson & Chhim Sopheak ក្រោមចំណងជើងថា "លោកនាយករដ្ឋមន្ត្រីនិយាយថា បេសកជនពិសេសរបស់អង្គការសហប្រជាជាតិត្រូវដកចេញ ។ ព្រឹត្តិបត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០០៦ ។

[13] អត្ថបទរបស់ Erik Wasson ក្រោមចំណងជើងថាលោក Annan គាំទ្របេសកជនសិទ្ធិមនុស្ស ។ ព្រឹត្តិបត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយថ្ងៃទី ១-២ ខែមេសា ឆ្នាំ ២០០៦ ។

[14] អត្ថបទរបស់លោក Yun Samean :លោកហ៊ុន សែន ការបរិហារកេរ្តិ៍មិនមែនជាបទល្មើសព្រហ្មទណ្ឌ ។ ព្រឹត្តិបត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០៦ ។

សវនាការ ។

មានការគំរាមកំហែងមួយទៀតដែលសំដៅលើទៅអ្នកការពារសិទ្ធិមនុស្សនាពេលបច្ចុប្បន្ន ដែលបង្កឡើងដោយការពង្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (ឬច្បាប់ NGO) ដែលស្នើដោយរដ្ឋាភិបាល ។

ពង្រាងច្បាប់ចុងក្រោយ រួមមាននីតិវិធីចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាល ដែលចែងមិនច្បាស់លាស់ និងសាំញ៉ាំ រួមមានការផ្តន្ទាទោសចំពោះអង្គការមិនមែនរដ្ឋាភិបាលដែលមិនបានចុះបញ្ជី និងតម្រូវឱ្យអង្គការមិនមែនរដ្ឋាភិបាលជូនដំណឹងទៅអាជ្ញាធរមូលដ្ឋានអំពីសកម្មភាពរបស់ខ្លួន ហើយផ្តល់លទ្ធភាពឱ្យរដ្ឋាភិបាលត្រួតពិនិត្យតាមដានសកម្មភាពកម្មវិធីរបស់អង្គការមិនមែនរដ្ឋាភិបាលសំរាប់ "ផលប្រយោជន៍នយោបាយ" ដែលមានភាពមិនច្បាស់លាស់ ។ បទបញ្ញត្តិទាំងនេះផ្ទុយទៅនិងអនុសាសន៍របស់តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្ស ដែលបានសំដែងការព្រួយបារម្ភថា រដ្ឋាភិបាលកំពុងតែពន្លឿនការប្រើប្រាស់ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលនេះ ដើម្បីដាក់រឹតបន្តឹងសកម្មភាពរបស់អង្គការសិទ្ធិមនុស្ស[១៥] ។

[15] Hin Jilani របាយការណ៍របស់តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្ស ចុះថ្ងៃទី១ ខែ តុលា ឆ្នាំ ២០០៤ ។ A/59/401, p2

# III. ការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្ស ពីខែមករា ដល់ ខែតុលា ឆ្នាំ២០០៦

## ជនរងគ្រោះ និងជនល្មើស

ក្នុងអំឡុងពេលដប់ខែនៃឆ្នាំ២០០៦ មានអ្នកការពារសិទ្ធិមនុស្សជាច្រើននាក់ទទួលរងគ្រោះដោយការគំរាមកំហែង និងវាយប្រហារ ។ បុគ្គលិករបស់អង្គការសិទ្ធិមនុស្សក្នុងស្រុកជាច្រើននាក់បន្តប្រឈមមុខជាមួយនឹងការគំរាមកំហែង និងការបំភិតបំភ័យនៅពេលបំពេញការងារប្រចាំថ្ងៃរបស់ពួកគេ ព្រមទាំងមានការរាំងស្ទះដែលមានលក្ខណៈជាប្រព័ន្ធដល់កិច្ចប្រឹងប្រែងរបស់ពួកគេ ដើម្បីតាមដានករណីធ្ងន់ធ្ងរ ដូចជា ការបណ្តេញចេញពីលំនៅដ្ឋាន ការធ្វើបាតុកម្ម និងកូដកម្មផ្សេងៗ ដែលបានប្រើប្រាស់កងកំលាំងហួសប្រមាណ ហើយក្នុងនោះក៏មានអ្នកប្តឹងតវ៉ាខ្លះទទួលរងរបួស និងត្រូវបានចាប់ខ្លួន ។ ប្រជាពលរដ្ឋដែលព្យាយាមការពារសិទ្ធិរបស់អ្នកដទៃ ដូចជា អ្នកស្រុកជួយដល់ជនស្វែងរកសិទ្ធិជ្រកកោនបានក្លាយជាគោលដៅនៃការគំរាមកំហែង និងបំភិតបំភ័យ ។ ជនរងគ្រោះដោយសារអំពើវាយប្រហារធ្ងន់ធ្ងរជាច្រើន ដូចជា ការគំរាមសំលាប់ ការវាយធ្វើបាបលើរូបរាងកាយ ការចាប់ខ្លួន និងការចាប់ដាក់ពន្ធនាគារ ភាគច្រើនជាសកម្មជននៅតាមសហគមន៍ និងជាតំណាងរបស់ក្រុមដែលជាប់ពាក់ព័ន្ធក្នុងវិវាទដីធ្លី និងធនធានធម្មជាតិ ។ តំណាងសហជីពកម្មករ ដែលចូលរួមយ៉ាងសកម្មក្នុងវិវាទការងារក៏ជាជនរងគ្រោះនៃការវាយប្រហារយ៉ាងធ្ងន់ធ្ងរ និងជាញឹកញាប់ដែលត្រូវបានរាយការនៅក្នុងឆ្នាំនេះ ។ អ្នកសារព័ត៌មានដែលប្រមូលព័ត៌មានពីបញ្ហាសិទ្ធិមនុស្សក៏ជាជនរងគ្រោះនៃការគំរាមកំហែង និងគេវាយធ្វើបាបនៅក្នុងករណីជាច្រើន ។

ជនល្មើសដែលប្រព្រឹត្តអំពើគំរាមកំហែង និងវាយប្រហារលើអ្នកការពារសិទ្ធិមនុស្សទាំងអស់នេះ មានសមាសភាពផ្សេងៗគ្នា ។ មន្ត្រីនគរបាល យោធា និងកងរាជអាវុធហត្ថពាក់ព័ន្ធក្នុងរឿងគំរាមកំហែង ការវាយធ្វើបាប និងការចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្ស ក្នុងនោះក៏មានមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ និងមូលដ្ឋានពាក់ព័ន្ធក្នុងករណីខាងលើដែរ ។ ករណីញដែលជាប់ពាក់ព័ន្ធនឹងការចាប់ខ្លួន និងការឃុំខ្លួនអ្នកការពារសិទ្ធិដោយខុសច្បាប់ ច្រើនតែពាក់ព័ន្ធជាមួយជនល្មើសច្រើននាក់ រួម : មានជនដាក់ពាក្យបណ្តឹងដោយគ្មានភស្តុតាង កងកំលាំងប្រដាប់អាវុធ ដែលជាអ្នកអនុវត្តការចាប់ខ្លួន និងមន្ត្រីតុលាការ ដែលមានតួនាទីចោទប្រកាន់ ជំនុំជម្រះ និងផ្តន្ទាទោសដាក់ពន្ធនាគារជនរងគ្រោះ ។ ក្នុងកិច្ចការពារសិទ្ធិមនុស្សជារឿយៗ សកម្មជនសិទ្ធិមនុស្សវិវាទជាមួយអ្នកមានអំណាចខ្មែរ និងអ្នកជំនួញបរទេសដែលមានទំនាក់ទំនងជិតស្និទជាមួយអាជ្ញាធរ ហើយជាញឹកញាប់ជាអ្នកញុះញង់ឱ្យមានបណ្តឹងទៅតុលាការដោយគំនិតព្យាបាទ ហើយជួនកាលពួកគេជាអ្នកគាំទ្រអំពើហិង្សាទៀតផង ។

## អង្គការសិទ្ធិមនុស្សមិនមែនរដ្ឋាភិបាល

គួរឱ្យចាប់អារម្មណ៏ដែរថា ការគំរាមកំហែងចំពោះអ្នកបំរើការងារផ្នែកសិទ្ធិមនុស្ស ភាគច្រើនកើតនៅក្នុងបរិបទនៃករណីដែលសំបូរដោយរឿងចំរូងចំរាស់ ជាពិសេសរឿងវិវាទដីធ្លី ដែលពួកគេព្យាយាមឃ្លាំមើល ។ កាលពីខែឧសភា អ្នកឃ្លាំមើលករណីរបស់អង្គការអាដហុក លីកាដូ និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវបានឃុំខ្លួននិងគំរាមដោយកាណុងកាំភ្លើងពីកងរាជអាវុធហត្ថនៅខេត្តកំពត ក្នុងខណៈពេលពួកគេឃ្លាំមើលរឿងវិវាទដីធ្លីនៅទីនោះ ។

មួយខែក្រោយមកសកម្មជនរបស់អង្គការអាដហុកត្រូវបានដាក់ខ្នោះ ហើយហ្វីលម៉ាស៊ីនថតរបស់គាត់ត្រូវបានបំផ្លាញចោល នៅពេលកំពុងស៊ើបអង្កេតវិវាទដីធ្លីនៅខេត្តកោះកុង ។ ទន្ទឹមគ្នានេះដែរ សកម្មជនរបស់អង្គការអាដហុកនៅខេត្តសៀមរាប និងរតនគីរីត្រូវបានគំរាមកំហែងជាច្រើនដងពីសំណាក់មន្ត្រីថ្នាក់ស្រុក និងខេត្ត ។ ករណីធ្ងន់ធ្ងរដែលបានកត់ត្រាក្នុងឆ្នាំ២០០៦នេះ អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សពីរនាក់របស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវបានគំរាមនិងចុងកាណុង រីឯម្នាក់ទៀតត្រូវបានគេធាក់ចំពោះទឹកយ៉ាងដំណំដោយក្រុមជនប្រដាប់អាវុធអនាមឹកនៅពេលពួកគេតាមដានវិវាទដីធ្លីនៅខេត្តមណ្ឌលគីរី ។

ការបដិសេធដែលរៀបជាបន្តបន្ទាប់ចំពោះអ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ដើម្បីតាមដានករណីមួយចំនួនដែលមានការព្រួយបារម្ភណ៍ ជាពិសេស ដូចជាករណីបណ្តេញអ្នកស្រុកចេញពីផ្ទះសំបែង និងបាតុកម្ម ។ កាលពីខែកក្កដា អ្នកឃ្លាំមើលការំលោភរបស់អង្គការសិទ្ធិមនុស្សក្នុងស្រុក និងអង្គការសហប្រជាជាតិត្រូវបានបដិសេធមិនឱ្យចូលទៅក្នុងភូមិសំបុកចាបនៅទីក្រុងភ្នំពេញ ក្នុងអំឡុងពេលអាជ្ញាធរប្រតិបត្តិការបណ្តេញអ្នកស្រុកចេញពីផ្ទះសំបែងដោយអំពើហិង្សា ដែលក្នុងព្រឹត្តិការណ៍នោះ អ្នកស្រុកចំនួនប្រាំបីនាក់ត្រូវបានចាប់ខ្លួន ។ មួយខែក្រោយមកសកម្មជនសិទ្ធិមនុស្សត្រូវបានហាមឃាត់មិនឱ្យឃ្លាំមើលការបណ្តេញអ្នកស្រុកនៅសហគមន៍មុន្នីវង្ស A-B ស្ថិតនៅទីក្រុងភ្នំពេញ ហើយអ្នកស៊ើបអង្កេតរបស់អង្គការលីកាដូ ត្រូវបានហាមឃាត់មិនឱ្យថតរូបភាព និងប្រមូលព័ត៌មាននៅទីតាំងថ្មីឡើយ។ នៅខែកញ្ញា អ្នកឃ្លាំមើលសិទ្ធិមនុស្សមិនបានអនុញ្ញាតឱ្យចូលទៅឃ្លាំមើលការប្រឈមមុខដាក់គ្នាយ៉ាងតឹងតែងក្នុងរឿងវិវាទដីធ្លីនៅស្រុកស្រែអំបិល ខេត្តកោះកុង ដែលត្រូវបានគេមើលឃើញថា មានមនុស្សជាច្រើនត្រូវបានចាប់ខ្លួន វាយដំ និងបាញ់ទៅលើអ្នកតវ៉ាម្នាក់ ។

សកម្មជនរបស់អង្គការមិនមែនរដ្ឋាភិបាល បានក្លាយជាគោលដៅដោយសារពួកគេធ្វើសកម្មភាពលើកស្ទួយសិទ្ធិមនុស្ស និងប្រឆាំងអំពើពុករលួយ ។ នៅខែមករា សកម្មជនរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាត្រូវបានឃុំខ្លួនក្នុងរយៈពេលខ្លី ហើយសម្ភារៈរបស់ពួកគេត្រូវបានរឹបអូសនៅពេលពួកគេប្រជាមូលហត្ថលេខាសំរាប់គាំទ្រញត្តិ ដើម្បីដោះលែងលោក កឹម សុខា នាយកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងសហការីអ្នកការពារសិទ្ធិមនុស្សរបស់លោក ។ នៅខែកញ្ញា រថយន្តមួយគ្រឿងដឹក "ប្រអប់ខ្មៅ" នៃយុទ្ធនាការប្រឆាំងអំពើពុករលួយរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាត្រូវបានរឹបអូស និងបង្ខាំងទុកដោយនគរបាល ។ នៅខែ តុលា បុគ្គលិករបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីការអភិវឌ្ឍនិងសន្តិភាពកំពុងដើរចែកផ្ទាំងក្រដាសដែលមានខ្លឹមសារថា "បាតដៃស្អាត" ប្រឆាំងអំពើពុករលួយត្រូវបានឃាត់ខ្លួនក្នុងឧបទ្ទវហេតុបីកន្លែងផ្សេងៗគ្នានៅទីក្រុងភ្នំពេញ ។

## អ្នកជួយជនភៀសខ្លួន

ពេញមួយឆ្នាំ២០០៦ សមាជិកកុលសម្ព័ន្ធព្រៃភ្នំម៉ុងតាញ៉ាមកពីតំបន់ខ្ពង់រាបភាគកណ្តាលនៃប្រទេសវៀតណាមបានបន្តឆ្លងចូលកម្ពុជាដើម្បីស្វែងរកសុំសិទ្ធិជ្រកកោននយោបាយ និងរត់គេចពីអំពើការធ្វើទុក្ខបុកម្នេញខាងសាសនា ។ មានសេចក្តីរាយការណ៍ដែលគួរឱ្យទុកចិត្តបានថា អាជ្ញាធរកម្ពុជាបានចាប់ និងបញ្ជូនអ្នកស្វែងរកសិទ្ធិជ្រកកោនខាងនយោបាយម៉ុងតាញ៉ាក្នុងចំនួនយ៉ាងច្រើនទៅកាន់ប្រទេសវៀតណាមវិញ ដែលនៅទីនោះ ពួកគេអាចនឹងប្រឈមមុខទៅនឹងការឃុំខ្លួនក្នុងពន្ធនាគារ និងធ្វើទារុណកម្ម ។ ទង្វើរបស់អាជ្ញាធរកម្ពុជាគឺមិនគោរពកាតព្វកិច្ច

របស់ខ្លួនក្រោមអនុសញ្ញាឆ្នាំ១៩៥១ ស្តីពីជនភៀសខ្លួន ។ អាជ្ញាធរនៅតែបន្តបំភិតបំភ័យចាប់ខ្លួន និងដាក់ពន្ធនាគារចំពោះអ្នកការពារសិទ្ធិមនុស្សដែលជួយដល់ជនភៀសខ្លួនម៉ុងតាញ៉ា ដែលព្យាយាមទំនាក់ទំនងជាមួយមន្ត្រីឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ។

នៅថ្ងៃទី៩ ខែមករា ជនជាតិភាគតិចចំនួនប្រាំនាក់មកពីខេត្តរតនគីរី រត់គេចពីភូមិស្រុករបស់ពួកគេ បន្ទាប់ពីបានទទួលការគំរាមដល់ជីវិតជាលាយលក្ខណ៍អក្សរ ។ ពួកគេធ្លាប់បានទទួលការគំរាមកំហែងរួចមកហើយពីបទថាបានផ្តល់អាហារ និងជម្រកឱ្យជនម៉ុងតាញ៉ាដែលស្វែងរកសិទ្ធិជ្រកកោននៅពេលក្រុមនេះកំពុងរង់ចាំតំណាងមន្ត្រីឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនដឹកសង្គ្រោះពួកគេចេញពីព្រៃភ្នំ ។

នៅខេត្តមណ្ឌលគីរី អ្នកស្រុករស់នៅតាមព្រំដែនបានរាយការថា ការគំរាមកំហែងចាប់ខ្លួនពីសំណាក់នគរបាល និងមន្ត្រីរដ្ឋាភិបាលមូលដ្ឋាននៅតែបន្តចំពោះអ្នកស្រុករស់នៅតាមព្រំដែន ប្រសិនបើពួកគេជួយជនភៀសខ្លួនម៉ុងតាញ៉ា។ អ្នកដែលត្រូវបានសង្ស័យថា ផ្តល់ជំនួយដល់ជនស្វែងរកសិទ្ធិជ្រកកោនត្រូវបានគេឃ្លាំមើលយ៉ាងជិតដល់ពីសំណាក់នគរបាល និងដាក់ភ្នាក់ងារបង្កប់របស់រដ្ឋាភិបាល[១៦] ។

នៅខែសីហា ភាពគ្រោះថ្នាក់ដែលធ្លាប់មានពីមុន ត្រូវបានបង្កើតតាមរយៈការចាប់ខ្លួនពលរដ្ឋខ្មែរមួយរូបដែលដឹកនាំអ្នកស្វែងរកសិទ្ធិជ្រកកោនកុកសម្ព័ន្ធម៉ុងតាញ៉ាទៅការិយាល័យឧត្តមស្នងអង្គការការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននៅក្រុងភ្នំពេញ ។ លោក គង់ សុត ត្រូវបានគេនាំចេញពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ដោយមន្ត្រីនគរបាលរបស់ក្រសួងមហាផ្ទៃ នៅថ្ងៃទី៣១ ខែសីហា បន្ទាប់ពីគាត់បានអមដំណើរជនម៉ុងតាញ៉ាចំនួនបីនាក់ ដែលចូលមកកម្ពុជាពីប្រទេសវៀតណាមដោយខ្លួនគេ ដោយនាំខ្លួនពួកគេផ្ទាល់ទៅកាន់ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ដើម្បីទាមទារស្វែងរកសិទ្ធិជ្រកកោននៅថ្ងៃនោះ ។ លោក គង់ សុខ ត្រូវបានចាប់ខ្លួន ហើយចោទពីបទរំលោភបំពានច្បាប់អន្តោប្រវេសន៍ដោយតុលាការក្រុងភ្នំពេញ ហើយបញ្ជូនគាត់ដាក់ពន្ធនាគារព្រៃស ។ នៅថ្ងៃទី១ ខែធ្នូ ក្នុងខណៈពេលរបាយការណ៍សង្ខេបស្តីពីការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សត្រូវបានបញ្ចប់ លោក គង់ សុខ ត្រូវបានផ្តន្ទាទោសដោយតុលាការក្រុងភ្នំពេញពីបទ "ជួយលាក់បំពួន" ជនបរទេសដែលបានចូលកម្ពុជាដោយខុសច្បាប់ ។ គាត់ត្រូវបានផ្តន្ទាទោសដាក់ក្នុងពន្ធនាគាររយៈពេលបីខែ ។ ការផ្តន្ទាទោសលើរូបគាត់ ដោយគ្រាន់តែបានជួយជនជាតិម៉ុងតាញ៉ា ដែលបានចូលមកដល់កម្ពុជារួចទៅហើយ ដើម្បីស្វែងរកការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនខ្លួនក្នុងគោលបំណងដាក់ពាក្យស្វែងរកសុំឋានៈជាជនសុំសិទ្ធិជ្រកកោនផ្នែកនយោបាយនេះ គឺជាការគំរាមកំហែងដល់អ្នកការពារសិទ្ធិមនុស្សដែលការពារអ្នកដទៃក្នុងការស្វែងរកសិទ្ធិជ្រកកោននៅកម្ពុជា ។

## តំណាងសហជីពកម្មករ

នៅឆ្នាំ២០០៦ ត្រូវបានមើលឃើញថា មានការកើនឡើងនូវករណីចាប់ខ្លួន វាយធ្វើបាប និងគំរាមកំហែង

---

[16] អត្ថបទរបស់លោក Thet Sambath & Douglas Gilson ក្រោមចំណងជើងថា " អ្នកភូមិភ័យខ្លាចការចាប់ខ្លួន ដោយសារតែជួយដល់អ្នកស្វែងរកសិទ្ធិជ្រកកោន ។ ព្រឹត្តិប័ត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៦ ។

ដល់សហជីពកម្មករ ជាពិសេសក្នុងវិស័យកាត់ដេរ ។ ការកើនឡើងយ៉ាងលឿននូវករណីដូចពោលពីខាងដើមបានឆ្លុះបញ្ចាំងពីការធ្លាក់ចុះខាងវិស័យការងារ និងជីវភាពរស់នៅរបស់កម្មករ បន្ទាប់ពីការផុតអាណត្តិនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសំខាន់ៗ ហើយប្រាក់បៀវត្សអប្បបរមាមិនបានឆ្លើយតបទៅនឹងអតិផរណាដែលចេះតែកើនឡើង ។ ដោយសារមូលហេតុទាំងអស់នេះ ទើបមានកើតជាកូដកម្ម និងការទាមទារផ្សេងៗទៀត ដែលដឹកនាំដោយសហជីពកម្មករ ដែលធ្វើឱ្យតំណាងសហជីពកាន់តែច្រើនឡើងៗក្លាយជាគោលដៅវាយប្រហារជាលក្ខណៈបុគ្គល ។

កិច្ចព្រមព្រៀងពហុសរសៃដែលផុតអាណត្តិនៅថ្ងៃទី៣១ ខែធ្នូ ២០០៤ បែងចែកកូតាវាយនភ័ណ្ឌឱ្យប្រទេសកំពុងអភិវឌ្ឍសំរាប់នាំចេញទៅប្រទេសអ្នកមាន ហើយកូតាបែងចែកវាយនភ័ណ្ឌនេះផ្តល់សារប្រយោជន៍ជាសារវ័ណ្ឌសំរាប់ធានាទីផ្សារឧស្សាហកម្មកាត់ដេរកម្ពុជា ។ អ្នកអង្កេតការណ៍មួយចំនួនធ្វើការអះអាងថា បន្ទាប់ពីកិច្ចព្រមព្រៀងពហុសរសៃផុតអាណត្តិ នោះម្ចាស់រោងចក្រដែលមានជំហរមិនហ្មត់ចត់កំពុងធ្វើអាជីវកម្មមិនពិតប្រាកដចំពោះប័ណ្ណបញ្ជាទិញផលិតផលវាយនភ័ណ្ឌ ដើម្បីបន្ថយសិទ្ធិរបស់កម្មករបណ្តើរៗ ជាពិសេសទាក់ទងនឹងកំរិតនៃប្រាក់បៀវត្ស និងការធានាការងារ [១៧] ។ ស្របពេលជាមួយគ្នានេះដែរ ប្រាក់បៀវត្សអប្បបរិមានៅក្នុងឧស្សាហកម្មកាត់ដេរគឺចំនួន ៤៥ ដុល្លារក្នុងមួយខែចាប់តាំងតែឆ្នាំ២០០០មក ទោះបីជាមានអត្រាអតិផរណាគិតជាមធ្យម៥.៨% នៅឆ្នាំ២០០៥ក៏ដោយ [១៨] ។ ក្រោយពេលមានកិច្ចចរចាដ៏ទាល់ច្រកមួយរវាងតំណាងសហជីព និងនិយោជកនានា រដ្ឋាភិបាលសំរេចបង្កើនប្រាក់បៀវត្សរបស់កម្មករជាអប្បបរិមា ៥ដុល្លារក្នុងមួយខែ- ប៉ុន្តែកំណត់ថេរវេលារហូតដល់ឆ្នាំ២០១០ ។ ប៉ុន្តែ សហជីពកម្មករជាច្រើននិយាយថា ចំនួននេះនៅកំរិតយ៉ាងទាប វានឹងជាសក្តានុពលនៃការកើតមានកូដកម្មណាមួយនាថ្ងៃអនាគត [១៩] ។



ថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៦ នគរបាលបានរាយកម្លាំងគ្រប់ច្រកដើម្បី រាំងខ្ទប់មិនឱ្យកម្មករចូលរួមប្រារព្ធពិធីទ វាពលកម្មអន្តរជាតិ ។

មានកូដកម្មមួយចំនួនមិនត្រូវបានបង្ក្រាប តែមានកូដកម្មជាច្រើនទទួលរងនូវការបង្ក្រាប និងបណ្តឹងគ្មានភស្តុតាងតាមច្បាប់ជាច្រើន ហើយក៏មានការចោទប្រកាន់ទៅលើតំណាងសហជីពកម្មករដែលត្រូវចោទប្រកាន់ពីបទ "ញុះញង់ " អ្នកដទៃឱ្យធ្វើកូដកម្ម ។ កូដកម្មរួមគ្នាមួយបានធ្វើនៅខែកុម្ភៈ ឆ្នាំ២០០៦ ដែលមានកម្មករជាង ១០.០០០ នាក់មកពីរោងចក្រកាត់ដេរចំនួនប្រាំពីរ ដែលមានទីតាំងនៅក្រុងភ្នំពេញ និងខេត្តកណ្តាលចូលរួមបណ្តាលឱ្យម្ចាស់រោងចក្រកាត់ដេរឈ្មោះ Flying Dragon 3 ដាក់ពាក្យបណ្តឹងពីបទព្រហ្មទណ្ឌទៅលើតំណាងសហជីពប្រាំពីរនាក់មកពីសម្ព័ន្ធសហជីពកម្មករផ្នែកសំលៀកបំពាក់ ដើម្បីលទ្ធិប្រជាធិតេយ្យនៅកម្ពុជា ។ ជនជាប់ចោទទាំងប្រាំពីរនាក់ត្រូវបានចោទប្រកាន់ពីបទញុះញង់ ទោះបីជាពុំមានភស្តុតាងណាមួយដើម្បីដាក់បន្ទុកបទ ចោទប្រកាន់នេះក៏ដោយ ។

---

[17] សំរាប់ព័ត៌មានបន្ថែមសូមអានអត្ថបទក្រោមចំណងជើងថា " កម្ពុជា: កំពុងធ្វើការគាបសង្កត់លើសិទ្ធិរបស់សហជីពកម្មករ-ផលប៉ះពាល់បន្ទាប់ពីបញ្ចប់អាណត្តិកូតាឧស្សាហកម្មវាយនភ័ណ្ឌ ។ សហជីពសហព័ន្ធសេរីអន្តរជាតិ (International Confederation of Free Trade Union) ។

[18] ធានាគារអភិវឌ្ឍន៏អាស៊ី :ចក្ខុវិស័យនៃការអភិវឌ្ឍន៏នៅអាស៊ី ឆ្នាំ២០០៦

[1919] Prak Chan Thul & Erik Wasson: សហជីពកម្មករមិនទាន់សំរេចចិត្តពីវិធានការណ៍ធ្វើកូដកម្មទាមទារដំឡើងប្រាក់ខែ ។ ព្រឹត្តិបត្រ The Cambodia Diay ចេញផ្សាយនៅថ្ងៃទី ២១-២២ ខែតុលា ២០០៦ ។

ជនជាប់ចោទទាំងប្រាំពីរនាក់បានទទួលដីការកោះហៅឱ្យបង្ហាញខ្លួននៅតុលាការក្រុង ភ្នំពេញ ទង្វើនេះធ្វើឱ្យអ្នកទាំងអស់នោះយល់ពីស្ថានភាព ហើយមានការកាត់បន្ថយការទាមទារ ហើយព្យាយាមចរចារជាមួយអ្នកគ្រប់គ្រងរោងចក្រ ដើម្បីស្វែងរកមធ្យោបាយដំណោះស្រាយ ។

តំណាងរបស់សហជីពពាណិជ្ជកម្មសេរី មានលោក ឡាច សំបូ, សាល គឹមសាន្ត, និង យឹម គុន មកពីរោងចក្រកាត់ដេរនៅខេត្តកណ្តាលឈ្មោះ Genuine មានភ័ព្វសំណាងតិច ដែលប្រឈមមុខជាមួយការចោទប្រកាន់ជាច្រើនដងក្នុងឆ្នាំ២០០៦ ។ នៅថ្ងៃទី១២ ខែមិថុនា ពួកគេនិងសកម្មជនប្រាំនាក់ផ្សេងទៀតត្រូវបានផ្តន្ទាទោសដាក់ក្នុងពន្ធនាគាររយៈពេលមួយឆ្នាំ ហើយបង្ខំឱ្យបង់ប្រាក់ពិន័យចំនួន ៨ លានរៀល (២.០០០ដុល្លារ) ក្នុងករណីពាក់ព័ន្ធជាមួយកូដកម្មនៅឆ្នាំ២០០៤ ។ បន្ទាប់ពីប្តឹងឧទ្ធរណ៍ជំទាស់នឹងសាលក្រមរបស់តុលាការដំបូង ពួកគេត្រូវព្យួរពីការងារជាហេតុនាំឱ្យមានការធ្វើកូដកម្មបន្តជាប់គ្នាប្រាំមួយថ្ងៃនៅរោងចក្រនោះ ។ នៅថ្ងៃទី៣ ខែកក្កដា ពួកគេត្រូវបានចាប់ខ្លួន ហើយចោទពីបទបង្ខាំងមនុស្សខុសច្បាប់ក្នុងអំឡុងពេលធ្វើកូដកម្មចុងក្រោយ ។ទោះបី ពុំមានភស្តុតាងដើម្បីដាក់បន្ទុកលើការចោទប្រកាន់ក៏ដោយ តែពួកគេត្រូវបានផ្តន្ទាទោសនៅថ្ងៃទី៧ ខែសីហា តែទោសនេះត្រូវបានព្យួរក្នុងយៈពេលបីឆ្នាំ ។ នៅពេលសរសេររបាយការសង្ខេបនេះ មានសេចក្តីរាយការណ៍ថា ពួកគេប្រឈមមុខជាមួយបណ្តឹងរដ្ឋប្បវេណី ដែលប្តឹងដោយម្ចាស់រោងចក្រ ។

នៅឆ្នាំ២០០៦ មេដឹកនាំសហជីពកម្មករ ធ្លាប់ជាជនរងគ្រោះនៃអំពើវាយប្រហារលើរាងកាយយ៉ាងធ្ងន់ធ្ងរដោសាយអ្នកទាំងនោះជាអ្នកការពារសិទ្ធិមនុស្ស។ នៅថ្ងៃទី៤ ខែកក្កដា លោក ឡាយ ចំរើន អនុប្រធានសហជីពកម្មករសេរីនៅរោងចក្រកាត់ដេរនៅក្រុងភ្នំពេញ ត្រូវរងគ្រោះដោយគេបាញ់ត្រូវរបួសជើងនៅពេលធ្វើដំណើរទៅកន្លែងធ្វើការ ដែលគេមន្ទិលសង្ស័យថា ការវាយប្រហារនេះអាចជាប់ទាក់ទងនឹងសកម្មភាពសហជីពរបស់គាត់ប៉ុន្មានថ្ងៃមុននេះ ។ គួររំលឹកករណីលោក ជា វិជ្ជា ប្រធានសហជីពកម្មករសេរីនៅព្រះរាជាណាចក្រកម្ពុជា ដែលត្រូវគេបាញ់សំលាប់នៅតាមដងវិថីនៅទីក្រុងភ្នំពេញ នៅខែមករា ឆ្នាំ២០០៤ និងលោក រស់ សូវណ្ណារេត មេដឹកនាំសហជីពកម្មករសេរី ដែលត្រូវគេបាញ់សំលាប់នៅខែឧសភាក្នុងឆ្នាំតែមួយ [20] ។

### ករណីសិក្សាៈ មេដឹកនាំសហជីពកម្មករនៅរោងចក្រ Bright Sky និង Suntex

ប្រហែលជាករណីធ្ងន់ធ្ងរបំផុត ដែលបានរាយការណ៍ក្នុងអំឡុងពេលដប់ខែនៃឆ្នាំ២០០៦នេះ ដែលជាប់ពាក់ព័ន្ធជាមួយសមាជិកសហជីពកម្មករសេរីនៃព្រះរាជាណាចក្រកម្ពុជាបំរើការងារនៅរោងចក្រ **“Bright Sky”** **និង** **“Suntex”** ដែលមានទីតាំងនៅស្រុកដង្កោ ក្រុងភ្នំពេញ។ សកម្មភាពពេញឆ្នាំ២០០៦ ពួកគេបានខិតខំបញ្ចុះបញ្ចូល ដើម្បីកែលំអលក្ខខណ្ឌការងារ ជាពិសេស ថេរវេលាកិច្ចសន្យា ។ ក៏ប៉ុន្តែ កិច្ចខិតខំប្រឹងទាំងនេះរំខានដោយការគំរាមកំហែងយ៉ាងខ្លាំងខ្លា និងការវាយធ្វើបាបដល់រាងកាយយ៉ាងឃោរឃៅទៅវិញ ។

នៅថ្ងៃទី៣ ខែឧសភា នៅពេលធ្វើដំណើរត្រឡប់ទៅកាន់លំនៅដ្ឋាន បន្ទាប់ពីបញ្ចប់ធ្វើការនៅវេនយប់ លោក ជី សាម៉ុន ប្រធានសហជីពកម្មករសេរីប្រចាំរោងចក្រ **Bright Sky** ត្រូវបានគេវាយប្រហារ និងវាយឱ្យរង

[20] សំរាប់ព័ត៌មានបន្ថែម សូមអត្ថបទរបស់ Amnesty International ក្រោមចំណងជើងថា ″ ព្រះរាជាណាចក្រកម្ពុជា :ការបាញ់សំលាប់មេដឹកនាំសហជីពលោក ជា វិជ្ជា ។ចេញផ្សាយនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៤ ។

របួសជាទំងន់ ដោយមនុស្សមួយក្រុមមានគ្នាប្រាំពីរនាក់ នៅចំងាយប្រមាណ៣០ម៉ែត្រពីរោងចក្រនោះ ។ ប្រាំបួនថ្ងៃក្រោយមក គឺចំថ្ងៃលោក ជី សាម៉ុន ត្រលប់ចូលធ្វើការវិញ រួមជាមួយសហការី គឺលោក យ៉េង វណ្ណយុទ្ធ ទទួលរងនូវការវាយប្រហារដូចគ្នា ។ នៅថ្ងៃទី១៩ ខែកញ្ញា លោក ជ័យ រិទ្ធី អនុប្រធានសហជីពកម្មករសេរីប្រចាំរោងចក្រ **Suntex** ត្រូវបានវាយប្រហារដោយជនមិនស្គាល់អត្តសញ្ញាណពីរនាក់ ដែលចោលដុំថ្មមកលើគាត់ និងភរិយាដែលមានផ្ទៃពោះ នៅពេលជិះម៉ូតូពីរោងចក្រទៅគេហដ្ឋាន ។ នៅថ្ងៃទី ២២ ខែឧសភា នៅពេលត្រលប់ពីធ្វើការនៅវេនយប់វិញ លោក ជី សាម៉ុន បានប្រឈមមុខម្តងទៀតជាមួយមនុស្សចំនួន២០នាក់។ ប៉ុន្តែ គាត់បានរត់គេចខ្លួនរួចដោយពួនលាក់ខ្លួននៅរោងចក្ររហូតដល់ហៀបភ្លឺ។ នៅថ្ងៃទី៨ ខែមិថុនា លោក ឡឹម សុីត ហិរញ្ញិករបស់សហជីពកម្មករសេរីប្រចាំរោងចក្រ **Bright Sky** ត្រូវបានវាយដំដោយមនុស្សប្រុសមួយក្រុម ហើយនៅថ្ងៃទី១៩ លោក ចយ ជិន អគ្គលេខាធិការរបស់សហជីពកម្មករសេរីប្រចាំរោងចក្រ **Suntex** ទទួលរងនូវការវាយប្រហារដោយជនមិនស្គាល់មុខពីរនាក់ ដែលចោលដុំថ្មមកលើគាត់ ព្រមទាំងវាយគាត់នឹងដែកបំពង់ទីប ។

លោក ជី សាម៉ុន បានស្គាល់អត្តសញ្ញាណបុរសម្នាក់ក្នុងចំណោមមនុស្សដែលវាយប្រហារមកលើគាត់ និងសហការីរបស់គាត់លោក យ៉េង វណ្ណយុទ្ធ គឺជាសមាជិកសហជីពកម្មករដែលជាគូរប្រជែង ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល ហើយគាត់បានផ្តល់ឈ្មោះជននោះទៅនគរបាល និងតុលាការក្រុងភ្នំពេញ។ ករណីទាំងនេះពុំមានការស៊ើបអង្កេតណាមួយឡើយ ។

ទោះបីការវាយប្រហារនៅតែបន្ត សកម្មជនស្ត្រីវ័យក្មេងឈ្មោះ អ៊ឹម ចៃទៀង ព្រមទទួលយកមុខតំណែងជាអនុប្រធានសហជីពកម្មករសេរីប្រចាំរោងចក្រ **Bright Sky** នៅខែកក្កដា ។ ភ្លាមនោះ នាងចាប់ផ្តើមទទួលការគំរាមកំហែងជាច្រើន ។

> *"ពួកគេគំរាមខ្ញុំ និងលោក សាម៉ុន ដែលចេញពីលេខទូរសព្ទតែមួយ ។ ពួកគេប្រាប់យើងឱ្យបញ្ឈប់ការពាក់ព័ន្ធជាមួយសហជីពសេរីកម្មករ ហើយស្វែងរកការងារអ្វីផ្សេងធ្វើវិញ....ប្រសិនបើអ្នកឯងនៅតែបន្តការងារនេះទៀត លទ្ធផលចុងក្រោយពួកអ្នកឯងនឹងស្លាប់ ។ ខ្ញុំប្រាប់ទៅពួកអ្នកគំរាមនោះវិញថា ខ្ញុំនឹងមិនឈប់ទេ ខ្ញុំទើបតែចាប់ផ្តើមប៉ុណ្ណោះ ។ កាលពីមុន តំណែងនេះផ្តល់ឱ្យស្ត្រីដែលធ្វើការនៅវេនថ្ងៃ ក៏ប៉ុន្តែ ស្ត្រីរូបនោះត្រូវបានគេគំរាមនិងវាយចំមុខ។ បន្ទាប់មកនាងក៏លាឈប់ពីព្រោះនាងភ័យខ្លាចថា នាងនឹងត្រូវគេច្របាច់កនិងសំលាប់ ។ ខ្ញុំធ្វើការងារជំនួសគាត់ ។ តាំងពីពេលនោះមក ខ្ញុំត្រូវគេតាមគំរាមជារហូត ។ លោក សាម៉ុន និងខ្ញុំធ្វើការនៅវេនយប់ ហើយនៅពេលគាត់មិនមកធ្វើការ ខ្ញុំនឹងជំនួសកិច្ចការគាត់ ដើម្បីជួយដល់កម្មករ... ដែលពួកគេតែងតែរកខ្ញុំជួយ នៅពេលលោក សាម៉ុន មិនមកធ្វើការ ឬគាត់ឈឺ ពួកគេមិនទៅរកអ្នកណាផ្សេងឡើយ "* ។

នៅដើមខែតុលា កម្មករនៅរោងចក្រ **Bright Sky** ធ្វើកូដកម្មរឿងវិវាទស្តីពីពេលវេលានៃកិច្ចសន្យាការងារ ។ នៅពេលពួកគេវិលត្រលប់ចូលធ្វើការនៅវេនយប់វិញ នៅថ្ងៃ១៦ ខែតុលា នគរបាលសំរុកចូលក្នុងរោងចក្រព្យាយាមចាប់ខ្លួនសកម្មជនសហជីពកម្មករ ហើយវាយបំបែកដោយហិង្សាទៅលើកម្មករ ដែលសំរេចចិត្តបន្តធ្វើកូដកម្មដើម្បីតវ៉ា ។ អ៊ឹម ចៃទៀង ក៏ជាជនរងគ្រោះដែរ ។

*"សាម៉ុន មកដល់ ហើយបន្ទាប់មាននគរបាល និងទាហានភ្ជង់កាំភ្លើងតំរង់ទៅគាត់ នៅពេលនោះមាននគរបាលពី ២០ទៅ៣០នាក់ ដើរពីក្រោយគាត់ ។ ពេលនោះមានកម្មករម្នាក់ប្រាប់ខ្ញុំថា ពួកនគរបាលនឹងចាប់លោក សាម៉ុន.... ពេលនោះម៉ោង៥ល្ងាច ហើយមានកម្មករជាច្រើននាក់ ទោះបីជាពួកគេបានបញ្ចូលកាតទៅក្នុង ម៉ាស៊ីនរួចហើយក៏ដោយ ក៏ពួកគេមិនបានចាប់ផ្ដើមធ្វើការដែរ ដោយសារពួកគេស្រលាញ់តំណាងសហជីព ។ ភ្លាមៗនោះក៏មានអំពើអនាធិតេយ្យកើតឡើង ក្នុងខណៈដែលតំណាងរោងចក្រគំរាមថា ពួកគេនឹងចាប់លោក សាម៉ុន ។ ពេលនោះកម្មករមិនទៅធ្វើការទេ នៅតែបន្តធ្វើកូដកម្មទៅទៀត....*

*នគរបាលហ៊ុំព័ទ្ធពួកគេក្នុងខណៈដែលខ្ញុំដឹកនាំកម្មករដង្ហែរក្បួន ហើយយើងស្រែកថា យើងនឹងដើររហូតដល់ ព្រឹក ។ នៅម៉ោង៧:៣០នាទីល្ងាច យើងដើរមកដល់កន្លែងមួយ ហើយមាននគរបាលម្នាក់- ខ្ញុំមិនស្គាល់គាត់ទេ វាយខ្ញុំចំាមុខ និងច្រមុះ ។ ខ្ញុំហូរឈាមច្រើនណាស់ ដែលត្រូវការដេរជាច្រើនថ្នេរ ។*

*"ជិតម៉ោង ៩ យប់ ខ្ញុំឈរនៅខាងមុខរោងចក្រ* **Bright Sky** *ដែលមានកម្មករឈរនៅជ្រុងម្ខាង ហើយពួក យើងជាតំណាងសហជីពឈរនៅឯជ្រុងម្ខាងទៀត ។ ខ្ញុំបានឃើញរថយន្តមួយគ្រឿងដឹកនគរបាលប្រមាណ ៣០ នាក់ ពួកគេស្រែកថា "ចាប់ស្រីម្នាក់នោះដាក់ចូលក្នុងឡាន... ចាប់ពួកប្រុសៗ ហើយសំលាប់ពួកវា "ខ្ញុំរន្ធត់ជា ខ្លាំង ហើយរត់រកសាម៉ុន.... បន្ទាប់មក ខ្ញុំឃើញកម្មករម្នាក់កំពុងត្រូវគេវាយដំនៅចំពោះមុខខ្ញុំ គាត់សន្លប់បាត់ ស្មារតី ហើយខ្ញុំលើកគ្រាគាត់ ប៉ុន្តែកម្មករជាច្រើននាក់ទាញដៃខ្ញុំចេញ ហើយប្រាប់ខ្ញុំឱ្យរត់គេច... បន្ទាប់មកខ្ញុំ ឃើញនគរបាលវាយស្ត្រីមានផ្ទៃពោះម្នាក់ ហើយខ្ញុំជួយគ្រាគាត់រត់ចេញទៅ ។ ថ្ងៃបន្ទាប់ ស្ត្រីនោះមិនបានស្នាក់ នៅក្នុងមន្ទីរពេទ្យទេ ឪពុកម្ដាយរបស់នាងយកនាងត្រលប់ទៅផ្ទះ ហើយនាងបានរលូតកូន ។*

*"ក្នុងខណៈដែលខ្ញុំព្យាយាមរត់គេច នគរបាលតាមពីក្រោយ ហើយព្យាយាមបាញ់សំដៅមកលើខ្ញុំ ស្របពេល នោះមានកម្មករជាស្រីម្នាក់រត់ពីក្រោយខ្ញុំ ត្រូវគ្រាប់ត្រង់ក្បាលពោះ " ។*

កម្មករធ្វើការវេនយប់នៅរោងចក្រ **Bright Sky** ដែលមានកញ្ញា អ៊ឹម ចៃទ្បេង លោក ជី សាម៉ុន និង តំណាងសហជីពកម្មករសេរីដទៃទៀត ឥឡូវត្រូវគេបានបញ្ឈប់ពីការងារ ហើយស្វែងរកការងារថ្មី ។ យោងតាម កញ្ញា អ៊ឹម ចៃទ្បេង និយាយថា ពួកគេរកការងារថ្មីបានធ្វើហើយ ។ នាងបានបន្ថែមថា កិច្ចការពារសិទ្ធិការងារនៅ កម្ពុជាអាចជួបប្រទះគ្រោះថ្នាក់ជាច្រើន ។

*"ក្រុមហ៊ុនបានបញ្ជូនរូបថតពួកយើងសរុបមានចំនួន ១៦ នាក់ ទៅគ្រប់រោងចក្រ ដោយប្រាប់រោងចក្រទាំង នោះមិនឱ្យទទួលយកពួកយើងធ្វើការទេ ព្រមទាំងមេដឹកនាំសហជីពផ្សេងទៀត ។ ព្រឹកនេះខ្ញុំទៅសម្ភាសន៍ នៅរោងចក្រមួយកន្លែង-គេឱ្យខ្ញុំធ្វើជាប្រធានក្រុម... តែបន្ទាប់ធ្វើការបានកន្លះថ្ងៃ គេយកប្រវត្តិរូបរបស់ខ្ញុំ ហើយនិយាយថាសូមទោស អ្នកមកពីរោងចក្រ* **BrightSky** *ចៅហ្វាយមិនទទួលយកអ្នកទេ។ នៅរោង ចក្រមួយចំនួន គេមិនបានដាក់បង្ហាញរូបថតរបស់ពួកយើងនៅទេ ប៉ុន្តែដាក់បង្ហាញនៅការិយាល័យ ហើយរោង ចក្រនៅជិតព្រៃស មានរូបថតរបស់ខ្ញុំដាក់តាំងនៅប៉ុស្តិ៍នគរបាល-ខ្ញុំបានឃើញផ្ទាល់នឹងភ្នែក ។ ពួកគេមានបោះ ត្រាពីក្រសួងការងារ ដែលមានលិខិតសរសេរថា មនុស្សទាំងនេះមិនត្រូវទទួលយកធ្វើការឡើយ ដោយសារ*

*ពួកគេជាមេដឹកនាំក្លែងក្លាយ"* ។

## សកម្មជនដីធ្លី និងធនធានធម្មជាតិ

វិវាទដីធ្លី និងធនធានធម្មជាតិ កំពុងតែកើនឡើងនៅកម្ពុជា ក្នុងអត្រាមួយគួរឱ្យភ័យខ្លាច [២១] ហើយដោយសារបញ្ហានេះបានបង្កឡើងនូវការគំរាម និងវាយប្រហារមកលើសកម្មជនសហគមន៍ និងតំណាងដែលមានសេចក្តីក្លាហានធ្វើសកម្មភាពជួសមុខឱ្យប្រជាពលរដ្ឋ ។

ក្នុងករណីនេះ អំពើវាយប្រហារមានជាច្រើនទម្រង់ខុសៗគ្នា ចាប់ពីការគំរាមដោយពាក្យសំដី និងការយាយីតិចតួចរហូតដល់ការវាយដំលើរាងកាយធ្ងន់ធ្ងរ ជាពិសេសនៅពេលប្រតិបត្តិការបណ្តេញដោយហិង្សា ។ យុទ្ធសាស្ត្រមួយដែលជនល្មើសចូលចិត្តប្រើក្នុងករណីសំខាន់ៗ គឺកំណត់មុខសញ្ញាដែលជាតំណាងរបស់សហគមន៍ដែលពាក់ព័ន្ធ ហើយមានបំណងចាប់និងឃុំខ្លួនដោយចោទប្រកាន់មួលបង្កាច់ពីបទព្រហ្មទណ្ឌ ។ ក្នុងករណីមួយចំនួនទៀត ការចោទប្រកាន់បានផ្អែកទៅលើការសន្មត់ថាសហគមន៍រំលោភបំពានកម្មសិទ្ធិរបស់អ្នកដទៃ ។ នៅពេលមានជំលោះសំខាន់បំផុតនៅត្រង់ថា តើនរណាជាម្ចាស់កម្មសិទ្ធិលើដីនោះពិតប្រាកដ ដែលបញ្ហានេះត្រូវសំរេចដោយតុលាការ ។ តាមការត្រួតពិនិត្យលើបទចោទប្រកាន់ករណីព្រហ្មទណ្ឌ ជាញឹកញាប់បង្ហាញពីចេតនាមិនអនុវត្តច្បាប់ ដូចជា ច្បាប់ភូមិបាលឆ្នាំ២០០១ និងច្បាប់ព្រៃឈើឆ្នាំ២០០២ ។ ក្នុងករណីដទៃទៀត ការចោទប្រកាន់ពាក់ព័ន្ធយ៉ាងតិចតួច ឬគ្មានពាក់ព័ន្ធទាស់តែសោះជាមួយបញ្ហាទំនាស់ ។ ទោះបីជាសកម្មជនត្រូវបានដោះលែងជាបណ្តោះអាសន្ន ក៏បទចោទប្រកាន់លើពួកគេនៅតែតំកល់ទុកនៅឯស្ថាប័នតុលាការក្នុងរយៈពេលវេលាមិនកំណត់មួយ [២២] ។



ក្រុមគ្រួសារជនរងគ្រោះដែលត្រូវចាប់ខ្លួនពេលមានការបណ្តេញដោយអំពើហិង្សាត្រូវបានរាំងនៅ តាមផ្លូវពេលមានដង្ហែរ ក្បួនទាមទារឱ្យដោះលែងពួកគេ ។

គេមានចេតនាយ៉ាងច្បាស់ ដោយប្រើការចោទប្រកាន់ ដើម្បីបំភិតបំភ័យសហគមន៍ដែលពាក់ព័ន្ធ ដើម្បីឱ្យពួកគេបោះបង់ចោលដី ឬធនធានធម្មជាតិ ហើយដាក់ទណ្ឌកម្មបុគ្គលណាដែលព្យាយាមការពារសហគមន៍ ។ ការគំរាមកំហែងបែបនេះបណ្តាលឱ្យសហគមន៍មួយចំនួនបង្កើតយុទ្ធវិធីថ្មី ដូចជា មិនផ្តល់អត្តសញ្ញាណជាក់លាក់ចំពោះតំណាងរបស់ពួកក្នុងគោលបំណងការពារពួកគេពីការចាប់ខ្លួន ។ ផ្ទុយទៅវិញ ពួកគេអះអាងថា សមាជិកគ្នាទាំងអស់សុទ្ធតែសកម្មជនដូចៗគ្នា ។ ទោះបីជាមានកំលាំងខ្លាំងតាមរយៈការធ្វើសកម្មភាពរួបរួមគ្នាក្នុងស្មារតីសាមគ្គីភាព ព្រមទាំងមានការកើនឡើងបណ្តាញការងារប្រកបដោយប្រសិទ្ធិភាពខ្ពស់ និងកិច្ចប្រឹងប្រែងតស៊ូមតិរបស់សកម្មជន តែជោគវាសនា និងការតស៊ូរបស់សហគមន៍ក្រីក្រ និងមេដឹកនាំរបស់ពួកអ្នកទាំងអស់នោះនៅស្ថិតនៅក្នុងកណ្តាប់ដៃអ្នកមានអំណាច ។

---

[21] នៅឆ្នាំ ២០០៣ លីកាដូបានតាមដានករណីរំលោភយកដី២៥ករណី ហើយនៅឆ្នាំ ២០០៥ ករណីរំលោភយកដីបានកើនរហូតដល់ ១២៦ករណី បណ្តាលឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋ ៩.៨៣២ គ្រួសារ ។

[22] ជាញឹកញាប់តុលាការធ្វើមិនដឹងចំពោះនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលតម្រូវនាំខ្លួនជនជាប់ចោទមកកាត់សេចក្តីក្នុងរយៈពេល ៦ខែបន្ទាប់ពីថ្ងៃចាប់ខ្លួន មិនថាពួកគេជាប់ឃុំ ឬនៅក្រៅឃុំបណ្តោះអាសន្នក្នុងដំណាក់កាលស៊ើបអង្កេត ។

ក្នុងជំនួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មន្ត្រីគណបក្សជំទាស់ជាច្រើនរូប និងតំណាងអង្គការមិនមែនរដ្ឋាភិបាល នៅថ្ងៃទី១៥ ខែមីនា មានដំណើរផ្លាស់ប្តូរមួយគួរឱ្យកត់សំគាល់ ដោយលោកនាយករដ្ឋមន្ត្រីបានឯកភាព ថានឹងដោះលែងអ្នកភូមិទាំងអស់ដែលត្រូវឃុំខ្លួនដោយសាររឿងវិវាទដីធ្លី [២៣] ។ ប៉ុន្មានសប្តាហ៍ក្រោយមកអ្នកភូមិជាច្រើននាក់ រួមទាំងអ្នកការពារសិទ្ធិមនុស្សមួយចំនួនត្រូវបានដោះលែងពីពន្ធនាគារ ។ ក៏ប៉ុន្តែ ការគំរាមកំហែងនៅតែមានបន្ត ។ សឹងតែគ្រប់ករណីទាំងអស់នៃបទចោទប្រកាន់នៅមិនទាន់បញ្ឈប់នៅឡើយទេ ហើយសកម្មជនដែលទើបដោះលែងនៅតែមានការព្រួយបារម្ភណ៍ជានិច្ច ។ តំណាងសហគមន៍នៅក្នុងករណីផ្សេងទៀតត្រូវបានចាប់និងឃុំខ្លួនចាប់តាំងពីថ្ងៃទី១៥ ខែឧសភា ។ ទន្ទឹមគ្នានេះ លីកាដូបានសំដែងកិច្ចស្វាគមន៍ការដោះលែងអ្នកដែលត្រូវបានឃុំខ្លួនដោយខុសច្បាប់ ក៏ប៉ុន្តែសំដែងការព្រួយបារម្ភណ៍អំពីស្ថានភាពមួយដែលសេរីភាពរបស់ប្រជាពលរដ្ឋស្ថិតនៅក្នុងកណ្តាប់ដៃអ្នកមានអំណាច ហើយមិនមែនជាសេចក្តីសំរេចដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ។

ដោយសារទំនាស់ដីធ្លី និងធនធានធម្មជាតិបានកើតឡើងនៅគ្រប់ទីកន្លែងនៃប្រទេសកម្ពុជា ដូច្នេះគេមិនមានត្រូវភ្ញាក់ផ្អើលអ្វីសោះចំពោះការធ្វើទុក្ខបុកម្នេលើអ្នកការពារសិទ្ធិមនុស្សនៅគ្រប់ទីកន្លែង ដូចបានកត់ត្រានៅក្នុងឆ្នាំ២០០៦ ។ ជាឧទាហរណ៍ នៅខេត្តរតនគីរី សកម្មជនពីររូបដែលជាប់ពាក់ព័ន្ធជាមួយវិវាទដីធ្លីដែលបានអូសបន្លាយអស់រយៈពេលយូរអង្វែងត្រូវបានឃុំខ្លួននៅខែមករា ប៉ុន្មានថ្ងៃបន្ទាប់ពីសកម្មជនម្នាក់ ដែលជាប់ពាក់ព័ន្ធនឹងរឿងវិវាទដីធ្លីនេះដែរដែលត្រូវបានទទួលរងគ្រោះការវាយប្រហារយ៉ាងធ្ងន់ធ្ងរដោយជនមិនស្គាល់អត្តសញ្ញាណ ។ ស្របពេលជាមួយគ្នានេះ មានបុរស ពីរនាក់ត្រូវបានដោះលែងពីពន្ធនាគារនៅខែមីនា បន្ទាប់ពីការសន្យារបស់លោកនាយករដ្ឋមន្ត្រី ។ តុលាការខេត្ត រតនគីរីនៅតែបន្តដាក់គុកសកម្មជនដីធ្លីនៅខែក្នុងកញ្ញា ។ នៅខេត្តក្រចេះ អ្នកភូមិជនជាតិភាគតិចបីនាក់ត្រូវបានចាប់ខ្លួននៅខែកុម្ភៈ នឹងឃុំខ្លួនអស់រយៈពេលពីរខែ បន្ទាប់ពីពួកគេធ្វើយុទ្ធនាការប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើដែលជាទីសក្ការៈរបស់សហគមន៍តែពួកគេទទួលការផ្តន្ទាទោសដោយព្យួរទោស ។ ទង្វើនេះបង្ហាញពីការគំរាមកំហែងមកលើសកម្មជន ។ នៅក្រុងប៉ៃលិន សកម្មជនសហគមន៍ចំនួនប្រាំបួននាក់ត្រូវបានចាប់ដាក់ក្នុងពន្ធនាគារកាលពីខែមីនា បន្ទាប់ពីពួកគេតវ៉ារឿងរំលោភយកដីខុសច្បាប់ ហើយក្នុងខែនោះដែរព្រះសង្ឃមួយអង្គនៅខេត្តកំពតត្រូវបានគេគំរាមឱ្យដោះស្បង់ចីវរ ដោយសារតែព្រះអង្គជួយអ្នកភូមិ ដែលតវ៉ាជំទាស់នឹងការធ្វើសម្បទានដីដែលប៉ះពាល់អ្នកស្រុកចំនួន ១.០២០គ្រួសារ ។ នៅខេត្តកំពង់ស្ពឺ មានអ្នកសារព័ត៌មានពីរនាក់ ត្រូវបានគេភ្ជង់នឹងចុងកាណុងកាំភ្លើង ហើយវាយដំលើដងខ្លួននៅខែមិថុនា បន្ទាប់ពីគេព្យាយាមថតយកទិដ្ឋភាពនៃការរំលោភយកដីធ្លី ។ នៅខេត្តកណ្តាលតំណាងសហ-គមន៍ម្នាក់ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារនៅខែសីហា ដោយសារវិវាទដីធ្លីដែលបង្កឱ្យមានទំនាស់ប្រកបដោយអំពើហិង្សារវាងអាជ្ញាធរ និងអ្នកភូមិដែលទាមទារសុំឱ្យដោះលែងសកម្មជន ។ នៅក្រុងភ្នំពេញ អ្នកសារព័ត៌មានម្នាក់ទទួលរងនូវការគំរាមសំលាប់នៅខែកញ្ញាបន្ទាប់ពីគាត់បង្ហាញរឿងរំលោភយកដីដោយមន្ត្រីមានអំណាច ។

ឧទាហរណ៍ជាក់លាក់នៃមេដឹកនាំសហមគន៍ម្នាក់មកពីខេត្តកំពង់ចាម បានក្លាយជាគោលដៅសំរាប់ជាសកម្មជនទាមទារសិទ្ធិដីធ្លី ហើយត្រូវបានគេចាប់ដាក់ពន្ធនាគារនៅក្នុងខែសីហា ដោយសារគាត់ធ្វើជាតំណាងឱ្យគ្រួសារអ្នក

---

[23] អត្ថបទរបស់ព្រឹត្តិបត្រ The Cambodia Daily ចុះផ្សាយថ្ងៃទី ១៦ ខែមីនា ២០០៦ ក្រោមចំណងជើងថា: លោកនាយករដ្ឋមន្ត្រីដោះលែងអ្នកទោសទំនាស់ដីធ្លី ។

ភូមិចំនួន ១៣៣ គ្រួសារ ដែលរងការគំរាមកំហែង ក្រោយពេលប៉ុន្មានថ្ងៃបន្ទាប់ពីគាត់បានចូលគាល់អតីតព្រះមហាវរក្សត្រ នរោត្តម សីហនុ ។

**ករណីសិក្សា : តាន់ ហេង និងក្រុមហ៊ុនចំការកៅស៊ូបឹងកេត**

វិវាទដីធ្លីមួយមិនទាន់បានដោះស្រាយលើអតីតចំការកៅស៊ូបឹងកេត ដែលមានទំហំ៤៣១ហិកតា នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម បណ្តាលឱ្យតំណាងសហគមន៍ម្នាក់ត្រូវបានឃុំខ្លួន ដែលជាការប៉ុនប៉ងមួយ ដើម្បីគាបសង្កត់លើអ្នកភូមិឱ្យបោះបង់ចោលដីចំការដែលពួកគេទាមទារ ។ ក្រុមហ៊ុនចំការកៅស៊ូបឹងកេតបានអះអាងថាដីដែលមានបញ្ហានោះជាដីរបស់ក្រុមហ៊ុន ហើយបានបញ្ជូនគ្រឿងចក្រជាច្រើនគ្រឿងទៅឈូសឆាយ ហើយអ្នកភូមិនៅទីនោះក៏បានអះអាងផងដែរថា ដីដែលមានបញ្ហានេះជាកម្មសិទ្ធិរបស់ពួកគេ ហើយពួកគេបានដាំដំឡូង និងដំណាំស្វាយចន្ទីលើដីនោះទៀតផង ។ អ្នកភូមិអះអាងថា ពួកគាត់បានមករស់នៅលើដីនេះយូរឆ្នាំហើយ ហេតុដូច្នេះ ពួកគាត់ពិតជាកម្មសិទ្ធិករលើដីទំនាស់នោះដោយស្របច្បាប់បើយោងតាមច្បាប់ភូមិបាល ។

លោក តាន់ ហេង តំណាងឱ្យគ្រួសារដែលពាក់ព័ន្ធនឹងបញ្ហាដីនោះ ត្រូវបានចាប់ខ្លួននៅថ្ងៃទី៣ ខែសីហា អាចចំណុចមន្ទិលសង្ស័យថាហេតុអ្វីគាត់ត្រូវបានគេចាប់ខ្លួន :

*"(ខ្ញុំត្រូវបានគេចាប់ខ្លួន) ពីព្រោះដោយសារខ្ញុំតំណាងឱ្យមនុស្ស ១៣៣ គ្រួសារ ។ ខ្ញុំមិនមានទំនាស់ជាមួយនឹងអ្នកណាម្នាក់ទេ ។ ខ្ញុំទើបតែបញ្ជូនលិខិតទៅការិយាល័យស្ថាប័នពាក់ព័ន្ធនានា ហើយខ្ញុំបានផ្ញើរលិខិតសុំអន្តរាគមន៍ពីគណៈរដ្ឋមន្ត្រី សភាជាតិ ព្រឹទ្ធិសភា និងនាយកដ្ឋានអធិការកិច្ច.... ខ្ញុំអះអាងថា ដីមានទំនាស់នេះជារបស់ប្រជាពលរដ្ឋក្រីក្រ ។ ខ្ញុំទាមទាររដ្ឋាភិបាលសុំប្រគល់ដីនេះទៅឱ្យប្រជាពលរដ្ឋដែលជាកសិករដូចសេចក្តីថ្លែងការណ៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថាកសិករត្រូវការដី ហើយដីនេះកសិករបានគ្រប់គ្រង និងប្រើប្រាស់តាំងតែឆ្នាំ១៩៨២ រហូតដល់ ១៩៩២ គឺមានរយៈពេលជាងដប់ឆ្នាំ បើអនុលោមតាមច្បាប់ភូមិបាលដីនេះក្លាយជាកម្មសិទ្ធិស្របច្បាប់របស់អ្នកប្រើប្រាស់."* ។

*"ក្រុមហ៊ុនបានដាក់ពាក្យបណ្តឹងទៅតុលាការប្រឆាំងនឹងអ្នកភូមិ ហើយតុលាការបានកោះហៅតំណាងអ្នកភូមិ ។ ខ្ញុំជាតំណាងម្នាក់របស់អ្នកភូមិ រួមជាមួយតំណាងផ្សេងទៀតបានបង្ហាញខ្លួននៅតុលាការជាលើកដំបូង ហើយបួននិងប្រាំថ្ងៃបន្ទាប់មកតុលាការបានកោះហៅខ្ញុំម្តងទៀត... ។ ប៉ុន្តែខ្ញុំមានដីកាកោះហៅរបស់តុលាការមុនពេលខ្ញុំត្រូវបានចាប់ខ្លួន ។ មុនពេលខ្ញុំត្រូវបានចាប់ខ្លួន ខ្ញុំបានមកទីក្រុងភ្នំពេញ ដើម្បីជួបជាមួយអតីតព្រះមហាក្សត្រនៅព្រះបរមរាជវាំង... ខ្ញុំសូមអំពាវនាវពីសម្តេចតា និងសម្តេចយាយ ខ្ញុំកាន់ជាប់នូវដីការបស់តុលាការ ហើយទូលថ្វាយថា ខ្ញុំនឹងត្រូវចាប់ខ្លួននៅពេលណាខ្ញុំវិលត្រលប់ទៅវិញ..."*[២៤] ។

បីថ្ងៃក្រោយមក តាន់ ហេង បង្ហាញខ្លួនជាលើកទី២នៅតុលាការខេត្តកំពង់ចាម ។ តុលាការមិនបានចោទសួរគាត់ទាក់ទងទៅនឹងបទល្មើសដែលគាត់ត្រូវបានចោទប្រកាន់ឡើយ តែតុលាការប្រើប្រាស់អំណាចរបស់ខ្លួន

[24] លោក តាន់ ហេង ជាតំណាងម្នាក់ក្នុងចំណោមតំណាងជាច្រើននាក់ មកពីចំចារកៅស៊ូខុសគ្នា ដែលបានជួបជាមួយអតីតព្រះមហាក្សត្យនៅថ្ងៃទី៣១ ខែកក្កដា ហើយបានលើកការព្រួយបារម្ភណ៍អំពើបញ្ហាជាច្រើន ដែលគាត់ និងតំណាងផ្សេងទៀតកំពុងជួបប្រទេះ ។ អតីតព្រះមហាវរក្សត្រ មានព្រះបន្ទូលក្រោយការជួបជុំថា អ្នកចូលរួមប្រជុំជាមួយព្រះអង្គ មិនត្រូវដាក់ទណ្ឌកម្មឡើយ ។

ដើម្បីគំរាមគាត់ជំនួសក្រុមហ៊ុនចំការកៅស៊ូទៅវិញ ។

*"ក្រឡាបញ្ជីតុលាការ សួរខ្ញុំថា តើអ្នកយល់ព្រមឱ្យក្រុមហ៊ុនភ្ជួររាស់បំផ្លាញចោលដំណាំរបស់អ្នកដែរឬទេ ? ខ្ញុំឆ្លើយថា ខ្ញុំនឹងមិនអនុញ្ញាតឱ្យពួកគេបំផ្លាញផលដំណាំខ្ញុំឡើយ ។ ខ្ញុំបានខ្ចីលុយគេមកចំណាយលើការដាំសណ្តែកសៀងនេះ ។ ប្រសិនបើ ពួកគេភ្ជួររាស់លើដីនេះ វាហាក់ដូចជា សំលាប់ពួកខ្ញុំទាំងអស់គ្នា ដែលមានចំនួនជាង១០០គ្រួសារ ។" "ដូច្នេះ ពួកខ្ញុំមិនយល់ព្រមជាមួយក្រុមហ៊ុនទេ ?"។ ...ខ្ញុំចេញមកពីតុលាការ... នៅទីនោះមានមន្ត្រីនគរបាលបីទៅបួននាក់... ពួកគេចាប់ដាក់ខ្នោះដៃខ្ញុំ ហើយឃុំខ្ញុំកន្លែងនគរបាលមួយយប់។ នគរបាលបញ្ជាឱ្យខ្ញុំដោះសំលៀកបំពាក់ចេញ លើកលែងតែខោខ្លី ហើយឱ្យខ្ញុំនៅក្នុងទ្រុងមួយ ។ ព្រឹកបន្ទាប់មកនគរបាលឱ្យខ្ញុំសរសេររបាយការណ៏ ហើយបញ្ជូនខ្ញុំមកតុលាការខេត្តកំពង់ចាមសារជាថ្មីទៀត ។ តុលាការបានចោទខ្ញុំពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ.... ប៉ុន្តែ ខ្ញុំមិនបានបំផ្លាញអ្វីទាំងអស់ ខ្ញុំគ្រាន់កាប់ឆ្ការព្រៃលើដីដែលអ្នកភូមិទាំងអស់អះអាងថាជាដីរបស់ពួកគេ ហើយពួកគេធ្លាប់បានប្រើប្រាស់ដីនោះតាំងពីឆ្នាំ ១៩៨២ រហូតដល់ ១៩៩៧ ។*

*"ការចាប់ខ្លួននេះ គឺដើម្បីបង្ហាញអំពីការគំរាមកំហែងចំពោះប្រជាពលរដ្ឋ ដើម្បីបញ្ឈប់ពួកគេកុំបន្តការទាមទារធ្វើជាកម្មសិទ្ធិករលើដីនោះទៀត ។ តុលាការនិយាយថា ប្រសិនបើអ្នកស្រុកទាំងអស់ព្រមផ្តិតមេដៃលើឯកសារថា យល់ព្រមបញ្ឈប់ការទាមទារ តុលាការនឹងដោះលែងរូបខ្ញុំ " ។*

នៅចុងបញ្ចប់លោក តាន់ ហេង ត្រូវគេបង្ខំឱ្យបោះបង់ការទាមទារយកដីរបស់គាត់ ដើម្បីធានាចំពោះការដោះលែងរូបគាត់ចេញពីពន្ធនាគារ ។

*"ខ្ញុំជាប់ឃុំនៅក្នុងពន្ធនាគារអស់រយៈពេលប្រាំថ្ងៃ ឬប្រាំមួយថ្ងៃ ។ អ្នកភូមិប្រហែល ៦០ នាក់ បានតវ៉ាទាមទារសុំឱ្យដោះលែងរូបខ្ញុំ ហើយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងបណ្តាញសារព័ត៌មាន និងអង្គការមិនមែនរដ្ឋាភិបាលសិទ្ធិមនុស្សជួយគាំទ្រខ្ញុំ ។ គេដោះលែងខ្ញុំនៅម៉ោង ៥ រសៀលថ្ងៃច័ន្ទ ។ ពួកគេប្រាប់ខ្ញុំ... អ្នកត្រូវតែបញ្ឈប់ការទាមទារយកដីនោះ ហើយអ្នកនឹងត្រូវបានទទួលការដោះលែង អ្នកត្រូវតែប្រគល់ដីទៅឱ្យក្រុមហ៊ុនវិញ ។ ខ្ញុំគ្មានជម្រើសណាផ្សេងៗពីព្រោះខ្ញុំស្ថិតនៅក្នុងពន្ធនាគារ ។ ខ្ញុំនិយាយថា "បាទ" ខ្ញុំនឹងមិនទាមទារយកដីនោះទៀតទេ ប្រសិនបើអ្នកដោះលែងខ្ញុំ ។ ខ្ញុំយល់ព្រមដោយទាំងបង្ខំ... ខ្ញុំត្រូវការនាំកូនទៅសាលារៀន ខ្ញុំគ្មានជម្រើសទេ ។ គេព្រមានខ្ញុំថា ប្រសិនបើខ្ញុំនៅតែទាមទារយកដីនោះ ពួកគេនឹងមិនដោះលែងខ្ញុំឡើយ ។*

នៅពេលសរសេររបាយការណ៏សង្ខេបនេះ បទចោទប្រកាន់ស្តីពីការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈមកលើលោក តាន់ ហេង មិនទាន់លុបចោលនៅឡើយទេ ហើយគេអាចយកមកប្រើនៅពេលវេលាណាមួយក៏បានដែរ ដើម្បីនឹងគាបសង្កត់សហគមន៏តទៅទៀត ។

មានករណីចាប់ខ្លួន និងបំភិតបំភ័យស្រដៀងគ្នានេះកើតឡើងនៅទិសពាយ័ព្យនៃប្រទេសកម្ពុជា ដែលនៅទីនោះមានអតីតទាហានជាច្រើនបានទៅរស់នៅលើដីដែលមានទំនាស់កម្មសិទ្ធិ ។ ការគំរាមកំហែងដ៏ធ្ងន់ធ្ងរចំពោះអ្នក

ការពារសិទ្ធិមនុស្សនៅតែបន្តកើតមាននៅស្រុកបវេល ខេត្តបាត់ដំបង ដែលនៅទីនោះសកម្មជនសហគមន៍ដីធ្លីបីនាក់ជាប់ឃុំក្នុងពន្ធនាគាររង់ចាំសវនាការ ។

## សិក្សាករណី : ឈា នី និងទំនាស់ដីធ្លីនៅបវេល

ទំនាស់ដីធ្លីដែលបានអូសបន្លាយរយៈពេលវេលាយ៉ាងយូរ រវាងមន្ត្រីមូលដ្ឋាន និងប្រជាពលរដ្ឋចំនួន ៣.១៧០គ្រួសារ នៅស្រុកបវេល ខេត្តបាត់ដំបង បានលេចឮជាសាធារណៈនៅខែសីហា ឆ្នាំ២០០៦ ។ លោក ឈា នី ជាសកម្មជនមូលដ្ឋានត្រូវបានចាប់ខ្លួន ហើយបញ្ជូនមកពន្ធនាគារខេត្តបាត់ដំបង ។ ការចាប់ខ្លួនរបស់គាត់បង្កនូវភាពចលាចលក្នុងខណៈដែលអ្នកភូមិព្យាយាមការពាររូបគាត់ ហើយទទួលរងការវាយដំ អ្នកភូមិខ្លះទៀតត្រូវចាប់ខ្លួនដោយគេចោទពីសកម្មភាពរារាំង ។ ភរិយារបស់លោក ឈា នី គឺអ្នកស្រី អឿន សារីម ពន្យល់ពីមូលហេតុនានា ដូចខាងក្រោមនេះ:

*"ពួកគេមិនសប្បាយចិត្តជាមួយប្តីរបស់ខ្ញុំ ដោយសារគាត់ដឹងរឿងរ៉ាវរបស់មន្ត្រីជាន់ខ្ពស់នៅមូលដ្ឋានជាប់ពាក់ព័ន្ធជាមួយនឹងការលក់ដី ។ គាត់មានបំណងជួយដល់អ្នកដទៃ ដែលស្ថិតនៅក្នុងអតីតភាគីចលនាតស៊ូក្នុងសម័យសង្គ្រាម ហើយពួកទាំងនោះគ្មានដីសំរាប់ធ្វើស្រែចំការទេ បន្ទាប់ពីធ្វើសមាហរណកម្មរួចមក ។ ហេតុដូច្នេះ ពួកគេមករស់នៅលើដីដែលគ្មានអ្នកកាន់កាប់... ពួកគេគិតថាយើងគួរស្នើទៅរដ្ឋាភិបាលឱ្យផ្តល់ដីដែលជាកម្មសិទ្ធរបស់រដ្ឋទៅប្រជាពលរដ្ឋ ហើយសូមឱ្យពួកគេរស់នៅលើដីនេះស្របច្បាប់ផង ។ ពួកគេត្រូវការតំណាងដើម្បីជួយពួកគេបង្ហាញនូវការព្រួយបារម្ភណ៏ទៅអង្គការជាតិ និងអន្តរជាតិ ។ នេះជាបុព្វហេតុ ដែលនាំឱ្យ ឈា នី មានប្រជាប្រិយភាព ។ គាត់គ្រាន់តែជាមនុស្សសាមញ្ញម្នាក់ប៉ុណ្ណោះ តែគាត់មានចេតនាជួយ និងធ្វើសកម្មភាពជួសមុខឱ្យប្រជាពលរដ្ឋ "។*

ស្របពេលជាមួយគ្នានោះដែរ អ្នកស្រុកជឿជាក់ថា ដីនេះជាកម្មសិទ្ធិរបស់រដ្ឋ... ជាដីព្រៃ ហើយនៅទំនេរ... មានមន្ត្រីយោធាជាច្រើនបានអះអាងថា ពួកគេជាអ្នកគ្រប់គ្រងលើដី ហើយបានលក់ឱ្យឈ្មួញ ។ ប្រជាពលរដ្ឋពិភាក្សាបញ្ហានេះជាមួយលោក ឈា នី ហើយសុំឱ្យគាត់ជួយរៀបចំធ្វើញត្តិទៅរដ្ឋាភិបាលស្នើសុំប្រគល់ដីនេះឱ្យប្រជាពលរដ្ឋវិញ ដោយចាត់ថាជាដីសម្បទានសង្គមកិច្ច ។ នៅថ្ងៃទី១ ខែសីហា អ្នកភូមិញដែលនៅក្នុងតំបន់ពាក់ព័ន្ធបានមកជួបជុំគ្នានៅភូមិបឹងប្រាំ ឃុំអំពិលប្រាំដើម ក្នុងបំណងជួបក្រុមអធិការកិច្ចក្រសួងមហាផ្ទៃដែលកំពុងស៊ើបអង្កេតជុំវិញបញ្ហាទំនាស់ដីធ្លីនេះ ។ ផ្ទុយទៅវិញ មានកំលាំងនគរបាល យោធា និងកងរាជអាវុធហត្ថមកដល់ភូមិនេះហើយចាប់លោក ឈា នី ។

*"លោកអភិបាលស្រុកបញ្ជាឱ្យគេចាប់ប្តីរបស់ខ្ញុំ ដើម្បីគាបសង្កត់សហគមន៍ ។ អាជ្ញាធរមូលដ្ឋានមិនចង់ឱ្យមន្ត្រីជាន់ខ្ពស់មកមើលតំបន់ដែលអាជ្ញាមូលដ្ឋានជាប់ពាក់ព័ន្ធនិងបញ្ហាលក់ដីទេ ។ ប្រសិនបើក្រសួងមហាផ្ទៃដឹងថា ដីនេះជាដីព្រៃឬស្សី ពួកគេនឹងផ្តល់ដីនេះជូនប្រជាពលរដ្ឋដើម្បីធ្វើជាដីសម្បទានសង្គមកិច្ច... ហេតុដូច្នេះលោក ឈា នី ត្រូវគេចាប់ខ្លួនក្នុងគោលបំណងបិទបាំងដំណើរអធិការកិច្ចរបស់ក្រសួងមហាផ្ទៃ ។*

*"ក្នុងអំឡុងពេលចាប់ខ្លួន ពួកគេវាយដំលើប្រជាពលរដ្ឋ ខ្លួនខ្ញុំក៏ទទួលការវាយដំដែរ ។ ខ្ញុំព្យាយាម*

*បញ្ឈប់ពួកគេមិនឱ្យចាប់គាត់ ហើយស្នើសុំពួកគេឱ្យដោះស្រាយបញ្ហានេះតាមច្បាប់ ។ ខ្ញុំប្រាប់ពួកគេកុំឱ្យប្រើអំពើហិង្សាក្នុងផ្ទះរបស់ខ្ញុំ ហើយមិនត្រូវចាប់មនុស្សដោយគ្មានដីកាទេ បើធ្វើដូច្នេះ ពួកគេរំលោភបំពានលើសិទ្ធិពលរដ្ឋ ។ ពួកគេឆ្លើយថា គេមិនខ្វល់អ្វីទាំងអស់... គេប្រាប់ថា "គេត្រូវតែចាប់ខ្លួន ឈា នី " ហើយគេបន្ថែមទៀតថា "សំណាងហើយដោយគេមិនបានបាញ់សំលាប់គាត់" ។ អ្នកភូមិបានប្រើតុពីក្នុងផ្ទះលោក ឈា នី ដើម្បីការពារប្ដីខ្ញុំ និងរារាំងមិនឱ្យពួកគេចាប់គាត់... ប៉ុន្តែ ប្រជាពលរដ្ឋទទួលរងនូវការវាយនឹងបាតស្ព័យកាំភ្លើង និងទាត់ធាក់ ។ ពួកគេបាញ់ទៅលើបីដង ដើម្បីបំបែករនាំងការពាររបស់ប្រជាពលរដ្ឋ ។ ខ្ញុំស្ថិតនៅក្នុងផ្ទះជាមួយប្ដី និងប្អូនប្រុស.. ។ ប្អូនប្រុសស្រីរបស់ខ្ញុំត្រូវគេវាយនឹងស្នុកកាំភ្លើង ហើយគេវាយខ្ញុំចំដៃខាងឆ្វេងផងដែរ "។*

អ្នកផ្សេងទៀតដែលព្យាយាមការពារលោក ឈា នី គឺជាមិត្តភ័ក្តឈ្មោះ ឌឹម អាន :

*"ប្រជាពលរដ្ឋមានតែបាតដៃទទេ គ្មានដំបង ឬកាំបិត ប៉ុន្តែពួកគេចង់បញ្ឈប់ការចាប់ខ្លួន នៅពេលពួកគេមើលឃើញនូវអ្វីដែលអាជ្ញាធរកំពុងធ្វើនោះ ។ ខ្ញុំត្រូវគេចោទប្រកាន់ពីបទធ្វើអន្តរាគមន៍ ដើម្បីបញ្ឈប់ការចាប់ខ្លួនលោក ឈា នី ។ ពួកគេវាយខ្ញុំនឹងស្នុកកាំភ្លើង ហើយនឹងធាក់ខ្ញុំពីរជើង ហើយបន្ទាប់មកគេចាប់រូបខ្ញុំ ។ មានជនប្រដាប់ដោយអាវុធជាច្រើននាក់ឈរនៅខាងក្រៅផ្ទះ ។ ពួកគេភ្ជង់កាំភ្លើងមកខ្ញុំ ហើយបញ្ជាឱ្យខ្ញុំអង្គុយចុះ ។ ខ្ញុំធ្វើតាមបញ្ជាគេទាំងអស់ ។ ទាហានម្នាក់ប្រាប់ឱ្យខ្ញុំក្រោកឈរ ហើយបញ្ជាឱ្យខ្ញុំដើរទៅមុខដោយដាក់ដៃនៅលើក្បាល... ខ្ញុំដើរមកជិតអ្នកភូមិម្នាក់ឈ្មោះ ជ័យ ណើត ហើយពួកទាហានបញ្ជាឱ្យខ្ញុំអង្គុយក្បែរគាត់ ។ ពួកទាហានចងដៃរបស់យើងជាប់គ្នា ។ បន្ទាប់មកខ្ញុំឃើញគេចាប់ ឈា នី ដាក់ខ្នោះដៃ ហើយចងខ្សែរព័ទ្ធជុំវិញកដើម្បីអូសគាត់ ហើយគាត់ត្រូវបានគេវាយបណ្តើរពីក្រោយ ។ ពួកទាហានបណ្តើរពួកយើងបានចំងាយបីគីឡូម៉ែត្រពីភូមិ ហើយបន្ទាប់មកគេដឹកពួកយើងតាមរថយន្តមកស្រុកបវេល ។"*

*"នៅពេលពួកយើងមកដល់ទីស្នាក់ការស្រុក គេបញ្ជាពួកយើងចុះពីរថយន្ត ឈា នី និងខ្ញុំចងជាប់ជាមួយ ជ័យ ណើត ។ ពួកគេដាក់ខ្នោះយើង-លោកអាចមើលឃើញស្នាមខ្នោះដៃនេះ- ហើយប៉ូលីសនាំពួកយើងមកស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង នៅទីនោះអស់មួយថ្ងៃកន្លះ ។ នៅម៉ោង ៣ រសៀល ពួកគេបញ្ជូនខ្ញុំទៅកាន់បន្ទប់សួរចម្លើយ ហើយបញ្ជូនខ្ញុំមកមន្ទីរឃុំឃាំងនគរបាលវិញ ហើយបន្ទាប់មក ពួកគេដាក់ខ្នោះជើងខ្ញុំ ហើយបញ្ជូនខ្ញុំទៅតុលាការ។ តុលាការសួរចម្លើយខ្ញុំ ហើយខ្ញុំឆ្លើយ ។ ដំណើរការសួរចម្លើយមិនយុត្តិធម៌សំរាប់រូបខ្ញុំទាល់តែសោះ វាហាក់ដូចជាគេរៀបចំឡើង ដើម្បីគាបសង្កត់មកលើរូបខ្ញុំ ។*

*"បន្ទាប់ពីសួរចម្លើយ ពួកគេប្រាប់ខ្ញុំថា ខ្ញុំនឹងត្រូវដោះលែងជាបណ្តោះអាសន្ន ហើយប្រាប់ខ្ញុំថានៅពេលណាខ្ញុំត្រលប់ទៅផ្ទះវិញ ខ្ញុំមិនគួរស្នាក់នៅទីកន្លែងបច្ចុប្បន្ននេះទេ ត្រូវតែចាកចេញជាមួយប្រពន្ធនិងកូនពីភូមិបឹងប្រាំនេះ " ។*

លោក ឌឹម អាន និង ជ័យ ណើត ត្រូវបានដោះលែងនៅថ្ងៃទី២ ខែសីហា ជាបណ្តោះអាសន្ន តែលោក

ឈា នី ត្រូវគេបញ្ជូនទៅពន្ធនាគារខេត្ត ។ នៅថ្ងៃទី៤ ខែកញ្ញា សកម្មជនពីរនាក់ផ្សេងទៀត គឺ លោក ហែម ឡាក់ និង មូ សាប់ ត្រូវបានបញ្ជូនដាក់ពន្ធនាគារជាមួយលោក ឈា នី ក្រោមបទប្រកាន់ក្នុងករណីទំនាស់ដីធ្លីនៅបវេលនេះដែរ ។ អ្នកស្រី អឿន សារីម រៀបរាប់អំពីស្ថានភាពរបស់លោកតា មូ សាប់ ដែលមានអាយុ៧៨ឆ្នាំ ហើយកំពុងធ្លាក់ខ្លួនឈឺយ៉ាងខ្លាំងបន្ទាប់ពីកើតជំងឺស្ទឹក ។

*"គាត់ទទួលការគោរពពីអ្នកភូមិ ជាមនុស្សចាស់ទុំ... មានបទពិសោធន៍ និងចំណេះដឹង ហើយអាចផ្តល់ដំបូន្មានដល់មនុស្សវ័យក្មេង ។ គាត់ដឹងពីនីតិវិធីច្បាប់ ហើយជួយលើកទឹកចិត្តអ្នកភូមិឱ្យមានសាមគ្គីនៅក្នុងសហគមន៍ ។ គាត់ជំរុញសហគមន៍ឱ្យសរសេរលិខិតទៅរដ្ឋាភិបាល.. .គាត់តែងតែលើកសំណូមពរ ហើយមានគំនិតល្អៗ ហាមមិនឱ្យប្រើមធ្យោបាយហិង្សា ដែលអាចបង្កការប្រយុទ្ធនិងបង្ករឈាមគ្នា ។ ប្រសិនបើអ្នកភូមិចេះច្បាប់ និងនីតិវិធីច្បាប់ វានឹងធ្វើឱ្យអ្នកមានអំណាចនៅទីនេះមិនសប្បាយចិត្ត ។ ព្រោះគំនិតរបស់គាត់ផ្ទុយស្រឡះពីគំនិតរបស់ជនមានអំណាចនៅក្នុងតំបន់នេះ ដែលគេតែងតែចង់ប្រើអំពើខុសច្បាប់លើអ្នកភូមិដែលជាជនងាយទទួលរងគ្រោះ ។ ពួកគេមិនត្រូវការយល់ដឹងពីនីតិវិធីច្បាប់ឡើយ ដោយហេតុផលនេះហើយ បានជាពួកគេចោទប្រកាន់យ៉ាងធ្ងន់ធ្ងរមកលើរូប មូ សាប់ "* ។

មានដីកាស្វែងរកចាប់ខ្លួនចំនួនពីរនាក់ផ្សេងទៀត ដែលកំពុងសម្ងំលាក់ខ្លួន ។ អ្នកកស្រី អឿន សារីម រៀបរាប់អំពីការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ ដូចខាងក្រោមៈ

*"ខ្ញុំឆ្ងល់ណាស់ ថាហេតុអ្វីបានតុលាការចេញដីកាចាប់ខ្លួនតែមនុស្សប្រាំនាក់- មានមនុស្សច្រើនណាស់រស់នៅលើដីទំនាស់នេះ តើមនុស្សប្រាំនាក់ហ្នឹងធ្វើអ្វីខុស ? លោកអភិបាលស្រុកនិយាយថា ដីនេះជាទ្រព្យសម្បត្តិរបស់រដ្ឋ... ឈា នី រស់នៅលើដីរដ្ឋ... ចុះហេតុអ្វីបានជា ឈា នី ត្រូវរងចោទប្រកាន់ពីបទរំលោភបំពានទ្រព្យសម្បត្តិឯកជនទៅវិញ ?"*

ឈា នី ត្រូវបានចោទប្រកាន់ពីការរំលោភបំពានទ្រព្យសម្បត្តិឯកជន ក្រោមមាត្រា ២៥៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ដែលអាចផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ពីរឆ្នាំ និងពិន័យជាប្រាក់ចំនួន ២៥ លានរៀល ។ ទោះជាយ៉ាងណាក៏ដោយ មាត្រានេះអនុវត្តចំពោះតែករណីមានអំពើហិង្សា ដែលក្នុងករណី ឈា នី ពុំមានប្រព្រឹត្តអំពើហិង្សាទាល់តែសោះ ។ បទចោទប្រកាន់ជាប់ទាក់ទងជាមួយមាត្រា២៤៨ នៃច្បាប់ភូមិបាលជាមាត្រាទូទៅ ដែលអនុវត្តចំពោះការកាន់កាប់ដីដោយអហិង្សា ប៉ុន្តែ ពុំមានចែងពីការដាក់ទណ្ឌកម្មទេ ។ ពុំមានមូលដ្ឋានច្បាប់ចំពោះការភ្ជាប់ទំនាក់ទំនងករណីបែបនេះទេ ។ ប៉ុន្តែ ល្បិចកលដូចគ្នានេះត្រូវបានគេសង្កេតឃើញប្រើជាច្រើនកន្លែងដើម្បីផ្តន្ទាទោសបើខុសច្បាប់លើសកម្មជនការពារដីធ្លីជាច្រើននាក់ ។

ឈា នី ទទួលរងនូវការចោទប្រកាន់បន្ថែមពីបទរំលោភលើសិទ្ធិបុគ្គលក្រោមមាត្រា៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ប្រាំឆ្នាំ ។ មាត្រានេះអនុវត្តចំពោះតែ "ភ្នាក់ងាររដ្ឋមានជាអាទិ៍ៈ នគរបាល ឬយោធា ដែលរំលោភលើសិទ្ធិបុគ្គលនិងលំនៅស្ថាន" ហើយក៏អនុវត្តចំពោះការប្រព្រឹត្តដូចជា ការធ្វើទារុណកម្ម ការចាប់ឬឃុំខ្លួនខុសច្បាប់ និងការឆែកឆេរដោយខុសច្បាប់ ដែលលោក ឈា នី មិនបាន

ប្រព្រឹត្តទង្វើដូចពោលទាំងអស់នេះទេ ។ ឈា នី ត្រូវបានចោទប្រកាន់ថាជាអតីតកងទ័ព ហើយឈ្មោះរបស់គាត់នៅតែមាននៅក្នុងបញ្ជីឈ្មោះកងទ័ព។ គួរឱ្យរន្ធត់ណាស់ ដែលគេមិនបានយកច្បាប់មកផ្តន្ទាទោសមកលើមន្ត្រីរបស់រដ្ឋ ប៉ុន្តែគេបែរជាយកច្បាប់មកផ្តន្ទាទោសអ្នកការពារសិទ្ធិមនុស្សទៅវិញ ដែលរងគ្រោះដោយការគំរាមកំហែងពីមន្ត្រីមានអំណាច។

នៅថ្ងៃទី១៣ ខែវិច្ឆិកា សាលាឧទ្ធរណ៍បើសវនាការលើបណ្តឹងឧទ្ធរណ៍របស់លោក ឈា នី ដើម្បីសុំនៅក្រៅឃុំបណ្តោះអាសន្ន ។ មានការសំរេចមួយដែលគ្មានន័យ សាលាឧទ្ធរណ៍បានរកឃើញថាៈ អាចឱ្យលោក ឈា នី នៅក្រៅឃុំបាន លុះត្រាតែបទចោទប្រកាន់ជាការរំលោភលើសិទ្ធិបុគ្គល ប៉ុន្តែបើបទចោទប្រកាន់បំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជនត្រូវបានបដិសេធ ។ នៅពេលសរសេរឯកសារនេះលោក ឈា នី, ហែម ឡាក់ និង មូ សាប់ កំពុងស្ថិតនៅក្នុងពន្ធនាគារនៅឡើយ ។

ខេត្តបន្ទាយមានជ័យ ប្រហែលជាមានឧបទ្ទវហេតុនៃការគំរាមកំហែងចំពោះសកម្មជនដីធ្លីខ្ពស់បំផុត ។ នៅខែមិថុនា តំណាងសហគមន៍នៅឃុំប៉ោយប៉ែតចំនួនបីនាក់ ដែលបានរៀបចំញត្តិរបស់អ្នកភូមិដែលភ័យខ្លាចនឹងការបាត់បង់ដីធ្លីត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យអ្នកដទៃប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។ បទចោទប្រកាន់នេះទាក់ទងនឹងបាតុកម្មមួយ ដែលកើតឡើងកាលពីបីខែកន្លងទៅ ។ គេពុំមានភស្តុតាងណាមួយបញ្ជាក់ថា មានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះទេ ។ នៅខែមីនា អ្នកភូមិចំនួនបីនាក់ត្រូវបានគេគំរាម ហើយម្នាក់ត្រូវបានឃុំខ្លួនដោយមន្ត្រីយោធា បន្ទាប់ពីគាត់ធ្វើជាតំណាងឱ្យប្រជាពលរដ្ឋចំនួន ២៩៥គ្រួសារ នៅក្នុងរឿងទំនាស់ដីធ្លី នៅស្រុកម៉ាឡៃ ។ ក្នុងខែដដែលនេះនៅស្រុកសំរោង តំណាងសហគមន៍មួយនាក់ទៀតត្រូវគេចាប់ដាក់ពន្ធនាគារ បន្ទាប់ពីគាត់ធ្វើជាតំណាងឱ្យប្រជាពលរដ្ឋចំនួន១២៨គ្រួសារនៅក្នុងរឿងទំនាស់ដីធ្លីជាមួយយោធា ។ គាត់ត្រូវបានដោះលែងបន្ទាប់ពីមានមហាបាតុកម្មនៅពីមុខតុលាការ ប៉ុន្តែ បទចោទប្រកាន់ទៅលើរូបគាត់មិនទាន់ត្រូវបានលុបចោលទេ ។

អាជ្ញាធរអាចប្តឹងអ្នកតស៊ូមតិរបស់សហគមន៍ ប៉ុន្តែអាជ្ញាធរពុំមានឆន្ទះប្តឹងជនល្មើសដែលបានគំរាមកំហែង ឬវាយប្រហារចំពោះអ្នកកាពារសិទ្ធិមនុស្សឡើយ ។ មានករណីមួយ ក្នុងនោះអ្នកភូមិដែលជាជនពិការម្នាក់ត្រូវគេវាយដំយ៉ាងដំណំ ហើយគំរាមចាប់ខ្លួន បន្ទាប់ពីគាត់ព្យាយាមលើកឡើងពីការព្រួយបារម្ភណ៍របស់ប្រជាពលរដ្ឋអំពីការដកហូតម៉ាស៊ីនប៉ូមទឹកចេញពីភូមិរបស់ពួកគេ នៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

## ករណីសិក្សា ៖ ឈឿន រិទ្ធី អ្នកការពារសិទ្ធិមនុស្សដោយស្ម័គ្រចិត្ត

នៅខែមករា អ្នកភូមិជាច្រើននាក់នៅភូមិរស្មីសាមគ្គី ឃុំនិមិត្ត ស្រុកអូរជ្រៅព្រួយបារម្ភណ៍អំពីកង្វះខាតទឹកប្រើប្រាស់ ។ ដោយមានជំនួយពីបុរសមូលដ្ឋានម្នាក់ ក្រុមហ៊ុនមួយបានបូមទឹកចេញពីស្រះទឹករួម ដែលអ្នកភូមិទាំងអស់ក៏ដូចជាអ្នកស្រុកពីរភូមិនៅក្បែរនោះប្រើប្រាស់ដើម្បីស្រោចស្រព្វដំណាំ ។ ក្នុងខណៈដែលបរិមាណទឹកក្នុងស្រះផ្តើមស្រកចុះ អ្នកភូមិមិនដឹងជាទៅពឹងពាក់នរណា ដើម្បីបញ្ឈប់សកម្មភាពក្រុមហ៊ុនបូមទឹកចេញពីស្រះ ។ អ្នកភូមិម្នាក់ស្វែងរកជំនួយពីអ្នកភូមិដូចគ្នា គាត់នោះឈ្មោះ ឈឿន រិទ្ធី អាយុ៤១ឆ្នាំ ជាអតីតកងទ័ព ដែលបានពិកាជើងម្ខាងដោយសារគ្រាប់មីនក្នុងសង្គ្រាមស៊ីវិលកម្ពុជា ហើយឥឡូវនេះប្រកបរបរស៊ីឈ្នួល

ដោះគ្រាប់មីននៅក្នុងតំបន់នេះ ។

*"ខ្ញុំមិនបានជួយអ្នកស្រុកច្រើនទេកាលពីពេលមុន ។ ខ្ញុំគ្រាន់តែជួយពួកគេឱ្យមានលទ្ធភាពធ្វើកសិដ្ឋាន ពីព្រោះដីនៅនេះត្រូវការដោះគ្រាប់មីន ដូច្នេះខ្ញុំដោះគ្រាប់មីនឱ្យពួកគេក្នុងតំលៃថោក ។ ខ្ញុំជួយគេដោះមីន និងភ្ជួររាស់ដី...ដូច្នេះប្រជាពលរដ្ឋមកប្រាប់ខ្ញុំអំពីបញ្ហាទឹក ពួកគេនិយាយថា "សូមលោកមេត្តាជួយបញ្ឈប់ក្រុមហ៊ុនបូមទឹកពីស្រះ ព្រោះទឹកស្រះនេះយើងត្រូវការប្រើប្រាស់ បើមិនអញ្ចឹងទេ យើងប្រហែលជាគ្មានទឹកប្រើប្រាស់ទេ... ប្រហែលជាខ្ញុំជាមនុស្សដែលពួកគេទុកចិត្ត ។ ពួកគេទុកចិត្តខ្ញុំ ដោយសារខ្ញុំជាមនុស្សស្មោះត្រង់ មិនដែលបោកប្រាស់នរណា ឬទ្រព្យសម្បត្តិរបស់សហគមន៍ " ។*

រីទ្ធី សំរេចចិត្តទៅជជែកជាមួយបុរសមូលដ្ឋានឈ្មោះ គួរ ខេង ដែលជាតំណាងរបស់ក្រុមហ៊ុនបូមទឹក ដែលជាប់ពាក់ព័ន្ធទៅនឹងការបូមទឹកចេញពីស្រះ ។

*ខ្ញុំគ្រាន់តែចង់សួរគាត់ "សួស្តី ខេង ហេតុអ្វីបានជាបូមទឹកស្រះ ? ខ្ញុំទើបតែនិយាយបានពីរបីម៉ាត់... ពេលនោះគាត់លោតចុះពីលើផ្ទះ ច្រានម៉ូតូរបស់ខ្ញុំដួល ហើយវាយខ្ញុំ ។ គាត់បានវាយខ្ញុំជាច្រើនដង" ។*

បន្ទាប់ពីការទទួលរងនូវការវាយដំលើមុខជាច្រើនដៃ ភ្នែកឆ្វេងរបស់គាត់ហើមប៉ោងបើកលែងរួច ។ រីទ្ធី រត់ទៅប្តឹងមេភូមិ តែមេភូមិមិនបានព្យាយាមជួយគាត់ទេ ហើយគំរាមចាប់គាត់ទៀតផង ប្រសិនបើគាត់ចង់ប្តឹង គួរ ខេង ។ រីទ្ធី ប្តឹង គួរ ខេង ទៅតុលាការពីបទបង្ករបួសស្នាម ប៉ុន្តែតុលាការមិនបានចោទប្រកាន់ ខេង ទេ ។ មន្ត្រីតុលាការប្រាប់ រីទ្ធី ថាពុំមានភស្តុតាងអំពីការវាយដំឡើយ ទោះបីជាមានរូបថតបង្ហាញពីរបួសយ៉ាងធ្ងន់ធ្ងរលើផ្ទៃមុខរបស់ រិទ្ធី ក៏ដោយ ។ រីទ្ធី និងអ្នកភូមិដទៃទៀតជឿជាក់ថា គួរ ខេង ត្រូវបានគេការពារ ពីព្រោះគាត់ជាសាច់ញាតិរបស់លោកអតីតអភិបាលខេត្តបន្ទាយមានជ័យ ។

ជាយថាហេតុ ក្រុមហ៊ុនបញ្ឈប់ការបូមទឹកពីស្រះ ។ ប៉ុន្តែបើបញ្ហាបែបនេះនឹងកើតម្តងទៀត រីទ្ធី មិនចង់ឱ្យបទពិសោធន៍ដ៏អាក្រក់នេះកើតចំពោះគាត់ម្តងទៀតឡើយ ក្នុងនាមជាអ្នកការពារសិទ្ធិមនុស្សដោយស្ម័គ្រចិត្ត ។

*"ប្រសិនបើពួកគេបូមទឹកម្តងទៀត ខ្ញុំមិនជំទាស់ទេ- វាលំបាកណាស់សំរាប់រូបខ្ញុំ ។ យើងចង់បានសមភាព យើងចង់ឱ្យគេរាល់គ្នាយកចិត្តទុកដាក់ពីផលប្រយោជន៍រួម... ប៉ុន្តែនៅពេលខ្ញុំធ្វើអ្វីមួយជាប្រយោជន៍សម្ហភាព បែរជាខ្ញុំជួបនូវបញ្ហាយ៉ាងច្រើនទៅវិញ ដូច្នេះ ខ្ញុំមិនចង់ធ្វើម្តងទៀតទេ ។ បញ្ហាលំបាកនៅត្រង់ថា យើងត្រូវការច្បាប់ ។ ប៉ុន្តែ ច្បាប់មិនអាចជួយយើងស្វែងរកយុត្តិធម៌ឱ្យឃើញថានរណាជាអ្នកខុស និងនរណាជាអ្នកត្រូវ ..."* ។

អ្នកការពារសិទ្ធិមនុស្សទូទាំងប្រទេសកម្ពុជាជួបអំពើហិង្សា ឬការគំរាមកំហែងស្រដៀងគ្នា នៅពេលព្យាយាមធ្វើសកម្មភាពជួសឱ្យសហគមន៍របស់ពួកគេ ។ មានអ្នកខ្លះរួញរា ប៉ុន្តែមានអ្នកខ្លះមិនខ្លាចប្រឈមនឹងការគំរាមកំហែង និងការគាបសង្កត់ ហើយសំរេចចិត្តតស៊ូទៅមុខទៀត ក្នុងនោះមានស្ត្រីវ័យក្មេងម្នាក់នៅខេត្តសៀមរាប ។

## ករណីសិក្សា : កញ្ញា សូ សុជាតិ និងសហគមន៍ភូមិវត្តបូព៌ ខេត្តសៀមរាប

សូ សុជាតិ មានអាយុ២៣ឆ្នាំ រស់នៅភូមិវត្តបូពិ ខេត្តសៀមរាប ។ មានប្រជាពលរដ្ឋចំនួន ៤៩ គ្រួសារមានទំនាស់ដីធ្លីដែលបានអូសបន្លាយរយៈពេលយូរឆ្នាំកន្លងមកជាមួយចៅអធិការវត្តបូពិ ។ ប្រជាពលរដ្ឋអះអាងថាបានរស់នៅលើដីនេះរាប់ទសវត្សរ៏មកហើយ ហើយមានប័ណ្ណសំគាល់កម្មសិទ្ធិដែលទទួលបានក្នុងទសវត្សរ៏ទី៩០ ទៀតផង តែចៅអធិការវត្តមានឯកសារចេញនៅឆ្នាំ១៩៩៥ ដើម្បីទាមទារដីពីអ្នកភូមិ ។ សុជាតិ ជាអ្នកតំណាងមានវ័យក្មេងជាងគេក្នុងចំណោមអ្នកតំណាងទាំងបួននាក់ ដែលសហគមន៏បានតែងតាំង បាននិយាយពន្យល់ថាៈ

> *"យើងមិនមែនជាប្រជាពលរដ្ឋដែលទើបមករស់នៅទីនេះមួយឆ្នាំឬពីរឆ្នាំទេ ។ យើងរស់នៅទីនេះតាំងពីឆ្នាំ១៩៧៩ ។ ខ្លួនខ្ញុំផ្ទាល់កើតនៅទីនេះ ។ ខ្ញុំធុញទ្រាន់នឹងបញ្ហានេះណាស់ ខ្ញុំកើតនៅលើដីនេះ ហើយពួកគេចង់បណ្ដេញយើងចេញពីដី តែយើងគ្មានដីណាផ្សេងសំរាប់រស់នៅទេ លើកតែដីមួយកន្លែងនេះ...*
>
> *"ប្រជាពលរដ្ឋទាំងអស់គ្នានៅកន្លែងនេះមានការភ័យខ្លាច ។ ពួកគេទទួលរងនូវការគាបសង្កត់ និងគំរាមកំហែងពីសំណាក់អាជ្ញាធរមូលដ្ឋាន ។ នេះជាមូលហេតុជំរុញចិត្តខ្ញុំឱ្យក្រោកឈរឡើងដើម្បីតស៊ូមតិ និងធ្វើជាតំណាងឱ្យប្រជាពលរដ្ឋ ពីព្រោះខ្ញុំមានចំណេះដឹងផ្នែកច្បាប់ខ្លះដែលរៀនតាមរយៈការស្ដាប់វិទ្យុ និងមើលទូរទស្សន៏ ហេតុដូច្នេះ ពួកគេមិនអាចគាបសង្កត់ខ្ញុំបានឡើយ... ខ្ញុំតវ៉ា និងជជែកជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីមកពីស្ថាប័នផ្សេងៗ..."*

សុជាតិ និងតំណាងដទៃទៀតរៀបចំញត្តិ ដោយសរសេរលិខិតអំពាវនាវទៅស្ថាប័នរដ្ឋ ដើម្បីជំទាស់នឹងការទាមទាររបស់ចៅអធិការវត្តយកដីរបស់ពួកគេ ។ នៅដើមខែឧសភា បន្ទាប់ពីមានការគំរាមបណ្ដេញជាច្រើនលើកច្រើនសារពីសំណាក់អាជ្ញាធរមូលដ្ឋាន អ្នកភូមិសំរេចចិត្តប្រមូលផ្តុំនៅមុខវត្ត ហើយស្នើទៅអាជ្ញាធរមូលដ្ឋានឱ្យចូលរួមដើម្បីចរចាជាមួយគ្នា ។ ពួកគេប្រមូលផ្តុំគ្នានៅក្រៅវត្តប្រកបដោយសន្តិភាពអស់រយៈពេលពីរថ្ងៃ ដើម្បីរង់ចាំមន្ត្រីឃុំ-ស្រុកនិងខេត្តចូលរួមចរចាជាមួយគ្នា ។ តែគ្មាននរណាគេមកចូលរួមចរចារឡើយ ។ ការរង់ចាំរហូតដល់បីថ្ងៃ គឺចំថ្ងៃទី៣ ខែឧសភា នគរបាលប្រមាណ ៤០ នាក់ ប្រដាប់ដោយអាវុធគ្រប់ដៃបានមកដល់ :

> *"អភិបាលរងស្រុកមកជាមួយពួកនគរបាលដែរ ។ ដោយសារតែខ្ញុំជាតំណាងឱ្យអ្នកភូមិ ខ្ញុំចេញមុខចរចាជាមួយលោកអភិបាលរងស្រុកអំពីរឿងទំនាស់ដីធ្លីនេះ ។ ក៏ប៉ុន្តែពួកគេ មិនដែលស្ដាប់ការពន្យល់របស់ពួកយើង ទេ-ផ្ទុយទៅវិញ នគរបាលបានប្រើអំពើហិង្សាមកលើពួកយើង... ពួកយើងមានការសោកស្ដាយណាស់នៅពេលឃើញនគរបាលវាយដំ ហើយប្រើដំបងឆក់ពួកយើង-ពួកគេទាត់ធាក់និងប្រើដំបងឆក់ទៅលើមនុស្សអាយុ៥០ឆ្នាំឬ៦០ឆ្នាំ ។ ខ្ញុំព្យាយាមជួយមនុស្សសន្លប់បាត់ស្មារតី ប៉ុន្តែ ខ្លួនខ្ញុំក៏ត្រូវគេវាយឱ្យរបួសជើងដែរ ។ ខ្ញុំប្រាប់នគរបាលថា ប្រសិនបើអ្នកឯងក្លាហាន ចាប់ខ្ញុំមក កុំវាយធ្វើបាបប្រជាពលរដ្ឋរបស់ខ្ញុំ ហើយបន្ទាប់មកគេដាក់ខ្នោះដៃខ្ញុំ ហើយបណ្ដើរខ្ញុំចេញទៅ "* ។

សុជាតិត្រូវបានគេគ្រាចូលទៅក្នុងវត្ត ដោយសារជើងរបស់នាងមិនអាចដើររួច ព្រោះរងពីការវាយដំ ។ នាងត្រូវបានគេចាប់ពីក្នុងវត្ត ហើយនាំខ្លួននាងតាមម៉ូតូប៉ូលីសទៅឃុំឃាំង ក្នុងខណៈពេលចៅធិការវត្តបានឈរមើល ។

*"ប៉ូលីសឃុំម្នាក់ប្រាប់ខ្ញុំឱ្យផ្តិតមេដៃលើក្រដាសមួយសន្លឹក ដោយសរសេរថា ខ្ញុំបានបំផ្លិចបំផ្លាញសម្បត្តិទ្រព្យអ្នកដទៃ ។ ខ្ញុំបានបដិសេធ ព្រោះខ្ញុំមិនបានប្រព្រឹត្តដូច្នេះទេ... គាត់នៅតែបញ្ជាឱ្យខ្ញុំផ្តិតមេដៃ ខ្ញុំនៅតែជំទាស់ ។ ខ្ញុំបាននិយាយថា "លោកនិយាយថា ខ្ញុំជាអ្នកបំផ្លិចបំផ្លាញ ដូច្នេះលោកផ្តិតមេដៃខ្លួនឯងទៅ-ខ្ញុំមិនផ្តិតមេដៃអ្វីទាំងអស់" ។*

សុជាតិជាប់ក្នុងពន្ធនាគារមួយយប់ ត្រូវបានដោះលែងនៅថ្ងៃបន្ទាប់ពីមានការចរចារវាងអ្នកភូមិរបស់នាងជាមួយអាជ្ញាធរ និងមានអន្តរាគមន៍ពីអង្គការមិនមែនរដ្ឋាភិបាល ។ ប៉ុន្តែនាងត្រូវបានចោទប្រកាន់ដោយតុលាការពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ ហើយការចោទប្រកាន់នេះនៅមិនទាន់បញ្ឈប់នៅឡើយ ។ ចាប់តាំងពីថ្ងៃចាប់ ខ្លួនមក សុជាតិ និងតំណាងរបស់សហគមន៍ដទៃទៀតបានបន្តកិច្ចខិតខំប្រឹងប្រែងដោយបញ្ជូនរឿងក្តីរបស់ពួកគេ ទៅមន្ត្រីសំខាន់ៗនៅភ្នំពេញ រួមមានលោកនាយករដ្ឋមន្ត្រីផងដែរ ។ ចៅអធិការវត្តដែលគាំទ្រដោយមន្ត្រីមានអំណាច ដូចជា សម្តេចព្រះសង្ឃរាជ ទេព វង្ស បន្តបណ្តេញប្រជាពលរដ្ឋពីដីលំនៅដ្ឋានរបស់ពួកគេដោយពុំមានដំណោះស្រាយឡើយ ហើយសុជាតិក៏មិនបោះបង់ការតស៊ូរបស់នាងដែរ ។

*ខ្ញុំត្រូវតែខ្លាំង... ខ្ញុំប្រាប់ប្រជាពលរដ្ឋថា យើងទាំងអស់គ្នាត្រូវតែខ្លាំង មិនទន់ខ្សោយឡើយ...យើងទាំងគ្នាត្រូវតែក្រោកឡើង ហើយតស៊ូ ពីព្រោះយើងមិនបានលួចដីនរណាម្នាក់ឡើយ យើងរស់នៅលើដីស្របច្បាប់-មេភូមិ-ឃុំ ព្រមទាំងអភិបាលស្រុក និងខេត្តក៏បានជ្រាប ហើយទទួលស្គាល់យើងបានរស់នៅទីនេះជាច្រើនឆ្នាំហើយ ។ ទោះបី ខ្ញុំធ្លាប់ជាប់ពន្ធនាគារ ខ្ញុំនៅតែសប្បាយចិត្ត ពីព្រោះឃើញប្រជាពលរដ្ឋក្រោកឈរហើយតស៊ូ-ប្រកៀកដៃគ្នា ស្មារទល់ស្មារ-បង្ហាញពីភាពខ្លាំង... យើងចង់ផ្សព្វផ្សាយរឿងក្តីរបស់យើងឱ្យសាធារណៈជនបានដឹង ហើយក៏ចង់ឱ្យអាជ្ញាធរស្រុក ខេត្តដឹងថា យើងមិនទន់ខ្សោយទេ-យើងទាមទារសិទ្ធិរស់នៅ " ។*

# IV. អនុសាសន៍

ដោយមើលឃើញកើនឡើងនៃការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិនៅកម្ពុជាកើនឡើង អង្គការលីកាដូជឿជាក់ថា រាជរដ្ឋាភិបាលកម្ពុជាគួរតែចាត់វិធានការដូចខាងក្រោម ហើយសហគមន៍អន្តរជាតិត្រូវទទូចសុំទៅរដ្ឋាភិបាលឱ្យអនុវត្តនូវវិធានការទាំងនេះ :

- ចាត់វិធានការជាបន្ទាន់ដើម្បីស៊ើបអង្កេត និងកាត់ទោសជនល្មើសដែលត្រូវចោទប្រកាន់ពីបទប្រព្រឹត្តអំពើហិង្សា និងការបំភិតបំភ័យចំពោះអ្នកការពារសិទ្ធិមនុស្ស ។
- គោរពឱ្យបានពេញលេញនូវការប្តេជ្ញាចិត្តមិនដាក់ទណ្ឌកម្មបទល្មើសព្រហ្មទណ្ឌចំពោះបទបរិហារកេរ្តិ៍ និងការផ្សព្វផ្សាយព័ត៌មានមិនពិត ។
- ផ្អាករាល់ការប៉ុនប៉ងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ឬ "ច្បាប់អង្គការមិនមែនរដ្ឋាភិបាល" រហូតដល់ឯករាជ្យភាព និងសមត្ថភាពរបស់ប្រព័ន្ធតុលាការកម្ពុជាត្រូវបានធានា ។
- តម្រូវឱ្យអាជ្ញាធរគ្រប់ជាន់ថ្នាក់បញ្ឈប់ការរំខានដល់សកម្មភាពរបស់អង្គការសិទ្ធិមនុស្សស្របច្បាប់
- គោរពឱ្យបានពេញលេញនូវកាតព្វកិច្ចរបស់រដ្ឋាភិបាល ក្រោមអនុសញ្ញាឆ្នាំ១៩៥១ ស្តីពីជនភៀសខ្លួន និងបញ្ឈប់រាល់ការគំរាមកំហែង យាយី និងបំភិតបំភ័យដល់អ្នកដែលជួយជនស្វែងរកសិទ្ធិជ្រកកោន ។
- ធានាការអនុវត្តន៍គោលការណ៍មិនរើសអើង ដែលបទញ្ញត្តិនៅក្នុងច្បាប់ការងារ និងតំណាងសហជីពកម្មករមិនត្រូវបានគេហាមឃាត់ក្នុងការជ្រើសរើសចូលបំរើការងារ ឬយាយីដោយសារពាក់ព័ន្ធជាមួយសកម្មភាពរបស់សហជីព ។
- ធានាថាតុលាការ ត្រូវអនុវត្តច្បាប់ភូមិបាល និងច្បាប់ស្តីពីធនធានធម្មជាតិឱ្យបានត្រឹមត្រូវ សុក្រិត្យ និងម៉ឺងម៉ាត់ ។
- ធានាថារាល់ភាគីដែលពាក់ព័ន្ធជាមួយវិវាទដីធ្លី និងធនធានធម្មជាតិ មិនត្រូវចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ នៅពេលវិវាទនេះមិនទាន់ដោះស្រាយចប់សព្វគ្រប់ ។
- តម្រូវឱ្យមានសវនការក្នុងរយៈពេលប្រាំមួយខែ គិតពីថ្ងៃចាប់ខ្លួនជនសង្ស័យអនុលោមទៅតាមច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជា ឬលុបចោលបទចោទប្រកាន់ ហើយសូមយកចិត្តទុកដាក់ជាពិសេសចំពោះការរំលោភលើនីតិវិធីនេះនៃករណីពាក់ព័ន្ធជាមួយសកម្មជនការងារ និងបញ្ហាដីធ្លី ។

# ឧបសម្ព័ន្ធទី ១ : តារាងឧបទ្ទវហេតុពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ពីខែ មករា ដល់ ខែតុលា ឆ្នាំ២០០៦

| ឧបទ្ទវហេតុពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាពីខែមករា ដល់ ខែតុលា ឆ្នាំ ២០០៦ | |
|---|---|
| **ថ្ងៃទី ៤ ខែមករា** | **ការឃុំខ្លួនសកម្មជនសិទ្ធិមនុស្សដ៏សំខាន់ម្នាក់នៅភ្នំពេញ**[២៥]<br>• លោក ប៉ា ងួនទៀង នាយកវិទ្យុផ្សាយសំលេងរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវបានចាប់ខ្លួននៅខេត្តស្ទឹងត្រែង ជិតព្រំដែនប្រទេសឡាវក្នុងបទជាប់ពាក់ព័ន្ធជាមួយការបង្ហាញបដាមួយផ្ទាំងនៅទិវាអន្តរជាតិសិទ្ធិមនុស្ស ១០ ធ្នូ ឆ្នាំ២០០៥ ។<br>• នីត្យានុកូលភាពនៃការចាប់ និងឃុំខ្លួន ស្ថិតនៅជាសំណួរនៅឡើយដោយសារតែគេពុំមានដីកាចាប់ខ្លួន ហើយមានសេចក្តីរាយការណ៍ថាការចាប់ខ្លួនលោក ប៉ា ងួនទៀង ធ្វើតាមការបញ្ជាពីក្រសួងមហាផ្ទៃ ។<br>• លោក ទៀង ត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ នៅថ្ងៃទី៥ ខែមករា។ គាត់ត្រូវឃុំខ្លួននៅពន្ធនាគារព្រៃស ។ នៅទីនោះគាត់ទៅជួបជុំជាមួយអ្នកការពារសិទ្ធិមនុស្សដូចគ្នា មានលោក កឹម សុខា នាយកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងលោក យ៉េង វីរៈ ប្រធានមជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ ។ |
| **នៅថ្ងៃទី ៥ ខែមករា** | **សកម្មជនដីធ្លីជនជាតិភាគតិចពីររូប ត្រូវគេឃុំខ្លួននៅខេត្តរតនគិរី**[២៦]<br>• លោក ចាន់ ពូ និង កែវ រី ត្រូវចោទប្រកាន់ពីបទរំលោភបំពានទ្រព្យសម្បត្តិឯកជនក្នុងរឿងវិវាទដីធ្លីនៅឃុំឯកភាព ស្រុកអូរជុំ ។<br>• មេធាវីរបស់ពួកគេកត់សំគាល់ថា បុរសទាំងពីរនាក់នេះត្រូវបានគេនាំពីបន្ទប់សួរចម្លើយនៅតុលាការខេត្តរតនគិរីទៅពន្ធនាគារដោយគ្មានដីកាបង្គាប់ឱ្យឃុំខ្លួន ដែលត្រូវចុះហត្ថលេខា និងបោះត្រាដោយព្រះរាជអាជ្ញា ។<br>• មន្ត្រីតុលាការស្នើអ្នកភូមិឱ្យចុះហត្ថលេខាលើឯកសារមួយ ដោយសន្យាថានឹងបោះបង់ដីដែលពួកគេបានបង្កបង្កើនផលជាច្រើនឆ្នាំហើយ ដែលទាមទារដោយអ្នកជំនួញម្នាក់ឈ្មោះ ឃិត សុខៃ ។ មេធាវីរបស់អ្នកភូមិអះអាងថា ឃិត សុខៃ មិនបានបំពេញកាតព្វកិច្ចផ្លូវច្បាប់ដើម្បីថែរក្សាដីនេះទេ បន្ទាប់ពីគាត់ទទួលបានដីជាសម្បទានកសិកម្មពីរដ្ឋនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ហេតុដូច្នេះ ដីនេះត្រូវបង្វែរទៅរដ្ឋវិញ ។<br>• កាលពីសប្តាហ៍មុន សកម្មជនទី៣នៅក្នុងរឿងទំនាស់ដីធ្លីដដែល ត្រូវគេវាយនឹងគល់ឈើយ៉ាងដំណំ ។<br>• បុរសពីរនាក់ ត្រូវបានដោះលែងពីពន្ធនាគារនៅថ្ងៃទី១៧ ខែមីនា ឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ប៉ុន្តែបទចោទប្រកាន់មិនទាន់បានបញ្ចប់នៅឡើយទេ ហើយមនុស្សប្រាំមួយនាក់ |

[25] ឯកសារសង្ខេបរបស់លីកាដូ :ការគំរាមកំហែង ចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ២០០៥ ចុះខែមិថុនា ២០០៦

[26] របាយការណ៍តាមដានដែលមិនផ្សព្វផ្សាយរបស់លីកាដូ ចុះថ្ងៃទី៦ ខែមករា ២០០៦ ។ សូមអានអត្ថបទរបស់លោក Phan Ana មានចំណងជើងថា : អ្នកភូមិនៅខេត្តរតនគិរី តវ៉ាពីការឃុំខ្លួនខុសច្បាប់ ព្រឹត្តិបត្រសារព័ត៌របស់ The Cambodia Daily ចុះផ្សាយថ្ងៃទី៧-៨ ២០០៦ និងបទយករាយការណ៍ ចុះថ្ងៃទី១១ ២០០៦ ។

ទៀតនៅជាប់ឃុំក្នុងពន្ធនាគារ ។

**នៅថ្ងៃទី ៧ ខែមករា**

**សកម្មជនរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវគេឃុំខ្លួននៅខេត្តតាកែវ នៅពេលស្វែងរកការគាំទ្រចំពោះមេដឹកនាំ ដែលកំពុងឃុំខ្លួន គឺលោក កឹម សុខា**[២៧]

- មន្ត្រីរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាពីរនាក់ត្រូវបានឃុំខ្លួនក្នុងរយៈពេលខ្លី និងសួរចម្លើយដោយនគរបាលខេត្ត នៅពេលពួកគេលើកទឹកចិត្តអ្នកភូមិសូមចុះហត្ថលេខាលើញត្តិ ដើម្បីស្វែងរកការគាំទ្រដោះលែងលោក កឹម សុខា ។
- នគរបាលបានរឹបអូសឯកសារយុទ្ធនាការស្វែងរកហត្ថលេខារាប់រយសន្លឹក ហើយបើតាមប្រភពរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា នគរបាលបញ្ជាប្រជាពលរដ្ឋមិនឱ្យចុះហត្ថលេខាទេ រង់ចាំដល់អ្នកធ្វើយុទ្ធនាការនេះបានទទួលការអនុញ្ញាតិពីរដ្ឋាភិបាលសិន ។

**ថ្ងៃទី ៩ ខែមករា**

**អ្នកភូមិទទួលរងនូវការគំរាមកំហែង ដោយសារជួយអ្នកស្វែងរកសិទ្ធិជ្រកកោន**[២៨]

- អ្នកស្រុកជនជាតិភាគតិចប្រាំនាក់ចាកចេញពីភូមិស្រុក បន្ទាប់ពីទទួលសារដំណឹងស្តីពីការគំរាមសំលាប់ ដែលរកឃើញនៅក្នុងថង់មួយក្នុងភូមិរបស់គេ ។
- អ្នកភូមិទាំងប្រាំនាក់នេះធ្លាប់ត្រូវគេគំរាមពីមុន បន្ទាប់ពីពួកគេទទួលរងនូវការចោទប្រកាន់ថា បានជួយជនស្វែងរកសិទ្ធិជ្រកកោនកុលសម្ព័ន្ធភ្នំម៉ុងតាញ៉ា ។

**ថ្ងៃទី ១៧-៣១ ខែមករា**

**ការបំភិតបំភ័យចំពោះអ្នកការពារសិទ្ធិមនុស្ស ដែលត្រូវបានដោះលែងឱ្យនៅក្រៅឃុំ[២៩] បណ្តោះអាសន្ន នៅភ្នំពេញ**

- លោកនាយករដ្ឋមន្ត្រី ធ្វើជាអ្នកធានាសំរាប់ការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នចំពោះសកម្មជនសិទ្ធិមនុស្សមានលោក កឹម សុខា លោក ប៉ា ងួនទៀង លោក ម៉ម សូណង់ដូ និងលោក រ៉ុង ឈុន ។ ទោះបីជាលោកនាយករដ្ឋមន្ត្រីជំរុញឱ្យមានការដោះលែង តែលោកក៏អាចដកការធានានៅពេលណាមួយក៏បាន ហេតុដូច្នេះ សកម្មជនទាំងនេះនឹងត្រូវចាប់ខ្លួនសារជាថ្មីឡើងវិញ ។
- ការមានឥទ្ធិពលទៅលើអំណាចតុលាការ លោកនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា រដ្ឋាភិបាលអាចរក្សារឿងក្តីនេះនៅ "ស្ងាត់ស្ងៀម" តែបើមានសកម្មជនណាមួយមានប្រព្រឹត្តយ៉ាង "ក្រអឺតក្រទម" នឹងត្រូវចាប់ខ្លួនឡើងវិញ ។
- នៅពេលសរសេររបាយការណ៍សង្ខេបនេះ បទចោទប្រកាន់មកលើសកម្មជនទាំងអស់ខាងលើនៅមិនទាន់បានបញ្ឈប់នៅឡើយ ។

---

[27] ព្រឹត្តិបត្រសារព័ត៌មាន The Cambodia Daily សកម្មជនសិទ្ធិមនុស្សត្រូវបានឃុំខ្លួនរយៈពេលខ្លី ក្នុងបទជាប់ទាក់ទងជាមួយយុទ្ធនាការប្រមូលហត្ថ លេខា ។ ចុះផ្សាយនៅថ្ងៃទី១១ ខែមករា ២០០៦

[28] របាយការណ៍តាមដានដែលមិនផ្សព្វផ្សាយរបស់លីកាដូ ចុះថ្ងៃទី៩ ខែមករា ២០០៦

[29] របាយការណ៍សង្ខេបរបស់លីកាដូ ក្រោមចំណងជើងថា" ការគំរាមកំហែង ចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ខែមិថុនា ២០០៥ ។

**ថ្ងៃទី ២២ ខែមករា**

**អ្នកភូមិម្នាក់ត្រូវគេវាយដំ និងគំរាមកំហែង បន្ទាប់ពីតវ៉ាពីកង្វះទឹកនៅខេត្តបន្ទាយមានជ័យ**[៣០]

- លោក ជឿន រីទ្ធី ជាជនពីការនៅភូមិរស្មីសាមគ្គី ឃុំនីមិ្មត ស្រុកអូរជ្រៅ ត្រូវបានវាយដំដោយឈ្មោះ គួរ ខេង ដែលគេបានរាយការណ៍ថា ជាបងប្អូនរបស់លោក ថាច់ ឃនជាអតីតអភិបាលខេត្តបន្ទាយមានជ័យ (សព្វថ្ងៃជាអភិបាលខេត្តកំពត) ។
- អ្នកភូមិស្នើសុំលោក ជឿន រីទ្ធី ជួយធ្វើអន្តរគមន៍ដើម្បីបញ្ឈប់ក្រុមហ៊ុនបូមទឹកពីស្រះរួមមួយ ដែលអ្នកភូមិទាំងអស់ប្រើប្រាស់សំរាប់បង្កបង្កើតផល ។
- នៅពេលលោក ជឿន រីទ្ធី លើកបញ្ហានេះជាមួយ គួរ ខេង ដែលជាប់ពាក់ព័ន្ធនិងការបូមទឹកជួសមុខឱ្យក្រុមហ៊ុន លោក រិទ្ធី ត្រូវទទួលរងនូវវាយដំជាច្រើនដងចំមុខជាទម្ងន់ ។
- បន្ទាប់មកលោក ជឿន រីទ្ធី ប្តឹងមេភូមិឈ្មោះ ណៃ ហែល ។ មេភូមិមិនបានជួយគាត់ទេ ថែមទាំងគំរាមរកចាប់គាត់ដាក់ពន្ធនាគារទៀតផង ។
- ជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការខេត្តបន្ទាយមានជ័យ ។ មកដល់បច្ចុប្បន្ននេះ តុលាការពុំទាន់ចោទប្រកាន់ទៅលើឈ្មោះ គួរ ខេង ទេ ។

**ថ្ងៃទី៦ ខែកុម្ភៈ**

**សកម្មជនព្រៃឈើម្នាក់ និងគ្រួសារ ត្រូវជាប់ឃុំនៅខេត្តក្រចេះ**[៣១]

- លោក ជឿន ចាន់ដាច់ ជាជនជាតិភាគតិចស្មៀង នៅភូមិព្រែកដាច់ ជាសមាជិកគណៈកម្មការព្រៃឈើសហគមន៍នៅឃុំស្នួល ។ គាត់សកម្មក្នុងការការពារសិទ្ធិរបស់សហគមន៍លើដីប្រព៉ៃណី ហើយប្រឆាំងនឹងជនកាប់ឈើខុសច្បាប់ ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយមន្ត្រីមានអំណាច ។
- នៅថ្ងៃទី៦ ខែគុម្ភះ លោក ជឿន ចាន់ដាច់ និងភរិយាឈ្មោះ ភុំ សារុន និងកូនប្រុសអាយុ១៥ ឆ្នាំនិងកូនប្រសារប្រុសត្រូវបានចាប់ខ្លួនដោយគ្មានដីកា ។ ពីរថ្ងៃបន្ទាប់មក កូនប្រុសរបស់គាត់ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ប៉ុន្តែគាត់និងភរិយាព្រមទាំងកូនប្រសារប្រុសត្រូវបញ្ជូនទៅពន្ធនាគារខេត្តក្រចេះ ។
- ពួកគេត្រូវចោទប្រកាន់ពីបទកាប់ឆ្ការព្រៃខុសច្បាប់ ក្រោមច្បាប់ព្រៃឈើ បន្ទាប់ពីលោក ចាន់ដាច់ កាប់រំលំដើមឈើមួយចំនួននៅលើដីដែលគាត់កាន់កាប់តាំងពីឆ្នាំ១៩៧៩ នាពេលថ្មីៗនេះ គាត់បដិសេធមិនលក់ឱ្យម្ចាស់ចំការដែលមានទីតាំងនៅជាប់ដីគាត់ ។
- នៅថ្ងៃទី៣១ ខែមីនា សកម្មជនជាប់ឃុំបីនាក់ ត្រូវបានផ្តន្ទាទោសតាមរយៈការព្យួរទោសរយៈពេលប្រាំឆ្នាំ ហើយត្រូវបានដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន ។ ទន្ទឹមគ្នានេះដែរ កូនប្រុសរបស់លោក ចាន់ដាច់ បានទទួលការព្យួរទោសរយៈពេលមួយឆ្នាំ ។
- យោងតាមប្រភពរបស់អ្នកភូមិ សកម្មភាពកាប់រានព្រៃឈើបានកើនឡើង បន្ទាប់ពីការចាប់ខ្លួនលោក ចាន់ដាច់ ។ អ្នកភូមិទទួលរងនូវការគំរាមកំហែងធ្វើបាប និងឃ្លាំមើលជា

---

[30] របាយការណ៍តាមដានដែលមិនផ្សព្វផ្សាយរបស់លីកាដូ ចុះថ្ងៃទី១៤ ខែកក្កដា ២០០៦

[31] របាយការណ៍ស្តីពីលទ្ធផលនៃការស៊ើបអង្កេតករណីចាប់ខ្លួនសកម្មជនសហគមន៍នៅស្រុកស្នួល ខេត្តក្រចេះ របស់គំរោងសិទ្ធិជនជាតិភាគតិច នៃអង្គការហ្វ័រុមកម្ពុជា ចុះនៅខែមីនា ឆ្នាំ២០០៦ ។ សូមមើលព្រឹត្តិបត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយនៅថ្ងៃទី១-២ ខែមេសា ២០០៦

ប្រចាំទាក់ទងនិងសកម្មភាពព្រៃសហគមន៍ ។

**នៅដើមខែមីនា**

**លោកសង្ឃត្រូវគេគំរាម បន្ទាប់ពីព្រះអង្គតវ៉ានឹងដីសម្បទាននៅខេត្តកំពត**[៣២]

- លោកសង្ឃមួយអង្គគង់នៅវត្តភ្នំចំបក់ ស្រុកឈូក ទទួលរងនូវការគំរាមផ្សិកពីសំណាក់អាជ្ញាធរមូលដ្ឋាន ដោយសារព្រះអង្គជាប់ពាក់ព័ន្ធការតវ៉ាជាមួយអ្នកភូមិចំពោះដីសម្បទានដែលមានទំហំ៩.៨០០ហិតតា នឹងបង្កឱ្យអ្នកស្រុកចំនួន ១.០២០ គ្រួសារ នៅឃុំត្រពាំងឃ្លាំងដែលអាចប្រឈមមុខនឹងការបាត់បង់ផ្ទះសំបែង ។
- ព្រះអង្គបានមានសង្ឃដីកាជាមួយអ្នកភូមិ ដែលស្នើសុំដំបូន្មានពីព្រះអង្គទាក់ទងទៅនឹងច្បាប់និងសិទ្ធិរបស់ពួកគេលើដី ។ កិច្ចប្រជុំជាមួយគ្រួសារដែលពាក់ព័ន្ធទាំងអស់នោះបានប្រព្រឹត្តទៅនៅក្នុងបរិវេណវត្ត ។
- ការគំរាមកំហែងនេះបញ្ឈប់ដោយសារមហាបាតុកម្មគាំទ្រព្រះអង្គ និងមានអន្តរាគមន៍ពីអង្គការមិនមែនរដ្ឋាភិបាល ។

**ថ្ងៃទី១ ខែមីនា**

**មន្ត្រីសិទ្ធិមនុស្ស និងព្រះសង្ឃមួយអង្គ ត្រូវបានឃុំខ្លួននៅខេត្តកំពត**[៣៣]

- នាកយកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាប្រចាំតំបន់ លោក ផាន សឿន និងបុគ្គលិករបស់លោកម្នាក់ និងចៅអធិការវត្តកោះស្លា នៅស្រុកឈូក ត្រូវបានឃាត់ខ្លួនជាច្រើនម៉ោងតាមបញ្ជារបស់លោក ថាច់ ឃន អភិបាលខេត្តកំពត យោងតាមប្រភពព័ត៌មានរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានិយាយថា ពួកគេកំពុងពិភាក្សាអំពីទីតាំងសំរាប់រៀបចំវេទិការសាធារណៈ ។
- លោក ថាច់ ឃន បានបដិសេធអំពីការឃាត់ខ្លួនអ្នកខាងលើ ប៉ុន្តែលោកមានប្រសាសន៍ថា " លិខិតបេសកម្ម " ដែលអនុញ្ញាតិឱ្យពួកគេធ្វើការបានផុតសុពលភាព ។

**ថ្ងៃទី ១ ខែមីនា**

**មេដឹកនាំសហជីពទទួលការគំរាមដល់ជីវិត ក្នុងអំឡុងពេលធ្វើកូដកម្មនៅភ្នំពេញ**[៣៤]

- លោក ជី សាម៉ុន ប្រធានសហជីពកម្មរបស់សហជីពកម្មករសេរីប្រចាំរោងចក្រកាត់ដេរ Brigh Sky ដែលទីតាំងនៅខណ្ឌដង្កោ ត្រូវគេគំរាមក្នុងអំឡុងពេលធ្វើបាតុកម្មនៅក្នុងរោងចក្រ ដែលត្រូវបានបំបែកដោយកងរាជអាវុធហត្ថ ។
- ជនរងគ្រោះបាននិយាយថា កងរាជអាវុធហត្ថមិនស្គាល់អត្តសញ្ញាណម្នាក់បានគំរាមបាញ់សំលាប់គាត់ ប្រសិនបើគាត់បន្តដឹកនាំធ្វើបាតុកម្មតទៅទៀត ។
- សាម៉ុន ធ្លាប់ជាជនរងគ្រោះនៃការគំរាមកំហែងផ្សេងទៀតក្នុងឆ្នាំ២០០៦ រួមមានអំពើវាយឱ្យរបួសនៅថ្ងៃទី៣ ខែឧសភា ។

---

[32] របាយការណ៍តាមដានដែលមិនផ្សព្វផ្សាយរបស់លីកាដូ ចុះថ្ងៃទី១៥ ខែវិច្ឆកា ២០០៦ ។ អត្ថបទរបស់លោក ទិត សម្បត្តិ ចុះផ្សាយនៅថ្ងៃទី១០ ខែមីនា ២០០៦ លើព្រឹត្តិបត្រ The Cambodai Daily ក្រោមចំណងជើងថា " លោកសង្ឃ មានសង្ឃដីការថា ព្រះសង្ឃត្រូវគេព្រមានមិនឱ្យមានសង្ឃដីការ ។

[33] របាយការណ៍តាមដានដែលមិនផ្សព្វផ្សាយរបស់លីកាដូ ចុះថ្ងៃទី១៥ ខែវិច្ឆកា ២០០៦ ។ អត្ថបទរបស់លោកពីន ស៊ីសូវណ្ណ ចុះផ្សាយនៅថ្ងៃ ទី៣ ខែមីនា លើព្រឹត្តិបត្រ សារព័ត៌ The Cambodai Daily ក្រោមចំណងជើងថា " CCHR ស្នើរមន្ត្រីសុំទោសចំពោះការឃុំខ្លួន "។

[34] របាយការណ៍តាមដានដែលមិនផ្សព្វផ្សាយរបស់លីកាដូ ចុះថ្ងៃទី១០ ខែតុលា ២០០៦

**ថ្ងៃទី ៣ ខែឧសភា**

**តំណាងសហគមន៍ត្រូវគេគំរាមក្នុងនោះតំណាងម្នាក់ត្រូវចាប់ខ្លួន បន្ទាប់ពីតវ៉ាអំពីករណីរំលោភបំពានយកដីនៅខេត្តបន្ទាយមានជ័យ**[៣៥]

- នៅឆ្នាំ២០០៤ មានប្រជាពលរដ្ឋ ២៩៥ គ្រួសារមករស់នៅលើដីទំនេរមួយកន្លែង ដែលមានទីតាំងនៅស្រុកម៉ាឡៃ ហើយបានកាប់ឆ្ការព្រៃឬស្សីនោះដើម្បីបង្កបង្កើនផល ក្រោយមកមានមន្ត្រីយោធាម្នាក់នៅស្រុកប្រកាសថា ដីនេះជាដីរបស់គាត់ ហើយអ្នករស់នៅលើដីត្រូវតែទិញពីគាត់ ។
- នៅថ្ងៃទី៣ ខែមីនា មានទាហានប្រដាប់ដោយអាវុធចំនួនប្រាំនាក់មកចូលរួមប្រជុំនៅស្រុកម៉ាឡៃ ហើយគំរាមតំណាងបួននាក់របស់ប្រជាពលរដ្ឋទាំង២៩៥គ្រួសារ ។ តំណាងបីនាក់បានគេចខ្លួនតែនៅសល់តំណាងទីបួនត្រូវបានចាប់ខ្លួន ហើយជាប់ឃុំឃាំងមួយយប់ ។
- នៅពេលដោះលែង តំណាងរូបនេះត្រូវបានគេប្រាប់ថា ប្រជាពលរដ្ឋទាំងអស់ត្រូវតែចាកចេញពីដី ។ នៅថ្ងៃដដែល ទាហានផ្សេងរឹបអូសយកឧបករណ៍កាប់ឈើជារបស់សហគមន៍ ហើយទាមទារប្រាក់លោះប្រាំពាន់បាត (១៣៥ ដុល្លារ) សំរាប់ការប្រគល់ឧបករណ៍ទាំងនេះវិញ ។

**ថ្ងៃទី ៩ ខែមីនា**

**សកម្មជនសហគមន៍ប្រាំបួននាក់ ត្រូវបានដាក់ក្នុងពន្ធនាគារខ្លួនក្នុងរឿងទំនាស់ដីធ្លីនៅប៉ៃលិន**[៣៦]

- សកម្មជនប្រាំបួននាក់ ក្នុងចំណោមពួកគេមានម្នាក់អាយុ៨១ឆ្នាំ ត្រូវបានចាប់ខ្លួនក្នុងប្រតិបត្តិការបណ្តេញដោយហិង្សាលើប្រជាពលរដ្ឋចំនួន ២០គ្រួសារ ដែលរស់នៅមុខផ្សារភ្នំព្រាល ក្រុងប៉ៃលិន ។ ការបណ្តេញចាប់ផ្តើមនៅថ្ងៃទី៨ ខែមីនា ធ្វើឡើងដោយក្រុមប្រដាប់ដោយអាវុធចំនួន ៥០ នាក់ រួមមាន យោធា កងរាជអាវុធហត្ថ និងនគរបាល ។
- យោងតាមរបាយការណ៍ មនុស្សប្រាំបួននាក់ដែលត្រូវចាប់ខ្លួនមិនមែនជាអ្នកទទួលខុសត្រូវចំពោះអំពើហិង្សាណាមួយក្នុងអំឡុងពេលបណ្តេញឡើយ ប៉ុន្តែពួកគេទទួលរងនូវការវាយនឹងដំបង ទាត់ធាក់ ទះកំភ្លៀង និងវាយនឹងស្នូកកាំភ្លើង ដោយសមត្ថកិច្ចដែលចាប់ខ្លួនពួកគេ ។ ទោះជាយ៉ាងនេះក្តី ជនរងគ្រោះត្រូវបានចោទប្រកាន់ពីបទបង្ករបួសស្នាមមកលើកងកំលាំងប្រដាប់អាវុធទៅវិញ ហើយត្រូវបានបញ្ជូនមកដាក់ឃុំនៅពន្ធនាគាខេត្តបាត់ដំបង ។
- ជនជាប់ឃុំប្រាំមួយនាក់ ត្រូវបានដោះលែងដោយមានលក្ខខណ្ឌ នៅថ្ងៃទី២៩ ខែមីនា ហើយបីនាក់ផ្សេងទៀតត្រូវបានដោះលែងនៅថ្ងៃទី១១ ខែមេសា ។

**ថ្ងៃទី ១៣ ខែមីនា**

**តំណាងសហគមន៍ម្នាក់ត្រូវបានឃុំខ្លួន ដោយជាប់ទាក់ទងនឹងទំនាស់ដីធ្លីនៅខេត្តបន្ទាយមានជ័យ**[៣៧]

- ប៉ៅ យួន តំណាងប្រជាពលរដ្ឋ ១២៨ គ្រួសារនៅភូមិសំរោង ឃុំសំរោង ស្រុកអូរជ្រៅ មានទំនាស់ដីធ្លីជាមួយមន្ត្រីយោធា ។

---

35 របាយការណ៍តាមដានដែលមិនផ្សព្វផ្សាយរបស់លីកាដូ ចុះថ្ងៃទី៣០ ខែសីហា ២០០៦

36 របាយការណ៍តាមដានដែលមិនផ្សព្វផ្សាយរបស់លីកាដូ ចុះថ្ងៃទី២០ ខែតុលា ២០០៦

37 របាយការណ៍តាមដានដែលមិនផ្សព្វផ្សាយរបស់លីកាដូ ចុះថ្ងៃទី៦ ខែតុលា ២០០៦ ។ អត្ថបទរបស់លោកពីន ស៊ីសូវណ្ណ ចុះផ្សាយនៅថ្ងៃ ទី២៧ ខែមីនា លើព្រឹត្តិបត្រសារព័ត៌ិ The Cambodai Daily ក្រោមចំណងជើងថា " ជនជាប់ឃុំក្នុងរឿងទំនាស់ដីធ្លីមួយចំនួនត្រូវបានដោះលែង "។

- គាត់ត្រូវបានចាប់ខ្លួនតាមអំណាចដីកាចាប់ខ្លួនចេញកាលពីឆ្នាំ២០០១ ចោទដោយគ្មានភស្តុតាងពីបទបង្ករបួសស្នាម ដែលជាបណ្តឹងព្យាបាទចំពោះគាត់ ធ្វើឡើងពីមន្ត្រីយោធានៅកងពលលេខ១២ (ពាក្យបណ្តឹងជាប់ទាក់ទងនឹងទំនាស់ដីធ្លីចាស់ ដែលលោក ប៉ៅ យួន បានជួយអ្នកភូមិ។ ពួកអ្នកភូមិបានទទូចសុំថាលោក ប៉ៅ យួន មិនបានបង្ករបួសស្នាមដល់មន្ត្រីយោធានោះទេ) ។
- បន្ទាប់ពីការចាប់ខ្លួនគាត់ អ្នកភូមិធ្វើបាតុកម្មយ៉ាងធំមួយ ដើម្បីបង្ហាញការគាំទ្រចំពោះគាត់ ។
- ប៉ៅ យួន ត្រូវបានដោះលែង នៅថ្ងៃទី២៤ ខែមិនា ប៉ុន្តែបទចោទប្រកាន់មិនទាន់បានបញ្ឈប់នៅឡើយទេ ។

**ថ្ងៃទី ១៤ ខែមីនា**

**តំណាងសហជីពកម្មករប្រាំពីរនាក់ ជាកម្មវត្ថុនៃបណ្តឹងព្យាបាទ បន្ទាប់ពីកូដកម្មនៅភ្នំពេញ**[៣៨]

- ណាត លៀងសៀប, កែវ ពៅ, ណាត សុខណា, លុន សាវ៉ាន់, ណាត លៀងសាត, រឿន សាវៀត និងផុង សុខភា តំណាងសហជីពកម្មកររបស់សម្ព័ន្ធភាពសហជីពកម្មករកាត់ដេរសំលៀកបំពាក់ដើម្បីលទ្ធិប្រជាធិបតេយ្យ ត្រូវបានចោទប្រកាន់ពីបទចូលរួមធ្វើកូដកម្មដែលមានកម្មករចូលប្រមាណ១០.០០០នាក់ នៅខេត្តកណ្តាល និងក្រុងភ្នំពេញ។
- ម្ចាស់រោងចក្រកាត់ដេរ Flying Dragon 3 ចោទតំណាងសហជីពទាំងប្រាំពីរនាក់ថាបានប្រព្រឹត្តបទល្មើសបីៈ ញុះញុងឱ្យអ្នកដទៃឱ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋដោយបានសំរេច, ញុះញុងឱ្យប្រព្រឹត្តបទល្មើឧក្រិដ្ឋដោយពុំបានសំរេចផល និងញុះញុងឱ្យមានការរើសអើង ។
- តំណាងសហជីពកម្មករទាំងប្រាំពីរនាក់ត្រូវបានលោក អ៊ុក សារុធ តំណាងអយ្យការអមតុលាការ[៣៩] ក្រុងភ្នំពេញកោះហៅឱ្យចូលខ្លួនមកជាបន្ទាន់ ។ ដោយប្រឈមមុខនឹងការ គំរាមនេះពួកគេយល់ព្រមដោះស្រាយបញ្ហាជាមួយអ្នកគ្រប់គ្រងរោងចក្រ ហើយដកពាក្យបណ្តឹង ។

**ថ្ងៃទី ១ ខែឧសភា**

**មេដឹកនាំសហជីពកម្មករចំនួនបីនាក់ ត្រូវបានឃុំខ្លួន ក្នុងអំឡុងពេលចូលរួមធ្វើបាតុកម្មដើម្បីលើកកំពស់សិទ្ធិការងារ**[៣៩]

- ជា មុន្នី ប្រធានសហជីពសេរីកម្មករ និងអនុប្រធានពីរនាក់ លោក យេន រដ្ឋកែវពិសី និង ជា វ៉ាន់នៀត ត្រូវបានឃុំខ្លួនដោយនគរបាលរយៈពេលពីរម៉ោង ។

**ថ្ងៃទី ១ ខែឧសភា**

**សកម្មជនសហគមន៍ ត្រូវបានសួរចម្លើយ និងគំរាមដោយនគរបាលខេត្តកំពង់ស្ពឺ**[៤០]

- ប្រជាពលរដ្ឋបីនាក់ដែលសកម្មក្នុងការតស៊ូមតិក្នុងរឿងបញ្ហាដីធ្លី និងធនធានធម្មជាតិ របស់ជនជាតិភាគតិចត្រូវបានកោះហៅដោយនគរបាល ហើយសួរចម្លើយរយៈពេលប្រាំម៉ោងអំពីសកម្មភាពរបស់ពួកគេ ហើយត្រូវបានគេគំរាមមិនឱ្យនិយាយតទៅទៀត ។
- សកម្មជនស្ត្រី ត្រូវបានគំរាមផ្លូវភេទដោយមន្ត្រីនគរបាល ។

[38] របាយការណ៍តាមដានដែលមិនផ្សព្វផ្សាយរបស់លីកាដូ ចុះថ្ងៃទី១០ ខែសីហា ២០០៦ ។ អត្ថបទរបស់លោកយុន សាមីន ចុះផ្សាយនៅថ្ងៃ ទី១ ខែឧសភា លើព្រឹត្តិបត្រសារព័តិ The Cambodai Daily ក្រោមចំណងជើងថា " កម្មករដង្ហែរក្បួននៅទិវាពលកម្មអន្តរជាតិ ទោះបីរដ្ឋាភិបាលដាក់បំរាមក៏ដោយ "។

[39] ព្រឹត្តបត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយនៅថ្ងៃទី២ ខែឧសភា ២០០៦ ។

[40] របាយការណ៍តាមដានដែលមិនផ្សព្វផ្សាយរបស់លីកាដូ ចុះថ្ងៃទី២០ ខែតុលា ២០០៦ ។

- សកម្មជនជាច្រើននាក់នៅប្រឈមមុខដោយការបំភិតបំភ័យ និងកាគំរាមកំហែងក្នុងកន្លែងការងាររបស់ពួកគេ ។

**ថ្ងៃទី ៣ ខែសភា**

**មេដឹកនាំសហជីពកម្មករត្រូវគេវាយយ៉ាងដំណំនៅភ្នំពេញ**[៤១]

- ជី សាម៉ុន ប្រធានសហជីពសេរីកម្មករប្រចាំរោងចក្រ Brigh Sky ដែលស្ថិតនៅខណ្ឌដង្កោ ត្រូវមនុស្សប្រមាណប្រាំពីរនាក់បានវាយប្រហារ នៅពេលចេញពីធ្វើការវេនយប់ ។
- ជនរងគ្រោះត្រូវគេវាយនឹងដំបង និងដែកបំពង់ទីបចំក្បាល ក ដៃ និងជើង ។ ជនល្មើសត្រូវបានបង្រ្កាបដោយកម្មករដទៃទៀតដែលទើបចេញធ្វើការពីរោងចក្រ ។
- ជី សាម៉ុន បានស្គាល់អត្តសញ្ញាណអ្នកវាយគាត់ម្នាក់ថា ជាសមាជិករបស់សហជីពកម្មករដែលគួរប្រជែងនៅរោងចក្រ ហើយបានរាយការពីបញ្ហានេះទៅនគរបាល ព្រមទាំងប្ដឹងទៅតុលាការក្រុងភ្នំពេញ។ មកដល់ពេលបច្ចុប្បន្នេះ ពុំមានការរីកចំរើនចំពោះរឿងក្ដីនេះទេ ។
- គាត់ត្រលប់ចូលធ្វើការនៅថ្ងៃទី១២ ខែឧសភា ទោះបីស្នាមរបួសនៅត្រង់ក្បាលដោយមិនទាន់ជាសះស្បើយនៅឡើយ ។
- កាលពីមុន សាម៉ុន ធ្លាប់ជាជនរងគ្រោះនៃអំពើបំភិតបំភ័យ ហើយនៅថ្ងៃទី២២ ខែឧសភា មានអ្នកវាយប្រហារព្យាយាមវាយគាត់ម្ដងទៀត ។

**ថ្ងៃទី ៣ ខែឧសភា**

**តំណាងសហគមន៍ត្រូវបានគេវាយ និងចាប់ខ្លួនក្នុងកិច្ចតវ៉ារឿងទំនាស់ដីធ្លី នៅខេត្តសៀមរាប**[៤២]

- សូ សុជាតិ អាយុ២៣ឆ្នាំ ជាសកម្មជនភេទស្រី ត្រូវបានចាប់ខ្លួនក្នុងពេលជួបជុំដោយសន្តិភាពមួយរបស់អ្នកភូមិវត្តបូពិ ឃុំសាលាកំរើក ដើម្បីតវ៉ាការប៉ុនប៉ងបណ្ដេញពួកគេចេញពីដី ។
- ចៅអធិការវត្តបូពិ ដែលគេរាយការណ៍ថា មានការគាំទ្រដោយព្រះសម្ដេចរាជ ទេព វង្ស ទាមទារយកដីដែលបានប្រើប័ណ្ណកាន់កាប់ឆ្នាំ១៩៩៥ តែប្រជាពលរដ្ឋមានប័ណ្ណកាន់កាប់តាំងពីឆ្នាំ១៩៩០ ។
- អ្នកភូមិជួបជុំគ្នានៅក្រៅវត្តអស់រយៈពេលពីរថ្ងៃ រង់ចាំមន្ត្រីមូលដ្ឋានចូលមកចរចារជាមួយពួកគេ ។ នៅថ្ងៃទី៣ ខែឧសភា ការជួបជុំរបស់អ្នកភូមិត្រូវបានបំបែកដោយនគរបាលប្រដាប់ដោយកាំភ្លើង និងដំបងឆក់ ។ សុជាតិ ត្រូវបានចាប់ខ្លួនក្នុងខណៈនាងព្យាយាមការពារប្រជាពលរដ្ឋពីការវាយដំ ។
- សុជាតិ ត្រូវចោទពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ផ្អែកតាមពាក្យបណ្ដឹងរបស់នគរបាល ។ នាងត្រូវបានដោះលែងនៅថ្ងៃបន្ទាប់ ប៉ុន្តែបទចោទប្រកាន់មកលើរូបនាងមិនទាន់បានបញ្ឈប់នៅឡើយទេ។

---

41 របាយការណ៍តាមដានដែលមិនផ្សព្វផ្សាយរបស់លីកាដូ ចុះថ្ងៃទី១០ ខែតុលា ២០០៦ ។ អត្ថបទរបស់លោកសេង សឿនរឹត ចុះផ្សាយនៅថ្ងៃ ទី៤ ខែឧសភា លើព្រឹត្តិបត្រសារព័ត៌ The Cambodai Daily ក្រោមចំណងជើងថា " ជា មុន្នី សមាជិកសហជីពកម្មករ ទទួលរងនូវការវាយដុំនៅខាងក្រៅរោងចក្រ "។

42 របាយការណ៍តាមដានដែលមិនផ្សព្វផ្សាយរបស់លីកាដូ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ២០០៦ ។ អត្ថបទរបស់លោកគុជ ណារ៉ែន ចុះផ្សាយនៅថ្ងៃ ទី៨ ខែឧសភា លើព្រឹត្តិបត្រសារព័ត៌ The Cambodai Daily ក្រោមចំណងជើងថា " ស្រីម្នាក់ត្រូវគេចាប់ខ្លួនក្នុងបទញុំញុងបង្កឱ្យមានអំពើហិង្សានៅវត្ត "។

**ថ្ងៃទី ៤ ខែឧសភា**

**បុគ្គលិកសិទ្ធិមនុស្សបួនរូបត្រូវបានឃាត់ខ្លួន និងគំរាមកំហែងក្នុងពេលពួកគេកំពុងធ្វើការតាមដានរឿងជម្លោះដីធ្លីនៅខេត្តកំពត**[៤៣]

- ទេព ណារ័ត្ន និង ង៉ែត សូរ្យសែង មកពីអង្គការលីកាដូ ទ្រី ឈួន មកពីអង្គការអាដហុក និង ឈឹម សារ៉ុធ មកពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បាននឹងកំពុងតាមដានក្នុងរឿងជម្លោះដីធ្លីមួយរវាងអ្នកភូមិ និងអាជ្ញាធរខេត្ត នៅភូមិព្រៃពាយ ឃុំត្រពាំងផ្លាំង ស្រុកឈូក ។
- បុគ្គលិកសិទ្ធិមនុស្ស ត្រូវបានរារាំងមិនឱ្យចូលទៅកាន់ទីកន្លែងកើតមានជម្លោះ ព្រមទាំងមិនឱ្យប្រមូលយកព័ត៌មានប្រហែលមានការទាក់ទិននឹងការរុះរើផ្ទះសម្បែង ។ បន្ទាប់មកពួកគេត្រូវបានភ្ជង់ឃាត់ខ្លួនដោយកាំភ្លើងពីសំណាក់នគរបាល យោធា និងកងរាជអាវុធហត្ថ ប្រមាណជា៣០នាក់ តាមបញ្ជារបស់ប្រធានមន្ទីរកសិកម្មខេត្ត និងប្រធានមន្ទីររដ្ឋបាលព្រៃឈើ ។
- នៅពេល ទ្រី ឈួន ប្រើប្រាស់ម៉ាស៊ីនថតរបស់នាងត្រូវបានរឹបអូស ហើយរូបភាពក៏ត្រូវបានលុបចោលអស់ ។
- បុគ្គលិកសិទ្ធិមនុស្សទាំងបួនរូប ត្រូវបានដោះលែងនៅប្រហែល៣០នាទី មុនពេលត្រូវបណ្តេញចេញពីតំបន់នោះ ។
- អង្គការអាដហុក បានដាក់ពាក្យបណ្តឹងជាបន្តបន្ទាប់ទៅតុលាការខេត្តកំពតលើបញ្ហានៃការឃាត់ខ្លួនដោយខុសច្បាប់នេះ ។ ប៉ុន្តែ រហូតមកដល់ថ្ងៃនេះមិនទាន់មានអ្វីកើតឡើងនៅឡើយទាក់ទិននឹងករណីនេះ ។

**ថ្ងៃទី ១២ ខែឧសភា**

**សកម្មជនសហជីពត្រូវបានវាយដំ នៅទីក្រុងភ្នំពេញ**[៤៤]

- យ៉េង វណ្ណយុទ្ធ សកម្មជនសហជីពកម្មករនៃរោងចក្រ Brigh Sky ក្នុងខណ្ឌដង្កោ ត្រូវបានគេវាយប្រហាធ្វើឱ្យគាត់មានរបួសនៅត្រង់ក្បាល និងឆ្អឹងជំនី ហើយត្រូវចូលសំរាកនៅមន្ទីរពេទ្យ ។
- ប្រធានសហជីពកម្មករ ជី សាម៉ុន ជឿថាជនដៃដល់គឺជាក្រុមតែមួយដែលបានបង្ករបួសស្នាមមកលើរូបគាត់ម្តងរួចមកហើយកាលពីថ្ងៃទី៣ ខែឧសភា ហើយករណីលើកនេះគឺជាចេតនាមកលើរូបគាត់ ។

**ថ្ងៃទី ១៤ ខែឧសភា**

**សកម្មជនសិទ្ធិមនុស្សត្រូវបានគេគំរាមកំហែង និងបង្ករបួសស្នាម នៅខេត្តរតនគីរី**[៤៥]

- បុគ្គលិកពីររូប មកពីអង្គការសិទ្ធិមនុស្ស ដើម្បីឥស្សរភាពនិងសន្តិភាព ហៅកាត់ថា (HROTP) និងម្នាក់ទៀតមកពីអង្គការសិទ្ធិមនុស្សវីជីឡែនកម្ពុជា (HRVC) ត្រូវបានគេប្រើកាំភ្លើង

---

[៤៣] របាយការណ៍តាមដានរបស់អង្គការលីកាដូដែលមិនផ្សព្វផ្សាយ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦។ សូមមើល អត្ថបទចុះផ្សាយនៅក្នុងព្រឹត្តបត្រ The Cambodia Daily ចុះផ្សាយថ្ងៃទី ៩ ខែមេសា ឆ្នាំ២០០៦ ដែលមានចំណងជើងថា សមាជិកអង្គការមិនមែនរដ្ឋាភិបាល ចោទប្រកាន់មន្ត្រីថាធ្វើការឃាត់ខ្លួនពួកគេ *ដោយ គុច ណារ៉េន* ។

[៤៤] ICFTU សេរីភាពសមាគម: ករណីលេខ ២៣១៨ (កម្ពុជា) (ព័ត៌មានបន្ថែម), លិខិតបើកចំហមកកាន់អង្គការ ILO ចុះថ្ងៃទី ៣ តុលា ២០០៦

[៤៥] ព័ត៌មាន ផ្តល់ដោយអង្គការអាដហុក។ សូមមើលអត្ថបទចុះផ្សាយនៅព្រឹត្តិបត្រ The Cambodia Daily ចុះផ្សាយថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០០៦ ដែលមានចំណងជើងថា អង្គការមិនមែនរដ្ឋាភិបាល: ជនប្រដាប់អាវុធបានគំរាមកំហែងអ្នកភូមិលើបញ្ហារឿងដីធ្លី *ដោយ ថេត សម្បត្តិ* ។

គំរាមកំហែងក្នុងខណៈពួកគេកំពុងធ្វើការតាមដានរឿងជម្លោះដីធ្លីមួយនៅក្នុងឃុំរម្យនា ស្រុកសែនមនោរម្យ ។

- នៅពេលអ្នកតាមដានបានធ្វើដំណើរមកដល់ដើម្បីពិនិត្យមើលទៅលើខ្ទមមួយ ដែលបានដុតឆេះអស់កាលពីយប់មិញ ពេលនោះពួកគេត្រូវបានគំរាមកំហែងដោយក្រុមប្រដាប់អាវុធ ដែលគេជឿថាក្រុមនេះមកពីទីក្រុងភ្នំពេញកាលពីមុននេះមួយថ្ងៃ ។
- នៅពេលដែលបុគ្គលិកអង្គការ HROTP ថតរូបទៅលើបុរសដែលកំពុងតម្រង់កាំភ្លើងដាក់អ្នកភូមិ បុរសម្នាក់ក៏បានយកកាំភ្លើងមកភ្ជង់ក្បាលរបស់គាត់រួចនិយាយថា "ប្រសិនបើឯងនៅតែថតរូបបន្តទៀត យើងនឹងសម្លាប់ឯងភ្លាម"។ ថាហើយបុរស (ប៉ូលីស) នោះក៏បានទាត់ពោះគាត់រួចដកយកម៉ាស៊ីនថតនោះទៅ។

**ថ្ងៃទី ១៩ ខែឧសភា**

**មេដឹកសហជីព ត្រូវបានវាយប្រហារនៅទីក្រុងភ្នំពេញ**[៤៦]

- ជ័យ ឫទ្ធី អនុប្រធានសហជីពសេរីកម្មករនៃរោងចក្រ សាន់តិចហ្គាមិន ត្រូវបានវាយប្រហារដោយបុរសមិនស្គាល់អត្តសញ្ញាណពីរនាក់ ដោយការគប់ដុំថ្មដាក់រូបគាត់ ពេលគាត់កំពុងជិះម៉ូតូពីកន្លែងធ្វើការមកផ្ទះជាមួយនងភរិយារបស់គាត់ដែលមានផ្ទៃពោះផង។ គាត់ទទួលរងរបួស និងមានឈាមហូរចេញពីក្បាលគាត់។
- រោងចក្រកាត់ដេរ សាន់តិច មានទីតាំងស្ថិតនៅជិតនឹងរោងចក្រ Brigh Sky ដេរ ដែលទីនោះតំណាងសហជីពសេរីកម្មករធ្លាប់ទទួលរងការគំរាមកំហែង និងវាយបង្កឱ្យរបួសស្នាមជាច្រើនលើកច្រើនសារមកហើយក្នុងឆ្នាំ២០០៦ ហើយរោងចក្រនេះ ក៏ជាកម្មសិទ្ធិរបស់ម្ចាស់តែមួយដូចគ្នា ។

**ថ្ងៃទី ២២ ខែឧសភា**

**បុគ្គលិកសិទ្ធិមនុស្ស ត្រូវបានចាប់ខ្លួននៅក្នុងរឿងជម្លោះលំនៅដ្ឋាន នៅខេត្តកោះកុង**[៤៧]

- តាន់ សុខុម ជាសកម្មជនសិទ្ធិមនុស្សនៃអង្គការអាដហុក ត្រូវបានចាប់ខ្លួនដោយក្រុមល្បាតអភិរក្សព្រៃឈើ រួមមានកងរាជអាវុធហត្ថ និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិវ៉ាយអេដ ។
- ជនរងគ្រោះត្រូវចាប់ដាក់ច្រវាក់ដៃអស់រយៈពេលប្រហែល២០-៣០នាទី ។ ចំណែកម៉ាស៊ីនថតរបស់នាងត្រូវបានបំផ្លាញចោល បន្ទាប់ពីនាងបានថតនូវសកម្មភាពប្រឈមមុខដាក់គ្នារវាងក្រុមល្បាតនិងអ្នកភូមិ ដែលកាលពីមុននេះពួកគេបានដុតបំផ្លាញផ្ទះអ្នកភូមិអស់ចំនួនបីខ្នងដោយពួកគេអះអាងថា ផ្ទះទាំងនោះសាងសង់ក្នុង តំបន់ព្រៃដែលត្រូវបានការពារ ។
- អ្នកតំណាងអង្គការវ៉ាយអេដ ក្រោយមកបានចោទប្រកាន់សកម្មជនថា "ជាអ្នកដឹកនាំកុប្បកម្ម" ជាការចោទប្រកាន់មួយដែលអង្គការអាដហុកបានបដិសេធ ។ ពាក្យបណ្តឹងមួយត្រូវ

---

[៤៦] ICFTU សេរីភាពសមាគមៈ ករណីលេខ ២៣១៨ (កម្ពុជា) (ព័តិមានបន្ថែម), លិខិតបើកចំហមកកាន់អង្គការ ILO ចុះថ្ងៃទី ៣ តុលា ២០០៦

[៤៧] របាយការណ៍តាមដានរបស់អង្គការលីកាដូមិនទាន់បោះពុម្ពផ្សាយនៅឡើយ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៦។ សូមមើលអត្ថបទចុះផ្សាយនៅក្នុង ព្រឹត្តិបត្រ The Cambodia Daily ចុះផ្សាយថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០០៦ ដែលមានចំណងជើងថា អ្នកភូមិនិយាយថា មន្ត្រី, NGO ដុតផ្ទះ *ដោយ គុច ណារ៉េន និង* Douglas Gillision និងអត្ថបទចុះផ្សាយជាបន្តបន្ទាប់នៅថ្ងៃទី ២៦ ខែឧសភា — ថ្ងៃទី ២ មិថុនា ។

បានធ្វើឡើងដោយអង្គការអាដហុកប្តឹងអង្គការវ៉ាយអេដ ក៏បានដាក់ជូនតុលាការខេត្តកោះកុងរួចហើយដែរ ។

**ថ្ងៃទី ២២ ខែឧសភា**

**មេដឹកនាំសហជីព ត្រូវបានគំរាមកំហែងនៅទីក្រុងភ្នំពេញ**[៤៨]

- ជី សាម៉ុន ប្រធានសហជីពសេរីកម្មករនៃរោងចក្រប្រាយស្កាយ នៅក្នុងខណ្ឌដង្កោ ត្រូវបានគំរាមកំហែងជាថ្មីម្តងទៀត ពេលនេះធ្វើឡើងដោយក្រុមមានគ្នាប្រហែល ២០នាក់ ក្នុងពេលគាត់ចាកចេញពីធ្វើការនៅវេនយប់ ។ គាត់បានគេចផុតពីតាមការវាយប្រហារនោះដោយការរត់ត្រឡប់ទៅរោងចក្រវិញ ហើយរង់ចាំរហូតដល់ពេលហៀបភ្លឺទើបគាត់ចាកចេញទៅ ។

**ថ្ងៃទី ៦ ខែមិថុនា**

**បុគ្គលិកសិទ្ធិមនុស្ស ត្រូវបានរារាំងរំខានចំពោះការតាមដានលើការបណ្តេញចេញមួយប្រកបដោយហិង្សានៅទីក្រុងភ្នំពេញ**[៤៩]

- ជានិច្ចកាល អាជ្ញាធរបានរារាំងចំពោះការឃ្លាំមើលទៅលើការបណ្តេញចេញអ្នកភូមិសំបុកចាប ដោយប្រើកងកម្លាំង។ នគរបាលបានបដិសេធការសុំចូលរបស់អង្គការសិទ្ធិ មនុស្សមិនមែនរដ្ឋាភិបាល បុគ្គលិកមកពីការិយាល័យឧត្តមស្នងអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងប្រព័ន្ធឃោសនាព័ត៌មាន ។ នគរបាលបានរារាំងដល់អ្នកសង្កេតការណ៍មិនឱ្យថតរូបភាព ហើយបានរឹបអូសសៀវភៅសំរាប់កត់ត្រាពីបុគ្គលិកអង្គការមិនមែន រដ្ឋាភិបាល។
- ក្នុងអំឡុងពេលនៃការបណ្តេញចេញនេះ សមាជិកសហគមន៍ចំនួនប្រាំបីរូបត្រូវបានចាប់ខ្លួន ។ ប្រជាពលរដ្ឋមួយរូបរស់នៅក្បែរភូមិសំបុកចាប ក៏ត្រូវបានឃាត់ខ្លួនមួយរយៈខ្លីផងដែរ ដើម្បីសួរនាំនៅប៉ុស្តិ៍នគរបាល ដោយសារតែគាត់បានអនុញ្ញាតអោយបុគ្គលិកអង្គការមិនមែនរដ្ឋភិបាលធ្វើការឃ្លាំមើលព្រឹត្តិការណ៍នេះពីលើដំបូលផ្ទះរបស់គាត់ ។

**ថ្ងៃទី ៧ ខែមិថុនា**

**ការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌដោយការព្យាបាទ ទៅលើអ្នកតំណាងភូមិបីរូប នៅខេត្តបន្ទាយមានជ័យ**[៥០]

- នុត ឡាយ, សាត សំនៀង និង ហេង ណូក អ្នកតំណាងភូមិអូរឫស្សី ឃុំប៉ោយប៉ែត ត្រូវបានចោទប្រកាន់ដោយខុសច្បាប់ ពីលោកព្រះរាជអាជ្ញាអមតុលាការខេត្តបន្ទាយមានជ័យ ។
- ថ្ងៃទី២៣ ខែមីនា អ្នកទាំងបីបានដឹកនាំការធ្វើបាតុកម្មដោយសន្តិវិធីមួយ ដែលមានមនុស្សចូលរួមប្រមាណ ១០០នាក់ ដើម្បីទាមទារឱ្យដោះស្បង់ចីវរព្រះសង្ឃមួយអង្គ ដែលបានចោទប្រកាន់ថា បានរំលោភសេពសន្ថវៈទៅលើក្មេងស្រីជាច្រើននាក់ ដែលពួកគាត់មានអារម្មណ៍ថាព្រះសង្ឃអង្គនេះកំពុងទទួលបានកិច្ចការពារពីសំណាក់មេភូមិឈ្មោះ សូ មឿន។
- ថ្ងៃទី១ ខែមិថុនា អ្នកទាំងបីបានផ្ញើរញត្តិមួយជូនអាជ្ញាធរមូលដ្ឋាន ដោយស្នើសុំឱ្យពួកគេចាប់ផ្តើមដំណើរការតាមផែនការក្នុងការសាងសង់ផ្លូវសាធារណៈមួយខ្សែជាបន្ទាន់ ដែលផ្លូវនេះ

---

[៤៨] ICFTU សេរីភាពសមាគមៈ ករណីលេខ ២៣១៨ (កម្ពុជា) (ព័ត៌មានបន្ថែម), លិខិតបើកចំហមកកាន់អង្គការ ILO ចុះថ្ងៃទី ៣ តុលា ២០០៦

[៤៩] CHRAC, HRTF & RNAF, សេចក្តីថ្លែងការណ៍រួម ស្តីពីការបណ្តេញចេញ អ្នកភូមិសំបុកចាប ថ្ងៃទី ៧ ខែមិថុនា និងរបាយការណ៍តាមដានរបស់លីកាដូ ដែលមិនទាន់ផ្សព្វផ្សាយ ។

[៥០] របាយការណ៍តាមដានរបស់ការលីកាដូ មិនផ្សព្វផ្សាយ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០០៦។

ស្ថិតនៅជាប់នឹងផ្ទះរបស់ពួកគាត់ ។ ដីដែលទុកសំរាប់ធ្វើផ្លូវនេះ ប៉ុន្តែមិនទាន់បានសាងសង់នៅឡើយ តែត្រូវមានការចោទប្រកាន់ថាមេភូមិ លោក សូ មឿន បានលក់ ឬបានដឹងអំពីការលក់ដីនេះទៅឱ្យចៅក្រមតុលាការខេត្តបន្ទាយមានជ័យ ឈ្មោះ តុប ចាន់សេរីវុទ្ធ ។

- ថ្ងៃទី២ ខែមិថុនា លោក សូ មឿន បានដាក់ពាក្យបណ្តឹងផ្នែកព្រហ្មទណ្ឌមួយទៅតុលាការដោយប្តឹងអ្នកភូមិចំនួនបីនាក់ក្នុងរឿងធ្វើបាតុកម្មកាលពីថ្ងៃទី២៣ ខែមីនា ។
- ថ្ងៃទី៧ ខែមិថុនា តុលាការខេត្តក៏បានធ្វើការចោទប្រកាន់អ្នកភូមិទាំងបីនាក់ ថាជាអ្នកញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋទាក់ទិនទៅនឹងរឿងធ្វើបាតុកម្មកាលពីថ្ងៃទី២៣ ខែមីនា បើទោះបីជាគ្មានភស្តុតាងក្នុងការចោទប្រកាន់នេះក៏ដោយ ។ (លោក សូ មឿន ពេលក្រោយមកក៏បានប្រាប់ទៅមេធាវីរបស់ជនរងគ្រោះថា គាត់ទទួលរងការខាតបង់ខាងផ្នែកសេដ្ឋកិច្ចនៅពេលមានបាតុកម្មកើតឡើងបង្កឱ្យបិទពិធីជប់លៀងមួយ ដែលរូបគាត់ជាអ្នករៀបចំ) ។
- ថ្ងៃទី៣០ ខែមិថុនា អ្នកទាំងបីក៏ទៅបង្ហាញមុខនៅតុលាការខេត្តដើម្បីឱ្យសួរនាំដោយចៅក្រម ឈ្មោះ តុប ចាន់សេរីវុទ្ធ ។ ដោយមានការអន្តរាគមន៍ជាបន្តបន្ទាប់ពីមេធាវីអង្គការគំរោងអ្នកការពារក្តីកម្ពុជា និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ពួកគេមិនត្រូវបានជាប់ឃុំឡើយ ប៉ុន្តែការចោទប្រកាន់នៅតែមានចំពោះពួកគេ ។

**ថ្ងៃទី៨ ខែមិថុនា**

**មេដឹកនាំសហជីព ត្រូវបានវាយដំ នៅទីក្រុងភ្នំពេញ**[៥១]

- ឡៃម សំរិទ្ធ ជាហិរញ្ញិកនៃសហជីពសេរីកម្មករប្រចាំរោងចក្រ ប្រាយស្ហាយ ក្នុងខណ្ឌដង្កោ បានត្រូវវាយដំដោយក្រុមមនុស្សប្រមាណ២០នាក់ ពេលគាត់ចាកចេញពីធ្វើការវេនយប់ ។
- ឡៃម សំរិទ្ធ គឺជាជនទីបីនៃតំណាងសហជីពកម្មករប្រចាំរោងចក្រ ប្រាយស្ហាយ ដែលទទួលរងនូវវាយឱ្យរបួសស្នាមក្នុងកំឡុងពេលតែ ៥ សប្តាហ៍ប៉ុណ្ណោះ ។

**ថ្ងៃទី ១៣ ខែមិថុនា**

**ការកាត់ទោសអ្នកតំណាងសហជីព នៅខេត្តកណ្តាល**[៥២]

- ឡាច សំបូ, យិន យុន, សាល គឹមសាន និង ហេង សំណាង ដែលជាសកម្មជនសហជីពសេរីកម្មករនៃរោងចក្រ ហ្គីនីនហ្គាមិនហ្វែកតូរី មានទីតាំងស្ថិតនៅស្រុកអង្គស្នួល ត្រូវបានកាត់ទោសពីបទចោទប្រកាន់ថា បានបង្ករបួសស្នាម និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ដោយតុលាការខេត្តកណ្តាល ។ ពួកគេម្នាក់ៗទទួលទោសជាប់ពន្ធនាគារមួយឆ្នាំដោយការព្យួរ និងពិន័យជាប្រាក់ចំនួន ៨ លានរៀល ។
- បទចោទប្រកាន់នេះទាក់ទិនក្នុងរឿងធ្វើកូដកម្មមួយនៅរោងចក្រកាលពី២ឆ្នាំកន្លងទៅ ។ សកម្មជនបួនរូបផ្សេងទៀត ដែលបានចាកចេញពីរោងចក្រ ចាប់ពីពេលនោះមកត្រូវបានចោទប្រកាន់ និងកាត់ទោសស្រដៀងគ្នានេះដែរ ។
- ថ្ងៃទី១៧ ខែមិថុនា ចុងចោទក៏បានដាក់ពាក្យប្តឹងឧទ្ធរណ៍ចំពោះការកាត់ទោសនេះ ។ បីថ្ងៃ

---

[៥១] ICFTU សេរីភាពសមាគមៈ ករណីលេខ ២៣១៨ (កម្ពុជា) (ព័ត៌មានបន្ថែម), លិខិតបើកចំហមកកាន់អង្គការ ILO ចុះថ្ងៃទី ៣ តុលា ២០០៦

[៥២] របាយការណ៍តាមដានរបស់អង្គការលីកាដូ មិនទាន់បោះពុម្ពផ្សាយ ថ្ងៃទី២០ ខែតុលា ឆ្នាំ ២០០៦ ។

បន្ទាប់មកពួកគេក៏ត្រូវបានព្យួរពីការងារ ដោយសារពាក់ព័ន្ធនឹងការចូលរួមធ្វើកូដកម្មទាមទារ និងការដាក់ពន្ធនាគារជនបីនាក់ទៀតក្នុងពេលថ្មីៗ (សូមអានខាងក្រោម) ។

**ថ្ងៃទី ១៧ ខែមិថុនា**

**សកម្មជនសហជីពជាគ្រូបង្រៀន ទទួលរងរបួសស្នាម នៅទីក្រុងភ្នំពេញ**[៥៣]

- អ្នកស្រី ឯម ពុននី ជាគ្រូបង្រៀនសាលាបឋមសិក្សា វត្តមហាមន្ត្រី ក្នុងខណ្ឌចំការមន ហើយក៏ជាសមាជិកសហជីពគ្រូបង្រៀនឯករាជ្យកម្ពុជា ទទួលរងរបួសក្បាលដោយការវាយនឹងដុំថ្ម ។
- ជនរងគ្រោះដែលកំពុងតែធ្វើការផ្សព្វផ្សាយព័ត៌មានទាក់ទិននឹងសំណើរធ្វើកូដកម្មរបស់សហជីពគ្រូបង្រៀនឯករាជ្យកម្ពុជាដើម្បីទាមទារតម្លើងប្រាក់ខែ និងលក្ខខណ្ឌការងារឱ្យបានប្រសើរឡើង ។
- ឯម ពុននី បានអះអាងថា នាងត្រូវ យឹម សុខា ដែលជាអនុប្រធាននាយកដ្ឋានអប់រំស្រុកវាយមកលើរូបគាត់ ហើយគាត់ក៏បានដាក់ពាក្យបណ្តឹងទៅតុលាការក្រុងភ្នំពេញកាលពីថ្ងៃទី ២១ ខែមិថុនា ។ រហូតមកដល់ថ្ងៃនេះ មិនទាន់មានរបាយការណាមួយស្តីពីការរីកចំរើនជុំវិញនៃករណីនេះនៅឡើយ ។

**ថ្ងៃទី ២១ ខែមិថុនា**

**ការបង្ករបួសស្នាមទៅលើអ្នកកាសែតដែលសរសេរពីបញ្ហានៃការរឹបអូសដីធ្លី នៅខេត្តកំពង់ស្ពឺ**[៥៤]

- ខែម ជាម និង ឡេង សារ៉ន មកពីសហព័ន្ធអ្នកកាសែតកម្ពុជា ត្រូវបានវាយប្រហារខណៈដែលគាត់កំពុងធ្វើការរាយការណ៍អំពីបញ្ហាទំនាស់ដីធ្លីមួយក្នុងភូមិចំការចេក ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ។
- បុរសទាំងពីរនាក់ ត្រូវបានប៉ូលីស និងសន្តិសុខឯកជនធ្វើការវាយដំ និងទាត់ធាក់ ព្រមទាំងបាញ់ផ្ទុចដីនៅចំពោះមុខគេទាំងពីរទៀតផង ។ ម៉ាស៊ីនថត ឧបករណ៏ថតសម្លេង និងឯកសារត្រូវបានគេរឹបអូស បើទោះបីម៉ាស៊ីនថតត្រូវបានប្រគល់ឱ្យវិញនៅថ្ងៃបន្ទាប់ក៏ដោយ ។
- បុរសទាំងពីរនាក់បានដាក់ពាក្យបណ្តឹងជូនតុលាការខេត្តកំពង់ស្ពឺរួចហើយ ។ រហូតមកដល់ថ្ងៃនេះ មិនទាន់មានរបាយការណ៍ណាមួយស្តីពីការរីកចំរើននៃករណីនេះនៅឡើយ ។

**ថ្ងៃទី ២៩ ខែមិថុនា**

**បុគ្គលិកសិទ្ធិមនុស្សត្រូវបានរារាំងរំខានពីការតាមដានទៅលើការបណ្តេញចេញ និងផ្លាស់ទីលំនៅដោយហិង្សា**[៥៥]

- នគរបាលបានរារាំងបុគ្គលិកសិទ្ធិមនុស្សអង្គការមិនមែនរដ្ឋាភិបាល និងអ្នកកាសែតមិនឱ្យសង្កេតការណ៍តាមដានការបណ្តេញចេញដោយប្រើកម្លាំងទៅលើប្រជាពលរដ្ឋ ចំនួន ១៦៨ គ្រួសារ ដែលកំពុងរស់នៅជិតមន្ទីរពេទ្យព្រះមុន្នីវង្ស ។

---

[៥៣] របាយការណ៍តាមដានរបស់អង្គការលីកាដូ មិនទាន់បោះពុម្ពផ្សាយ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០០៦ ។ សូមមើលផងដែរ អត្ថបទចុះផ្សាយនៅក្នុង ព្រឹត្តបត្រ the Cambodia Daily ចុះផ្សាយថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៦ ដែលមានចំណងជើងថា គ្រូបង្រៀននិយាយថា ខ្លួនទទួលរងរបួសស្នាមដោយសារការវាយតប់គ្នាជាមួយមន្ត្រីអប់រំ *ដោយ យុន សាមៀន* ។

[៥៤] របាយការណ៍តាមដានការលីកាដូ ដែលមិនផ្សព្វផ្សាយ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០០៦ ។ សូមមើលផងដែរនូវ សេចក្តីថ្លែងការណ៍ព័ត៌មានពី FJC ចុះថ្ងៃទី២១ មិថុនា ២០០៦ និងចុះផ្សាយនៅក្នុងការសែតកម្ពុជាថ្មី ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៦ ។

[៥៥] កង្វល់អំពីការបណ្តេញចេញ អ្នកភូមិចំនួន ១៦៨ គ្រួសារ នៅមន្ទីពេទ្យមុន្នីវង្ស *គណៈកម្មាធិការប្រព្រឹត្តិកម្មសិទ្ធិមនុស្សកម្ពុជា* ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៦ ។

- ក្រោយមកក្នុងថ្ងៃតែមួយ អ្នកស៊ើបអង្កេតពីររូបរបស់អង្គការលីកាដូ ដែលស្ថិតនៅទីកន្លែងដែលត្រូវផ្លាស់ប្តូរទីតាំងថ្មី នៅភូមិស្រែអំពិល ឃុំស្នោ ស្រុកអង្គស្នួល ខេត្តកណ្តាលត្រូវបានឃាត់ខ្លួនរយៈពេលខ្លី នឹងសួរនាំដោយនគរបាលព្រមទាំងរារាំងមិនឱ្យថតរូប ។

**ថ្ងៃទី ៣ ខែកក្កដា**

**ការដាក់ពន្ធនាគារនៃអ្នកតំណាងសហជីពទាំងបីរូប នៅខេត្តកណ្តាល**[៥៦]

- ឡាច សំបូ, យិន យុន និង សាល គឹមសាន ជាសកម្មជនសហជីពសេរីកម្មករនៅរោងចក្រហ្គិននិនហ្គាមិនហ្វែកតូរី នៅក្នុងស្រុកអង្គស្នួល ត្រូវបានចាប់ខ្លួននៅក្នុងផ្ទះរបស់ពួកគេដោយមន្ត្រីនគរបាល ។ នៅថ្ងៃបន្ទាប់ ពួកគេត្រូវបានចោទប្រកាន់ពីបទបង្ខាំងមនុស្សដោយខុសច្បាប់ ហើយត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារខេត្តកណ្តាល ។
- ការចោទប្រកាន់ពាក់ព័ន្ធទៅនឹងកូដកម្ម ដែលបានកើតឡើងនៅរោងចក្រតាំងពីថ្ងៃទី២៣ ខែមិថុនា ដែលជាការទាមទារឱ្យផ្អាកការងាររបស់សកម្មជនបីរូប ក្រោយពីពួកគេទាំងបីនាក់ត្រូវបានកាត់ទោសពីបទល្មើសព្រហ្មទណ្ឌ កាលពីថ្ងៃទី១៣ ខែមិថុនា (សូមមើលការរៀបរាប់ដូចបានពោលខាងលើ) ហើយជាបន្តបន្ទាប់ ពួកគេក៏បានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ។
- នៅថ្ងៃទី៧ ខែសីហា ជនទាំងបីនាក់ ត្រូវបានគេរកឃើញថា មានកំហុសពីបទបង្ខាំងមនុស្សខុសច្បាប់ បើទោះបីជាគ្មានភស្តុតាងគ្រប់គ្រាន់ក៏ដោយ ហើយក៏បានកាត់ទោសឱ្យជាប់ទោសរយៈពេលដែលពួកគេបានរស់នៅក្នុងពន្ធនាគារ រួចទើបដោះលែងឱ្យរួចខ្លួនដោយមានការព្យួរទោសរយៈពេលបីឆ្នាំបន្ថែមទៀត ។ ពួកគេទាំងបីនាក់មិនបានទទួលការងារនៅកន្លែងដើមវិញឡើយ ។

**ថ្ងៃទី ៤ ខែកក្កដា**

**អ្នកតំណាងសហជីពត្រូវបានគេបាញ់ប្រហារ នៅទីក្រុងភ្នំពេញ**[៥៧]

- ឡាយ ចំរើន ជាអនុប្រធានសហជីពសេរីកម្មករ នៅរោងចក្រភ្នំពេញ ស៊ីធីហ្គាមិន ហ្វែកតូរី ត្រូវទទួលរងរបួសជើង ដោយអំបែងគ្រាប់កាំភ្លើងដែលបាញ់តម្រង់មកគាត់ក្នុងខណៈគាត់កំពុងជិះម៉ូតូពីកន្លែងធ្វើការត្រឡប់ទៅផ្ទះវិញ ។
- ជនរងគ្រោះ ត្រូវជនប្រាំមួយនាក់ជិះម៉ូតូបីគ្រឿងតាមពីក្រោយ មានម្នាក់បានដកកាំភ្លើងខ្លីបាញ់មកលើរូបគាត់មួយគ្រាប់ ។ គ្រាប់កាំភ្លើងបានបុកចំម៉ូតូក្បែរជើងរបស់គាត់ធ្វើឱ្យបំណែកផ្លាតមកចំភ្លៅរបស់គាត់ ។ គាត់បានរាយការណ៍ថា "ជនម្នាក់ក្នុងចំណោមជនមិនស្គាល់មុខទាំងនោះបាននិយាយមកគាត់ថា "យើងតែងធ្វើដូច្នេះ" មុននឹងពួកគេបើកម៉ូតូគេចចេញទៅ ។
- ចំរើន បានដាក់ពាក្យបណ្តឹងជាមួយនឹងប៉ូលីសមូលដ្ឋាន ហើយនឹងតុលាការក្រុងភ្នំពេញ នៅថ្ងៃបន្ទាប់ ។ ប៉ុន្តែរហូតមកដល់ថ្ងៃនេះ មិនទាន់មានរបាយការណ៍ណាមួយស្តីពីការរីកចំរើន

---

[៥៦] របាយការណ៍តាមដានអង្គការលីកាដូ ដែលមិនផ្សព្វផ្សាយ ថ្ងៃទី២០ ខែ តុលា ឆ្នាំ ២០០៦។ សូមមើលផងដែរអត្ថបទចុះផ្សាយនៅក្នុង ការសែត The Cambodia Daily ចុះផ្សាយថ្ងៃទី ៥ ខែកក្កដា ឆ្នាំ ២០០៦ ដែលមានចំណងជើងថា អ្នកធ្វើកូដកម្មបីនាក់ត្រូវបានចោទប្រកាន់ពីបទឃុំខ្លួនបុគ្គលិកជនជាតិចិន *ដោយ ប្រាក់ ចាន់ធុល* ។

[៥៧] របាយការណ៍តាមដានរបស់អង្គការលីកាដូ មិនទាន់បោះពុម្ពផ្សាយ ថ្ងៃទី៥ ខែ កក្កដា ឆ្នាំ ២០០៦។ សូមមើលផងដែរ អត្ថបទចុះផ្សាយនៅក្នុង ព្រឹត្តិបត្រ The Cambodia Daily ចុះផ្សាយថ្ងៃទី ៦ ខែកក្កដា ឆ្នាំ២០០៦ ដែលមានចំណងជើងថា សកម្មជនសហជីពអះអាងថា គាត់ត្រូវបានគេបាញ់ប្រហារ *រងរបួស* ដោយ *ប្រាក់ ចាន់ធុល* ។

នៃករណីនេះនៅឡើយ ។

**ថ្ងៃទី ១ ខែ សីហា**

**ការចាប់ខ្លួនសកម្មជនសហគមន៍ នៅក្នុងរឿងជម្លោះដីធ្លីនៅខេត្តបាត់ដំបង**[៥៨]

- ឈា នី តំណាងអោយអ្នកភូមិចំនួន ៣.១៧០ គ្រួសារ នៅក្នុងរឿងជម្លោះដីធ្លីរយៈពេលវែងមួយនៅស្រុកបវេល ត្រូវបានចាប់ខ្លួនដោយកម្លាំងចម្រុះដែលរួមមាន ប៉ូលីស យោធា និងកងរាជអាវុធហត្ថ ។ គាត់ត្រូវបានចោទប្រកាន់ពីបទរំលោភលើទ្រព្យសម្បត្តិឯកជន និងរំលោភបំពានសិទ្ធិបុគ្គល ។
- ជនពីរនាក់ទៀត ដែលព្យាយាមការពារ ឈា នី ក៏ត្រូវបានចាប់ខ្លួនផងដែរ ។ តែពួកគេត្រូវបានដោះលែងមកវិញនៅថ្ងៃបន្ទាប់ ប៉ុន្តែពួកគាត់ត្រូវបានគេប្រាប់ឱ្យដឹងថាបទចោទនៅតែមានចំពោះគាត់ ។
- យ៉ាងតិចណាស់ក៏មានអ្នកភូមិចំនួនប្រាំពីរនាក់ផ្សេងទៀត រួមទាំងប្រពន្ធរបស់លោក ឈា នី ផងដែរត្រូវរងរបួសក្នុងខណៈដែលពួកគេព្យាយាមទប់ស្កាត់មិនឱ្យមានការចាប់ខ្លួនលោក ឈា នី ។
- នៅថ្ងៃទី ១៣ ខែវិច្ឆិកា បណ្ដឹងឧទ្ធរណ៍របស់លោក ឈា នី ដែលប្ដឹងជំទាស់នឹងការឃុំខ្លួនមុនពេលកាត់ក្ដីរបស់គាត់ត្រូវបានតុលាការឧទ្ធរណ៍បដិសេធ ។ នៅពេលកំពុងសរសេររបាយការណ៍នេះ គាត់កំពុងស្ថិតនៅក្នុងពន្ធនាគារខេត្តបាត់ដំបងនៅឡើយ ។

**ថ្ងៃទី ៣ ខែ សីហា**

**អ្នកតំណាងសហគមន៍ ត្រូវបានចាប់ខ្លួនដាក់ពន្ធនាគារ នៅក្នុងរឿងជម្លោះដីធ្លី នៅខេត្តកំពង់ចាម**[៥៩]

- តាន់ ហេង តំណាងឱ្យអ្នកភូមិ ១៣៣ គ្រួសារ នៅក្នុងស្រុកស្ទឹងត្រង់ ត្រូវបានចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ បន្ទាប់ពីគាត់បានសរសេរសំបុត្រឱ្យមានការតវ៉ាចំពោះក្រុមហ៊ុនចំការកៅស៊ូ ដែលកាប់ឆ្ការព្រៃនៅលើដីមានជម្លោះរួចមក ។
- ប៉ុន្មានថ្ងៃមុនការចាប់គាត់ ជនរងគ្រោះបានធ្វើដំណើរមកភ្នំពេញ ដើម្បីនាំយកការកង្វល់របស់អ្នកភូមិមកថ្វាយអតីតព្រះមហាវរក្សត្រ នរោត្តម សីហនុ ។
- គាត់ត្រូវបានដោះលែងនៅថ្ងៃទី៧ ខែសីហា ជាមួយនឹងអ្នកភូមិទីពីរ ដែលបានចាប់ដាក់ពន្ធនាគារក្នុងរឿងទំនាស់ដីធ្លីនេះដែរ បន្ទាប់ពីបានបង្ខិតបង្ខំអោយផ្តិតមេដៃលើឯកសារបោះបង់ចោលការទាមទារដីរបស់គាត់រួចមក ។ នៅពេលកំពុងសរសេររបាយការណ៍នេះ បទចោទប្រកាន់មកលើរូបគាត់នៅមាននៅឡើយ ។

---

[៥៨] របាយការណ៍តាមដានរបស់លីកាដូ មិនផ្សព្វផ្សាយ ថ្ងៃទី២៣ ខែ តុលា ឆ្នាំ ២០០៦ ។ សូមមើលផងដែរ ករណីសិក្សាៈ ឈា នី និង *ជម្លោះដីធ្លីនៅស្រុកបវេល* នៅត្រង់វគ្គ III នៃរបាយការណ៍នេះ សំរាប់ព័ត៌មានបន្ថែម ។

[៥៩] របាយការណ៍តាមដានលីកាដូ មិនផ្សព្វផ្សាយ ថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ។ សូមមើលផងដែរអត្ថបទចុះផ្សាយនៅក្នុង ព្រឹត្តបត្រ The Cambodia Daily ចុះផ្សាយថ្ងៃទី ៥-៦ ខែសីហា ឆ្នាំ២០០៦ ដែលមានចំណងជើងថា អ្នកភូមិអំពាវនាវអោយដោះលែងអ្នក តំណាង *ដោយប្រាក់ ចាន់ធុល* ហើយនឹងអត្ថបទចុះផ្សាយជាបន្តបន្ទាប់ ហើយនឹង ករណីសិក្សាៈ *តាន់ ហេង និង ជម្លោះដីធ្លីនៅចំការកៅស៊ូបឹងកេត* នៅត្រង់វគ្គ III នៃរបាយការណ៍នេះ ។

**ថ្ងៃទី ៥ ខែ សីហា**

**អ្នកតំណាងសហគមន៍ ត្រូវបានចាប់ខ្លួនដាក់ពន្ធនាគារ នៅក្នុងរឿងតវ៉ាក្នុងជម្លោះដីធ្លី នៅខេត្តកណ្តាល**[៦០]

- អ៊ិន សៀង អ្នកតំណាងអោយសហគមន៍ និងជាសកម្មជនគណបក្សជំទាស់នៅឃុំពុនសាំង ស្រុកអង្គស្នួល ត្រូវបានចាប់ខ្លួនតាមដីកាពីតុលាការខេត្តកណ្តាល ។ កាលពីមុនគាត់ធ្លាប់ដឹកនាំអ្នកភូមិឱ្យតវ៉ាក្រុមហ៊ុនមួយកុំឱ្យសាងសង់របងព័ទ្ធជុំវិញដីដែលមានជម្លោះ ។
- គាត់ត្រូវបានចោទប្រកាន់ពីបទរំលោភលើកម្មសិទ្ធិឯកជន ហើយក៏ត្រូវបានបញ្ជូនខ្លួនមកពន្ធនាគារខេត្តកណ្តាល ។
- ការចាប់ខ្លួនរបស់គាត់បានធ្វើឱ្យផ្ទុះឡើងនូវការតវ៉ាដោយអ្នកភូមិចំនួន ៣០០ នាក់នៅថ្ងៃទី ៧ ខែសីហា នៅទីក្រុងភ្នំពេញ តែត្រូវបានបំបែកដោយកម្លាំងប៉ូលីសលើកុប្បកម្ម ដោយបង្កឱ្យមានអំពើហិង្សាទាំងសងខាង ។ គាត់ត្រូវបានដោះលែង នៅថ្ងៃទី ៦ ខែតុលា បន្ទាប់ពីមានការអន្តរាគមន៍ដោយសមាជិកតំណាងរាស្ត្រនៃគណបក្សជំទាស់ ។

**ថ្ងៃទី៣១ ខែ សីហា**

**សកម្មជនសហគមន៍ ត្រូវបានចាប់ខ្លួនដាក់ពន្ធនាគារ បន្ទាប់ពីការតវ៉ានៅក្នុងរឿងជម្លោះដីធ្លី នៅខេត្តបន្ទាយមានជ័យ**[៦១]

- សកម្មជនសហគមន៍ប្រាំមួយរូប នៅភូមិអណ្តូងថ្ម ឃុំប៉ោយប៉ែត ស្រុកអូជ្រៅ ត្រូវបានចាប់ខ្លួន និងវាយដំដោយនគរបាល និងកម្លាំងកងរាជអាវុធហត្ថក្នុងកំឡុងពេលនៃការបណ្តេញចេញមួយប្រកបដោយអំពើហិង្សាទៅលើអ្នកភូមិចំនួន ២៧ គ្រួសារ ដោយការរំលោភយកដីធ្លីពីសំណាក់មន្ត្រីយោធា ។
- សកម្មជនសហគមន៍ពីររូប ត្រូវបានដោះលែងបន្ទាប់ពីបានឃាត់ខ្លួនអស់រយៈពេល៤៨ ម៉ោងមក ចំណែកបួននាក់ទៀត ត្រូវបានឃុំខ្លួននៅពន្ធនាគារ ដោយចោទពីបទរំលោភលើព្រៃឡសម្បត្តិឯកជន ។
- ជនទាំងបួននាក់ត្រូវបានដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន នៅថ្ងៃទី១២ ខែកញ្ញា បន្ទាប់ពីមានការអន្តរាគមន៍ដោយគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសិទ្ធិមនុស្សកម្ពុជា ។ ចំណែកបទចោទប្រកាន់នៅតែមាននៅឡើយ ។

**ថ្ងៃទី៣១ ខែ សីហា**

**បុរសម្នាក់ត្រូវចាប់ខ្លួន បន្ទាប់ពីបានជួយអ្នកស្វែងរកសិទ្ធិជ្រកកោន**[៦២]

- គង់ សុខ ជាពលរដ្ឋកម្ពុជាកើតនៅតំបន់កម្ពុជាក្រោម នៃប្រទេសវៀតណាម រស់នៅក្នុងប្រទេសកម្ពុជា បានត្រូវនាំខ្លួនចេញពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននៅភ្នំពេញ ដោយប៉ូលីសក្រសួងមហាផ្ទៃ ។

---

[៦០] របាយការណ៍តាមដានលីកាដូ មិនផ្សព្វផ្សាយ ថ្ងៃទី៧ ខែ សីហា ឆ្នាំ ២០០៦ ។

[៦១] របាយការណ៍តាមដានលីកាដូ មិនផ្សព្វផ្សាយ ថ្ងៃទី១៩ ខែ តុលា ឆ្នាំ ២០០៦ ។

[៦២] របាយការណ៍តាមដានលីកាដូ មិនផ្សព្វផ្សាយ ថ្ងៃទី២០ ខែ តុលា ឆ្នាំ ២០០៦ ។ សូមមើលផងដែរអត្ថបទចុះផ្សាយនៅក្នុង ព្រឹត្តបត្រ The Cambodia Daily ចុះផ្សាយថ្ងៃទី ៩-១០ ខែសីហា ឆ្នាំ២០០៦ ដែលមានចំណងជើងថា ប៉ូលីសកំពុងស៊ើបអង្កេតលើការរត់ពន្ធ អ្នក ស្វែងរកសិទ្ធិជ្រកកោន *ដោយផាន់ អាណា* ។

- គាត់ត្រូវបានចាប់ខ្លួនពីបទការរំលោភច្បាប់អន្តោប្រវេសន៍ ក្រោយពីគាត់បានអមដំណើរជនម៉ុងតាញ៉ាបីនាក់ ដែលស្វែងរកសិទ្ធិជ្រកកោន (ដែលពួកគេចូលមកកម្ពុជាពីប្រទេសវៀតណាមដោយខ្លួនគេផ្ទាល់) នៅការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ដើម្បីដាក់ពាក្យសុំឋានៈជាជនភៀសខ្លួន។
- នៅថ្ងៃទី១ ខែធ្នូ គាត់ត្រូវបានកាត់ទោសដោយតុលាការក្រុងភ្នំពេញពីបទរំលោភបទប្បញ្ញត្តិច្បាប់អន្តោប្រវេសន៍ "តាមរយៈការជួយឬលាក់កំបាំង" ជនបរទេសចូលមកក្នុងប្រទេសកម្ពុជាដោយខុសច្បាប់។ គាត់ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារចំនួន ៣ ខែ។

**ថ្ងៃទី ៤ ខែ កញ្ញា**

**សកម្មជនសហគមន៍ច្រើននាក់ទៀត ត្រូវបានជាប់ពន្ធនាគារក្នុងជម្លោះដីធ្លី នៅខេត្តបាត់ដំបង**[៦៣]

- ហែម ឡាក់ និង មូ សាប់ ជាសកម្មជនក្នុងរឿងទំនាស់ដីធ្លីនៅស្រុកបវេល ជាមួយនឹងលោកឈា នី (សូមអានត្រង់ *ការចាប់ខ្លួន ថ្ងៃទី១ ខែសីហា*) ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅពន្ធនាគារខេត្តបាត់ដំបង។
- ក្នុងកំឡុងពេលសរសេររបាយការណ៍នេះ ជនទាំងពីរនាក់កំពុងស្ថិតនៅក្នុងពន្ធនាគារនៅឡើយ ហើយពាក្យបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្នមុនពេលកាត់ក្តីរបស់ពួកគាត់ក៏មិនទាន់បានដំណឹងពីសាលាឧទ្ធរណ៍នៅឡើយ។
- មូ សាប់ ជាអ្នកភូមិម្នាក់ដែលមានអាយុ ៧៨ ឆ្នាំទៅហើយ កំពុងមានជម្ងឺជាទម្ងន់នៅក្នុងពន្ធនាគារ។
- បុរសទីបី ឈ្មោះ តៀម តួយ ក៏ត្រូវបានចាប់ខ្លួនផងដែរ ប៉ុន្តែត្រូវបានដោះលែងមកវិញក្នុងរយៈពេលខ្លីក្រោយពីការចាប់ខ្លួន។

**ថ្ងៃទី ៩ ខែកញ្ញា**

**អ្នកការសែត ទទួលការគំរាមកំហែងដល់ជីវិត បន្ទាប់ពីធ្វើការស៊ើបអង្កេតករណីទៅលើមន្ត្រីពុករលួយ**[៦៤]

- សយ សុភាព អ្នកធ្វើសេចក្តីរាយការណ៍ព័ត៌មានឱ្យទូរទស្សន៍ ស៊ី ធី អ៊ិន ទទួលការគំរាមកំហែងដល់ជីវិតជាលាយលក្ខណ៍អក្សរ ។ លិខិតអនាមិកមួយត្រូវបានយកមកទុកឱ្យគាត់នៅហាងកាហ្វេមួយនៅទីក្រុងភ្នំពេញ ដែលអ្នកកាសែតនិយមចូលចិត្តទៅទីនោះ ដោយសរសេរថា "យើងទុកលិខិតនេះសំរាប់ឯង អាំ សុភាព... ប្រយ័ត្តខ្លួន បើឯងហ៊ានិរិះគន់ផ្កាយ៧ (ឧត្តមសេនីយ) គឺវាមានន័យថាស្លាប់"។
- ជនរងគ្រោះកំណត់ថា ការគំរាមកំហែងនេះ អាចបណ្តាលមកពីការធ្វើសេចក្តីរាយកាណ៍ថ្មីមួយ ដែលលាតត្រដាងរឿងការចាប់រំលោភយកដីធ្លី និងការរត់ពន្ធរថយន្តដែលទាក់ទិននឹង

---

៦៣ របាយការណ៍តាមដានលីកាដូ មិនផ្សព្វផ្សាយ ថ្ងៃទី២៣ ខែ តុលា ឆ្នាំ ២០០៦។ សូមមើលផងដែរ អត្ថបទចុះផ្សាយនៅក្នុងព្រឹត្តបត្រCambodia Daily ចុះផ្សាយថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០០៦ ដែលមានចំណងជើងថា អ្នកភូមិប្រាំពីនាក់ត្រូវបានឃាត់ខ្លួន ចំពោះរឿង ជម្លោះដីធ្លី *ដោយពិន ស៊ីសុវណ្ណ* និងករណីសិក្សា: ឈា នី និង *ជម្លោះដីធ្លីនៅស្រុកបវេល* នៅត្រង់វគ្គ III នៃរបាយការណ៍នេះ សំរាប់ព័ត៌មាន បន្ថែម។

៦៤ *អ្នកកាសែត ទទួលការគំរាមកំហែងដល់ជីវិត ចំពោះការធ្វើរបាយការណ៍រឿងអំពើពុករលួយ* សេចក្តីថ្លែងការដោយអ្នកយការណ៍ គ្មានព្រំដែន ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៦ ។ សូមមើលផងដែរ អត្ថបទចុះផ្សាយនៅក្នុងព្រឹត្តបត្រ The Cambodia Daily ចុះផ្សាយថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៦ ដែលមានចំណងជើងថា ការសរសេរសារគំរាមកំហែងដល់ជីវិតចំពោះអ្នកធ្វើសេចក្តីរាយការណ៍តាមទូរទស្ស *ដោយ ពិន ស៊ីសុវណ្ណ* ។

មន្ត្រីដែលមានអំណាច ។

- នៅថ្ងៃទី៣ ខែសីហា កម្មវិធីរបស់សុភាព "កម្ពុជាថ្ងៃនេះ" ត្រូវបានលុបចោល បន្ទាប់ពីមានការរិះគន់ដោយនាយករដ្ឋមន្ត្រី ចំពោះអត្ថបទនិយាយអំពីរបាយការណ៍សេដ្ឋកិច្ច ស្តីពីរឿងពុករលួយនៅកម្ពុជា ។

**ថ្ងៃទី១៩ ខែកញ្ញា**

**មេដឹកនាំសហជីពត្រូវបានវាយប្រហារនៅទីក្រុងភ្នំពេញ**[៦៥]

- ចយ ជីន អគ្គលេខាធិការនៃសហជីពសេរីកម្មករនៃរោងចក្រ សាន់ថិចហ្គាមិន ហ្វែកតូរី ត្រូវបានវាយប្រហារដោយជនមិនស្គាល់មុខពីរនាក់ដែលបានគប់ដុំថ្មមកលើរូបគាត់ ព្រមទាំងវាយក្បាល និងដៃរបស់គាត់ដោយប្រើបំពង់ដែកទីប ។
- ជនរងគ្រោះ គឺជាអ្នកតំណាងទីពីរនៃរោងចក្រសាន់ថិច ដែលទទួលរងការបង្ករបួសស្នាមក្នុងឆ្នាំ២០០៦ បន្ទាប់ពីមានការវាយប្រហារកាលពីថ្ងៃទី១៩ ខែឧសភា ទៅលើ ជ័យ រិទ្ធី កន្លងមក ។

**ថ្ងៃទី ២០ ខែកញ្ញា**

**បុគ្គលិកសិទ្ធិមនុស្សត្រូវបានរារាំងរំខានពីការតាមដាន ទៅលើការធ្វើបាតុកម្មមួយក្នុងរឿងទំនាស់ដីធ្លីដោយហិង្សា នៅខេត្តកោះកុង**[៦៦]

- បុគ្គលិកសិទ្ធិមនុស្សនៃអង្គការមិនមែនរដ្ឋាភិបាលត្រូវបានរារាំងមិនឱ្យតាមដានទៅលើសកម្មភាពនៃការធ្វើបាតុកម្មដោយប្រជុំមួយពាក់ព័ន្ធនឹងសមាជិកសហគមន៍ចំនួន ៣០០ នាក់ នៅភូមិឈ្យូក ឃុំជីកខលើ ស្រុកស្រែអំបិល ។
- ការតវ៉ាស្រដៀងគ្នានេះនៅក្នុងភូមិ កាលពីប៉ុន្មានថ្ងៃមុន ត្រូវបានបំបែកដោយអំពើហិង្សា ដោយធ្វើឱ្យស្ត្រីម្នាក់ត្រូវរបួសដោយគ្រាប់កាំភ្លើង ហើយអ្នកតវ៉ាបួននាក់ផ្សេងទៀតត្រូវបានវាយដំ និងពីរនាក់ទៀតត្រូវចាប់ខ្លួន ។

**ថ្ងៃទី២៩ ខែ កញ្ញា**

**សកម្មជនសហគមន៍ត្រូវជាប់ពន្ធនាគារនៅក្នុងរឿងជម្លោះដីធ្លី នៅខេត្តរតនៈគីរី**[៦៧]

- ទូច ឈុនលី អ្នកតំណាងឱ្យគ្រួសារជនជាតិភាគតិចចំនួន ២៧ គ្រួសារ នៅឃុំឡាបានសៀក ស្រុកបានលុង ត្រូវបានចាប់ខ្លួនដោយនគរបាលខេត្ត ហើយត្រូវបានឃុំខ្លួននៅពន្ធនាគារខេត្តរតនៈគីរី ដោយចោទពីបទលក់ដីដោយខុសច្បាប់ ។
- ដីដែលមានទំនាស់ ត្រូវបានកាន់កាប់ដោយគ្រួសារជនជាតិតាំងពីឆ្នាំ១៩៨៦ ប៉ុន្តែក៏មានការទាមទារដោយគណបក្សប្រជាពលរដ្ឋកម្ពុជាផងដែរ ដោយមានផែនការសាងសង់សាលាប្រជុំរបស់គណបក្សនៅលើដីនោះ ។ ជម្លោះដែលមានរយៈពេល៧ឆ្នាំមកហើយនេះ នៅតែមានក្នុងតុលាការរហូតមក ។

---

[៦៥] ICFTU សេរីភាពសមាគមៈ ករណីលេខ ២៣១៨ (កម្ពុជា) (ព័ត៌មានបន្ថែម), លិខិតបើកចំហមកកាន់អង្គការ ILO ចុះថ្ងៃទី ៣ ខែតុលា ២០០៦

[៦៦] របាយការណ៍តាមដានរបស់អង្គការលីកាដូមិនទាន់បោះពុម្ពផ្សាយ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ។

[៦៧] បទសម្ភាសន៍ជាមួយគំរោងអ្នកការពារក្តីកម្ពុជា ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៦ ។ សូមមើលផងដែរ អត្ថបទចុះផ្សាយនៅក្នុងព្រឹត្តិបត្រ The Cambodia Daily ចុះផ្សាយថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៦ ដែលមានចំណងជើងថា អ្នកភូមិនៅក្នុងខេត្តរតនៈគីរី ត្រូវបានចោទប្រកាន់ពីបទលក់ដី ដោយខុសច្បាប់ *ដោយគុច ណារ៉េន* ។

- បទចោទប្រកាន់ទៅលើ ឈុនលី គឺពាក់ព័ន្ធទៅនឹងឧប្បត្តិហេតុកើតឡើងក្នុងឆ្នាំ២០០៣ នៅពេលដែលជនរងគ្រោះត្រូវបានគេរាយការណ៍ថា បានលក់ដីមួយចំណែករបស់ខ្លួន ដើម្បីបង់ថ្លៃព្យាបាលក្រោយពីទទួលរងគ្រោះថ្នាក់ចរាចរណ៍។
- ក្នុងពេលធ្វើរបាយការណ៍នេះ ជនរងគ្រោះនៅជាប់ពន្ធនាគារនៅឡើយ ចំណែកបណ្តឹងឧទ្ធរណ៍របស់គាត់ប្តឹងជំទាស់នឹងការឃុំខ្លួនក៏ត្រូវបានព្យួរជារហូតមក។

**ថ្ងៃទី១២ ខែតុលា**

**បុគ្គលិកសិទ្ធិមនុស្សត្រូវបានឃាត់ខ្លួន បន្ទាប់ពីធ្វើការចែកចាយសម្ភារៈប្រឆាំងនឹងអំពើពុករលួយ នៅទីក្រុងភ្នំពេញ**[៦៨]

- បុគ្គលិកនៃមជ្ឈមណ្ឌលដើម្បីការអភិវឌ្ឍ និងសន្តិភាពប្រជាពលរដ្ឋ ដែលជាអង្គការមិនមែនរដ្ឋាភិបាល (មជ្ឈមណ្ឌលភីឌីភី) ត្រូវបានបញ្ឈប់ដោយអាជ្ញាធរនៅផ្សារតឹឡូម៉ែត្រលេខ៦ ក្នុងខ័ណ្ឌឫស្សីកែវ ក្នុងពេលកំពុងចែកចាយសម្ភារៈសំរាប់ធ្វើយុទ្ធនាការប្រឆាំងអំពើពុករលួយ ដែលមានខ្លឹមសារថា "បាតដៃស្អាតស្អំ" ដែលគាំទ្រដោយអង្គការផែក(PACT)។
- ដំបូង បុគ្គលិកត្រូវបានបញ្ជូនទៅកាន់ការិយាល័យខណ្ឌ ហើយបន្ទាប់មកក៏បញ្ជូនទៅកាន់ការិយាល័យនគរបាលខណ្ឌ ដែលនៅទីនោះពួកគេត្រូវឃាត់ខ្លួនអស់រយៈពេលប្រមាណ៤ម៉ោង និងបានឱ្យធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាពឃោសនាតទៅទៀត មុននឹងត្រូវបានដោះលែង។

**ថ្ងៃទី ១៦ ខែ តុលា**

**មេដឹកនាំសហជីព ត្រូវបានគំរាមកំហែង និងវាយដំក្នុងពេលធ្វើកូដកម្ម**[៦៩]

- អ៊ឹម ចៃឡេង អនុប្រធានសហជីពសេរីកម្មករនៅរោងចក្រប្រាយស្ពាយ នៅក្នុងខណ្ឌដង្កោ ត្រូវបានដាល់ចំមុខ និងគំរាមថា នឹងចាប់ខ្លួន ក្នុងពេលកំពុងធ្វើកូដកម្មនៅរោងចក្រនេះ ដែលត្រូវបានបំបែកដោយកម្លាំងប៉ូលិសដោយប្រើអំពើហិង្សា។
- ក្នុងពេលបំបែកកូដកម្ម ដែលកូដកម្មនេះធ្វើឡើងដើម្បីគាំទ្រដល់ ជី សាម៉ុន ដែលជាមេដឹកនាំសហជីពសេរីកម្មករ ដែលទទួលរងការគំរាមកំហែង មានកម្មកររោងចក្រជាច្រើនផ្សេងទៀតត្រូវបានវាយដំ និងឆក់ដោយដំបងប្រើភ្លើងអេឡិចត្រិច មានកម្មការនីម្នាក់រងការបាញ់ត្រូវពោះ ។
- បន្ទាប់ពីកូដកម្ម និងក្រោយពីបាត់បង់ការងារនៅរោងចក្រ ប្រាយស្ពាយ អ៊ឹម ចៃឡេង និង ជី សាម៉ុន ត្រូវបានចុះក្នុងបញ្ជីខ្មៅ ដែលជាឧបសគ្គក្នុងការស្វែងរកការងារនៅតាមរោងចក្រផ្សេងទៀត។

---

[៦៨] បទសម្ភាសន៍ជាមួយមជ្ឈមណ្ឌល ភីឌីភី ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៦។

[៦៩] របាយការណ៍តាមដានរបស់អង្គការលីកាដូ មិនទាន់បោះពុម្ពផ្សាយ ថ្ងៃទី៣ ខែ វិច្ឆិកា ឆ្នាំ២០០៦ ។ សូមមើលផងដែរ ករណីសិក្សា: មេដឹកនាំសហជីពសេរីកម្មករ នៅរោងចក្រប្រាយស្ពាយ និងសាន់ថិច នៅត្រង់វគ្គ III នៃរបាយការណ៍នេះ សំរាប់ជាព័ត៌មានបន្ថែម។

| | |
|---|---|
| **ថ្ងៃទី២៦ ខែតុលា** | **បុគ្គលិកសិទ្ធិមនុស្ស ត្រូវបានឃាត់ខ្លួន បន្ទាប់ពីធ្វើការចែកចាយសម្ភារៈប្រឆាំងនឹងអំពើពុករលួយ នៅទីក្រុងភ្នំពេញ[៧០]**<br>• បុគ្គលិកនៃមជ្ឈមណ្ឌលដើម្បីការអភិវឌ្ឍ និងសន្តិភាពប្រជាពលរដ្ឋ ដែលជាអង្គការមិនមែនរដ្ឋាភិបាល (មជ្ឈមណ្ឌលភីឌីភី) ត្រូវបានបញ្ឈប់ដោយនគរបាលនៅផ្សារទឹកថ្លា ក្នុងខណ្ឌឫស្សីកែវ ក្នុងពេលកំពុងចែកចាយសម្ភារៈសំរាប់ធ្វើយុទ្ធនាការប្រឆាំងអំពើពុករលួយដែលមានខ្លឹមសារថា "បាតដៃស្អាតស្អំ"។<br>• បុគ្គលិកត្រូវបាននាំខ្លួនទៅកាន់ការិយាល័យប៉ូលីសប្រចាំផ្សារ ឃាត់ខ្លួនប្រហែល២ម៉ោង ហើយសម្ភារៈត្រូវបានរឹបអូស។ |
| **ថ្ងៃទី ២៩ ខែតុលា** | **បុគ្គលិកសិទ្ធិមនុស្សត្រូវបានឃាត់ខ្លួន បន្ទាប់ពីធ្វើការចែកចាយសម្ភារៈប្រឆាំងនឹងអំពើពុករលួយ នៅទីក្រុងភ្នំពេញ[៧១]**<br>• បុគ្គលិកនៃមជ្ឈមណ្ឌលដើម្បីការអភិវឌ្ឍ និងសន្តិភាពប្រជាពលរដ្ឋ ដែលជាអង្គការមិនមែនរដ្ឋាភិបាល(មជ្ឈមណ្ឌលភីឌីភី) ត្រូវបានបញ្ឈប់ដោយនគរបាលនៅសង្កាត់ចតុមុខក្នុងខណ្ឌដូនពេញ ខណៈពេលកំពុងចែកចាយសម្ភារៈសំរាប់ធ្វើយុទ្ធនាការប្រឆាំងអំពើពុករលួយដែលមានខ្លឹមសារថា "បាតដៃស្អាតស្អំ" ។<br>• បុគ្គលិកត្រូវបាននាំខ្លួនទៅកាន់ប៉ុស្តិប៉ូលីសខណ្ឌ ឃាត់ខ្លួនប្រហែល ២ ទៅ ៣ ម៉ោង ហើយសម្ភារៈត្រូវបានរឹបអូស។ |

[៧០] បទសម្ភាសន៍ជាមួយមជ្ឈមណ្ឌល ភីឌីភី ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០០៦។

[៧១] ibid

# សេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវ
# របស់បុគ្គល ក្រុម និងអង្គការសង្គម ក្នុងការលើកស្ទួយ និងការពារ
# សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដែលត្រូវបានទទួលស្គាល់ជាសកល

អនុម័តដោយមហាសន្និបាត
តាមសេចក្តីសម្រេចចិត្តលេខ ៥៣/១៤៤ ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ១៩៩៨

***មហាសន្និបាត***

*បញ្ជាក់ឡើងវិញ* នូវសារសំខាន់នៃការអនុវត្តទិសដៅ និងគោលការណ៍នៃធម្មនុញ្ញសហប្រជាជាតិ ដើម្បីលើកស្ទួយនិងការពារសិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋាន ទាំងអស់សំរាប់មនុស្សទាំងអស់ នៅក្នុងប្រទេសទាំងអស់នៃពិភពលោក។

*បញ្ជាក់ឡើងវិញផងដែរ* នូវសារសំខាន់នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស សេចក្តីសំរេចចិត្តលេខ ២២00 A (XXI) ឧបសម្ព័ន្ធ ជាកត្តាមូលដ្ឋាននៃកិច្ចខិតខំជាអន្តរជាតិ ដើម្បីលើកស្ទួយការគោរព និងការអនុវត្តជា សកលនូវសិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋាន និង

*បញ្ជាក់ឡើងវិញផងដែរ* នូវសារសំខាន់នៃលិខិតុបករណ៍សិទ្ធិមនុស្សផ្សេងទៀត ដែលអនុម័តក្នុងក្របខ័ណ្ឌសហប្រជាជាតិ និងក្នុងក្របខ័ណ្ឌទាំងឡាយនៅថ្នាក់តំបន់។

*សង្កត់ធ្ងន់ថា* សមាជិកទាំងអស់នៃសហគមន៍អន្តរជាតិ ត្រូវបំពេញកាតព្វកិច្ចដ៏ឱឡារិករបស់ខ្លួនដោយរួមគ្នា និងដោយឡែកពីគ្នា ដើម្បីលើកស្ទួយ និងលើកទឹកចិត្តដល់ការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានសម្រាប់ទាំងអស់គ្នា ដោយគ្មានការប្រកាន់បែងចែកប្រភេទណាមួយ រួមមានការប្រកាន់បែងចែកដែលផ្អែកលើ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ប្រភពសញ្ជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬឋានៈផ្សេងទៀតផង និង

*បញ្ជាក់ឡើងវិញ* នូវសារសំខាន់ ពិសេសនៃការ ធ្វើឱ្យសំរេចបាននូវសហប្រតិបត្តិការអន្តរជាតិ ដើម្បីបំពេញកាតព្វកិច្ចនេះ ស្របតាមធម្មនុញ្ញសហប្រជាជាតិ។

*ទទួលស្គាល់* នូវតួនាទីសំខាន់នៃសហប្រតិបត្តិការអន្តរជាតិ និងការងារដ៏មានតម្លៃនៃបុគ្គល ក្រុម និងសមាគម ក្នុងការរួមចំណែកលុបបំបាត់ដោយស័ក្តិសិទ្ធិនូវរាល់ការរំលោភសិទ្ធិមនុស្ស និងសេរី

ភាពមូលដ្ឋានរបស់ប្រជាជាតិ និងបុគ្គល រួមមានពាក់ព័ន្ធទៅនឹងការរំលោភដោយមហាជន ដោយជាក់ស្តែង ឬដោយរៀបចំហ្មត់ចត់ ដូចជាការរំលោភដែលបណ្តាលមកពីនយោបាយអាប៉ាថេតផង រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អាណានិគមនិយម ការគាបសង្កត់ ឬការកាន់កាប់របស់បរទេស ការឈ្លានពាន ឬការគំរាមកំហែងអធិបតេយ្យជាតិ ឯកភាពជាតិ ឬបូរណភាពដែនដី និងដែលបណ្តាលមកពីការបដិសេធមិនទទួលស្គាល់ សិទ្ធិស្វ័យសម្រេចរបស់ប្រជាជាតិ និងសិទ្ធិប្រជាជាតិនីមួយៗ ក្នុងការប្រើប្រាស់អធិបតេយ្យភាពពេញលេញលើភោគទ្រព្យ និងធនធានធម្មជាតិរបស់ខ្លួន។

*ទទួលស្គាល់ថា* ទំនាក់ទំនងរវាងសន្តិភាព និងសន្តិសុខអន្តរជាតិ និងការអាស្រ័យផលនៃសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន *និងគិតថា* ការគ្មានសន្តិភាពនិងសន្តិសុខអន្តរជាតិ មិនមែនជាការសំអាងសម្រាប់លើកលែងការមិនអនុវត្តឡើយ។

*ប្រកាសឡើងវិញថា* សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់ មានលក្ខណៈសកល មិនអាចចែកដាច់ពីគ្នា អាស្រ័យគ្នាទៅវិញទៅមក និងទាក់ទងគ្នាទៅវិញទៅមក ហើយត្រូវលើកស្ទួយ និងអនុវត្តក្នុងលក្ខណៈត្រឹមត្រូវ និងប្រកបដោយសមធម៌ ដោយមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តសិទ្ធិ និងសេរីភាពនីមួយៗ ទាំងនោះឡើយ។

*សង្កត់ធ្ងន់ថា* ការទទួលខុសត្រូវ និងករណីយកិច្ចមុនគេបង្អស់ ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន គឺជាបន្ទុករបស់រដ្ឋ។

*ទទួលស្គាល់* សិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងសមាគម ក្នុងការលើកស្ទួយការគោរពនិង ការបណ្តុះបណ្តាលឱ្យមានការយល់ដឹងអំពីសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាននៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។

***ប្រកាស :***

## មាត្រា ១

ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗ និងដោយរួមជាមួយអ្នកដទៃ ក្នុងការលើកស្ទួយ និងការខំប្រឹងប្រែងការពារនិងធ្វើឱ្យសម្រេចបាននូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាននៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។

## មាត្រា ២

១. រដ្ឋនីមួយៗ មានការទទួលខុសត្រូវ និងករណីយកិច្ចមុនគេបង្អស់ក្នុងការការពារ ការលើកស្ទួយ និងការអនុវត្តសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់ ដោយការការអនុម័ត ជាអាទិ៍នូវវិធានការដែលអាចចាំបាច់ ដើម្បីបង្កើតរាល់ល័ក្ខខ័ណ្ឌចាំបាច់ក្នុងវិស័យសង្គមកិច្ច សេដ្ឋកិច្ច នយោបាយ និងវិស័យផ្សេងទៀត ព្រមទាំងការធានាខាងផ្លូវច្បាប់ដែលចាំបាច់ ដើម្បីធានាឱ្យជនគ្រប់រូប ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ អាចទទួលបានសិទ្ធិ និងសេរីភាពទាំងអស់នោះ ក្នុងការអនុវត្តជាក់ស្តែង។

២. រដ្ឋនីមួយៗ ត្រូវអនុម័តវិធានការខាងច្បាប់ រដ្ឋបាល និងវិធានការផ្សេងទៀត ដែលចាំបាច់ ដើម្បីធានាថា សិទ្ធិ និងសេរីភាព ដែលចែងក្នុងសេចក្តីប្រកាសនេះ ត្រូវបានធានាដោយស័ក្តិសិទ្ធិ។

## មាត្រា ៣

ច្បាប់ក្នុងប្រទេស ដែលស្របនឹងធម្មនុញ្ញសហប្រជាជាតិ និងកាតព្វកិច្ចអន្តរជាតិផ្សេងៗទៀតរបស់រដ្ឋក្នុងវិស័យសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន គឺជាក្របខ័ណ្ឌច្បាប់ ដែលនៅក្នុងនោះ សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានត្រូវតែបានអនុវត្ត និងប្រើប្រាស់ ហើយដែលនៅក្នុងនោះ សកម្មភាពទាំងអស់ ដែលមានចែងក្នុងសេចក្តីប្រកាសនេះ ដើម្បីលើកស្ទួយ ការពារ និងធ្វើឱ្យសម្រេចបានដោយសក្តិសិទ្ធិនូវសិទ្ធិ និងសេរីភាពទាំងនេះ ត្រូវបានធ្វើឡើង។

## មាត្រា ៤

គ្មានបទបញ្ញត្តិណាមួយនៅក្នុងសេចក្តីប្រកាសនេះ ត្រូវយកមកបកស្រាយ តម្រូវឱ្យខូចខាត ឬជំទាស់គោលបំណង និងគោលការណ៍នៃធម្មនុញ្ញសហប្រជាជាតិ ឬតម្រូវឱ្យដាក់កំហិត ឬធ្វើបដិប្បញ្ញត្តិលើខទាំងឡាយនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍ និងកិច្ចសន្យាអន្តរជាតិផ្សេងទៀត ដែលក្នុងវិស័យនេះឡើយ។

## មាត្រា ៥

ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ជនគ្រប់រូបមានសិទ្ធិ ដោយម្នាក់ឯង និងដោយរួមជាមួយអ្នកដទៃ នៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ :

(ក) ជួប ឬប្រជុំដោយសន្តិវិធី ។

(ខ) បង្កើត ចូលជាសមាជិក និងចូលរួមក្នុងអង្គការក្រៅរដ្ឋាភិបាល សមាគម ឬក្រុម ។

(គ) ឆ្លើយឆ្លងជាមួយអង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តររដ្ឋាភិបាល ។

## មាត្រា ៦

ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ :

(ក) ដឹង ស្វែងរក យកបាន ទទួល និងរក្សាព័ត៌មានស្តីពីសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់ រួមមានការទទួលបាននូវព័ត៌មានស្តីពីរបៀបផ្តល់អនុភាពដល់សិទ្ធិ និងសេរីភាពទាំងនោះផង ក្នុងប្រព័ន្ធច្បាប់ តុលាការ ឬរដ្ឋបាលនៅក្នុងប្រទេស ។

(ខ) បោះពុម្ព ចែកចាយ ឬផ្សព្វផ្សាយដោយសេរីទៅកាន់អ្នកដទៃទៀត អំពីទស្សនៈ ព័ត៌មាន និងការយល់ដឹងស្តីពីសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់ ដូចមានចែងក្នុងលិខិតុបករណ៍សិទ្ធិមនុស្ស និងលិខិតុករណ៍អន្តរជាតិសមស្របផ្សេងទៀត ។

(គ) សិក្សា ពិភាក្សា បង្កើត និងមានលើការប្រតិបត្តិ ទាំងក្នុងច្បាប់ និងការអនុវត្តនូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់ និងទាក់ទាញការយកចិត្តទុកសាធារណៈជនទៅលើបញ្ហាទាំងនោះ តាមរយៈមធ្យោបាយទាំងនេះ និងមធ្យោបាយសមស្របផ្សេងទៀត ។

## មាត្រា ៧

ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ បណ្តុះ និងពិភាក្សាគំនិត និងគោលការណ៍ថ្មីៗ ស្តីពីសិទ្ធិមនុស្ស និងតស៊ូមតិឱ្យមានការព្រមទទួលយកគំនិត និងគោលការណ៍ថ្មីៗទាំងនេះ ។

## មាត្រា ៨

១. ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ ដោយគ្មានការរើសអើង ក្នុងការចូលរួមជាក់ស្តែងក្នុងការគ្រប់គ្រងប្រទេសរបស់ខ្លួន និងការដឹកនាំកិច្ចការសាធារណៈ ។

២. សិទ្ធិនេះរាប់បញ្ចូលជាអាទិ៍ សិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ ដាក់ជូនស្ថាប័ន និងទីភ្នាក់ងាររដ្ឋាភិបាល និងអង្គការនានាទទួលបន្ទុកកិច្ចការសាធារណៈ នូវការរិះគន់ និងសេចក្តី

ស្មើសុំនានា សម្រាប់កែលំអការប្រព្រឹត្តទៅនៃអង្គការ និងស្ថាប័នទាំងនោះ និងសិទ្ធិទាញការយកចិត្តទុកដាក់ទៅលើទិដ្ឋភាពការងារនៃអង្គការ និងស្ថាប័នទាំងនោះ ដែលអាចរារាំង ឬបង្កឧបសគ្គដល់ការលើកស្ទួយ ការការពារ និងការសម្រេចបាននូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។

## មាត្រា ៩

១. ក្នុងការប្រើប្រាស់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន រួមមានការលើកស្ទួយ និងការការពារសិទ្ធិមនុស្សដូចមានចែងក្នុងសេចក្តីប្រកាសនេះផង ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗឯងក្តី និងដោយរួមជាមួយអ្នកដទៃ ទទួលបានការដោះស្រាយស័ក្តិសិទ្ធិ និងការការពារនៅពេលមានការរំលោភសិទ្ធិទាំងនោះ។

២. ដើម្បីសម្រេចទិសដៅនេះ ជនគ្រប់រូប ដែលយល់ថាសិទ្ធិ និងសេរីភាពរបស់ខ្លួន ត្រូវបានរំលោភ មានសិទ្ធិប្តឹងដោយខ្លួនឯងផ្ទាល់ ឬតាមរយៈតំណាងស្របច្បាប់ និងមានសិទ្ធិឱ្យពិនិត្យពាក្យបណ្តឹងនោះភ្លាម ក្នុងសវនាការជាសាធារណៈ ចំពោះមុខតុលាការ ឬអាជ្ញាធរផ្សេងទៀត ដែលឯករាជ្យមិនលំអៀង និងមានសមត្ថភាព ដែលបង្កើតឡើងដោយច្បាប់ និងមានសិទ្ធិទទួលបានពីអាជ្ញាធរនោះនូវសេចក្តីសម្រេចមួយស្របតាមច្បាប់ ដែលផ្តល់ការជួសជុលការខូចខាត រួមមានការសងជំងឺចិត្តសមស្របផង បើមានការរំលោភសិទ្ធិ ឬសេរីភាពរបស់ជននោះ ព្រមទាំងការអនុវត្តសេចក្តីសម្រេច និងសំណងជាយថាហេតុ ដោយគ្មានការពន្យារឱ្យយូរពេកទេ។

៣. ដើម្បីសម្រេចទិសដៅដដែលនេះ ជនគ្រប់រូប ដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃមានសិទ្ធិជាអាទិ៍ :

(ក) ប្តឹងអំពីគោលនយោបាយ និងសម្ថភាពរបស់មន្ត្រីម្នាក់ៗ និងស្ថាប័នរដ្ឋាភិបាល ចំពោះការរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន តាមរយៈបណ្តឹងទាមទារ ឬមធ្យោបាយសមស្របផ្សេងទៀតទៅអាជ្ញាធរតុលាការ រដ្ឋបាល ឬអង្គនីតិបញ្ញត្តិនៅក្នុងប្រទេស ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតដូចមានចែងក្នុងប្រព័ន្ធច្បាប់រដ្ឋនោះ ហើយអាជ្ញាធរទាំងនោះ ត្រូវធ្វើសេចក្តីសម្រេចលើពាក្យបណ្តឹងដោយឥតពន្យារពេលឱ្យហួសពេកទេ។

(ខ) ចូលរួមក្នុងសវនាការ នីតិជំនុំជំរះ និងការជំនុំជំរះក្តីជាសាធារណៈ ដើម្បីធ្វើការវិនិច្ឆ័យអំពីការប្រព្រឹត្តស្របតាមច្បាប់ជាតិ និងកាតព្វកិច្ចនិងការសន្យាអន្តរជាតិ។

(គ) ផ្តល់ជំនួយផ្នែកច្បាប់ដែលមានលក្ខណៈវិជ្ជាជីវៈ ឬគំនិតប្រឹក្សា និងជំនួយពាក់ព័ន្ធផ្សេងទៀត ក្នុងការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។

៤. ដើម្បីសម្រេចទិសដៅដែលនេះ និងស្របតាមលិខិតុបករណ៍ និងនីតិវិធីអន្តរជាតិពាក់ព័ន្ធ ជនគ្រប់រូប ដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ មានសិទ្ធិចូលជួប និងឆ្លើយឆ្លងដោយគ្មានការរារាំង ជាមួយអង្គការអន្តរជាតិ ដែលមានសមត្ថកិច្ចទូទៅ ឬពិសេសសម្រាប់ទទួល និងពិនិត្យបណ្តឹងស្តីពីបញ្ហាសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។

៥. រដ្ឋត្រូវស៊ើបអង្កេតជាបន្ទាន់ និងដោយមិនលំអៀង ឬត្រូវធានាថា ការស៊ើបអង្កេតមួយនឹងធ្វើឡើង បើមានមូលដ្ឋានសមហេតុផលឱ្យជឿបានថា ការរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានបានកើតឡើងក្នុងដែនដីស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

## មាត្រា ១០

គ្មានជនណាម្នាក់ ត្រូវចូលរួមរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដោយទង្វើក្តី ឬដោយការខកខានមិនបានធ្វើនៅពេលកាលៈទេសៈតម្រូវឱ្យធ្វើ និងគ្មានជនណាម្នាក់ ត្រូវទទួលទណ្ឌកម្ម ឬការសងសឹក ក្នុងប្រភេទណាមួយ ចំពោះការមិនព្រមធ្វើនោះឡើយ។

## មាត្រា ១១

ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ ប្រកបមុខរបរ ឬវិជ្ជាជីវៈស្របច្បាប់របស់ខ្លួន។ ជនគ្រប់រូប ដោយសារតែវិជ្ជាជីវៈរបស់ខ្លួន អាចប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ ត្រូវគោរពសិទ្ធិ និងសេរីភាពទាំងនោះ និងត្រូវគោរពបទដ្ឋានជាតិ និងអន្តរជាតិអំពីបទវិន័យ ឬក្រមសីលធម៌ខាងមុខរបរ និងវិជ្ជាជីវៈ។

## មាត្រា ១២

១. ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ ចូលរួមសកម្មភាពសន្តិវិធី ប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។

២. រដ្ឋត្រូវចាត់រាល់វិធានការចាំបាច់ ដើម្បីធានាឱ្យមាននូវការការពារពីអាជ្ញាធរមានសមត្ថកិច្ច ចំពោះជនគ្រប់រូប ដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ ប្រឆាំងនឹងអំពើហិង្សា ការគំរាម

កំហែង ការសងសឹក ការរើសអើងជាអវិភូតជាក់ស្តែង ឬតាមផ្លូវច្បាប់ ការគៀបសង្កត់ ឬសកម្មភាពតាមអំពើចិត្តផ្សេងទៀត ដោយសារតែការប្រើប្រាស់សិទ្ធិស្របច្បាប់របស់ខ្លួន ដែលមានចែងក្នុងសេចក្តីប្រកាសនេះ។

៣. ពាក់ព័ន្ធរឿងនេះ ជនគ្រប់រូបមានសិទ្ធិ ដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ ក្នុងការទទួលសិទ្ធិទទួលបានការការពារស័ក្តិសិទ្ធិស្របតាមច្បាប់ជាតិ ក្នុងការធ្វើប្រតិកម្មប្រឆាំង ឬជំទាស់តាមមធ្យោបាយសន្តិវិធី ចំពោះសកម្មភាព និងទង្វើនានា រួមមានការខកខានមិនបានធ្វើរបស់រដ្ឋ ដែលនាំឱ្យមានការរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានផង ព្រមទាំងអំពើហិង្សាប្រព្រឹត្តដោយក្រុម ឬដោយបុគ្គល ដែលធ្វើឱ្យប៉ះពាល់ដល់ការអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។

## មាត្រា ១៣

ជនគ្រប់រូប ដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ មានសិទ្ធិរៃអង្គាស ទទួលនិងប្រើប្រាស់ធនធានសម្រាប់ទិសដៅជាក់លាក់ក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន តាមមធ្យោបាយសន្តិវិធី ស្របតាមមាត្រា ៣ នៃសេចក្តីប្រកាសនេះ។

## មាត្រា ១៤

១. រដ្ឋមានការទទួលខុសត្រូវក្នុងការចាត់វិធានការខាងនីតិបញ្ញត្តិ តុលាការ រដ្ឋបាល ឬវិធានការសមស្របដទៃទៀត ដើម្បីជំរុញឱ្យមនុស្សគ្រប់រូបដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន យល់ដឹងអំពីសិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់គេ។

២. មធ្យោបាយទាំងនោះ រួមមានជាអាទិ៍ :

(ក) ការបោះពុម្ព និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយ នូវច្បាប់ និងបទបញ្ញត្តិជាតិ ព្រមទាំងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗដែលពាក់ព័ន្ធ។

(ខ) លទ្ធភាពទទួលបានពេញលេញ និងស្មើភាព នូវឯកសារអន្តរជាតិក្នុងវិស័យសិទ្ធិមនុស្ស រួមមានរបាយការណ៍ទៀងទាត់តាមកាលកំណត់ ដែលរដ្ឋធ្វើ និងផ្ញើជូនស្ថាប័ននានា ដែលបង្កើតឡើងស្របតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលរដ្ឋចូលជាភាគីផង ព្រមទាំងសំណុំរឿងសង្ខេបស្តីពីកិច្ចពិភាក្សា និងរបាយការណ៍ផ្លូវការរបស់ស្ថាប័នទាំងនេះ។

៣. បើសមស្រប រដ្ឋត្រូវធានា និងគាំទ្រដល់ការបង្កើត និងពង្រីកស្ថាប័នជាតិឯករាជ្យបន្ថែម ទោះស្ថាប័នទាំងនេះជាឱមប៊ុដស្ម៊ិន (មន្ត្រីតែងតាំងពិសេសឱ្យទទួលបណ្តឹង និងស៊ើបអង្កេតបណ្តឹង) ក្តី ជាគណៈកម្មការសិទ្ធិមនុស្សក្តី ឬជាស្ថាប័នជាតិតាមទម្រង់ណាមួយក្តី ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ក្នុងដែនដីក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

## មាត្រា ១៥

រដ្ឋមានការទទួលខុសត្រូវចំពោះការលើកស្ទួយ និងការសម្រួលដល់ការបង្រៀនសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន នៅគ្រប់កម្រិតសិក្សា និងត្រូវធានាថា អ្នកទាំងឡាយ ដែលទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលមេធាវី មន្ត្រីអនុវត្តច្បាប់ បុគ្គលិកនៃកងកម្លាំងប្រដាប់អាវុធ និងមន្ត្រីសាធារណៈ ត្រូវបញ្ចូលផ្នែកៗសមស្របនៃការបង្រៀនសិទ្ធិមនុស្សទៅក្នុងកម្មវិធីហ្វឹកហ្វឺនរបស់ពួកគេ។

## មាត្រា ១៦

បុគ្គល អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ មានតួនាទីសំខាន់ក្នុងការរួមចំណែកធ្វើឱ្យសាធារណៈជនយល់ដឹងកាន់តែច្រើនឡើង អំពីបញ្ហាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់ តាមរយៈសកម្មភាពនានា ដូចជាការអប់រំ ការហ្វឹកហ្វឺន និងការស្រាវជ្រាវក្នុងវិស័យទាំងនេះ ដើម្បីពង្រឹងបន្ថែម ជាអាទិ៍ ការយោគយល់ ការអត់ឱនឱ្យគ្នា សន្តិភាព និងទំនាក់ទំនងជាមិត្តភាពក្នុងចំណោមប្រជាជាតិ និងក្រុមពូជ សាសន៍និងសាសនាទាំងអស់ ដោយគិតដល់សាវតារផ្សេងៗរបស់សង្គម និងសហគមន៍ ដែលបុគ្គល អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នទាំងនោះ ធ្វើសកម្មភាព។

## មាត្រា ១៧

ក្នុងការប្រើប្រាស់សិទ្ធិ និងសេរីភាព ដែលមានចែងក្នុងសេចក្តីប្រកាសនេះ ជនគ្រប់រូប ដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ អាចស្ថិតក្រោមការដាក់កម្រិតព្រំដែនបាន លុះត្រាតែស្របតាមកាតព្វកិច្ចអន្តរជាតិពាក់ព័ន្ធ និងមានកំណត់ដោយច្បាប់ សម្រាប់តែធានាឱ្យមានការទទួលស្គាល់ និងគោរពសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ និងសម្រាប់តែតម្រូវដល់ការចាំបាច់ខាងសីលធម៌ សណ្តាប់ធ្នាប់សាធារណៈ និងសុខុមាលភាពទូទៅក្នុងសង្គមប្រជាធិបតេយ្យ។

## មាត្រា ១៨

១. ជនគ្រប់រូប មានករណីកិច្ចចំពោះសហគមន៍ និងក្នុងក្របខ័ណ្ឌសហគមន៍ ដែលជាកន្លែងតែមួយគត់ ដែលអាចឱ្យមានការអភិវឌ្ឍន៍ពេញលេញ និងដោយសេរីនូវបុគ្គលិកលក្ខណៈរបស់ខ្លួន ។

២. បុគ្គល ក្រុម ស្ថាប័ន និងអង្គការក្រៅរដ្ឋាភិបាលនានា មានតួនាទីសំខាន់ និងការទទួលខុសត្រូវមួយ ក្នុងការរក្សាការពារលទ្ធិប្រជាធិបតេយ្យ ក្នុងការលើកស្ទួយសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន និងក្នុងការធ្វើវិភាគទានជួយ លើកស្ទួយ និងធ្វើឱ្យជឿនលឿនទៅមុខនូវសង្គម ស្ថាប័ន និងដំណើរការប្រជាធិបតេយ្យ ។

៣. បុគ្គល ក្រុម ស្ថាប័ន និងអង្គការក្រៅរដ្ឋាភិបាល មានតួនាទីសំខាន់ និងការទទួលខុសត្រូវមួយដែរ ក្នុងការធ្វើវិភាគទានតាមលទ្ធភាពសមស្របជួយលើកស្ទួយសិទ្ធិរបស់ជនគ្រប់រូប ក្នុងការទទួលបាននូវសណ្តាប់ធ្នាប់សង្គម និងអន្តរជាតិ ដែលក្នុងនោះសិទ្ធិ និងសេរីភាព ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍សិទ្ធិមនុស្សផ្សេងទៀត អាចសម្រេចបានយ៉ាងពេញលេញ ។

## មាត្រា ១៩

គ្មានបទបញ្ញត្តិណាមួយក្នុងសេចក្តីប្រកាសនេះ ត្រូវយកមកបកស្រាយសម្រាប់ឱ្យបុគ្គល ក្រុម អង្គការសង្គម ឬរដ្ឋណាមួយ មានសិទ្ធិធ្វើសកម្មភាព ឬប្រព្រឹត្តអំពើណាមួយ សំដៅទៅ បំផ្លិចបំផ្លាញសិទ្ធិ និងសេរីភាព ដែលមានចែងក្នុងសេចក្តីប្រកាសនេះឡើយ ។

## មាត្រា ២០

គ្មានបទបញ្ញត្តិណាមួយក្នុងសេចក្តីប្រកាសនេះ ត្រូវយកមកបកស្រាយ សម្រាប់អនុញ្ញាតឱ្យរដ្ឋគាំទ្រ និងលើកស្ទួយសកម្មភាពរបស់បុគ្គល ក្រុមបុគ្គល ស្ថាប័ន ឬអង្គការក្រៅរដ្ឋាភិបាល ដែលផ្ទុយពីបទបញ្ញត្តិនៃធម្មនុញ្ញសហប្រជាជាតិឡើយ ។

--------//--------